OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Mar-2016, 13:14
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៣៧៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាឡេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក ស្រ៊ា រតនៈ

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

លោក ត្រាវីស ហ្វារ*(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោក គឹម ម៉េងឃី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ម៉ឺ ពៅ (2-TCCP-1013) | ខ្មែរ |
| លោក ម៉ាន ស្តែះ (2-TCCP-263) | ខ្មែរ |
| លោកស្រី សៀង ចាន់ថី (2-TCCP-1015) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី: លោក ម៉ើ ពៅ** (2-TCCP-1013)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៣

សួរដោយលោក ឡោ ជុនធី ផ្តើមពី ........................................ ទំព័រ ៥

សួរដោយលោក ស្រ៊ា រតនៈ ផ្តើមពី ........................................ ទំព័រ ១៦

សួរដោយលោក លីវ សុវណ្ណា ផ្តើមពី ........................................ ទំព័រ ២៦

សួរដោយលោក គង់ សំអុន ផ្តើមពី ........................................ ទំព័រ ៣៥

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី: លោក ម៉ាន ស្លេះ** (2-TCCP-263)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៤០

សួរដោយលោក គីម ម៉េងឃី ផ្តើមពី ........................................ ទំព័រ ៤២

សួរដោយលោក ពេជ អង្គ ផ្តើមពី ........................................ ទំព័រ ៥០

សួរដោយលោក ត្រាវីស ហ្វារ ផ្តើមពី ........................................ ទំព័រ ៥៤

សួរដោយលោក សុន អរុណ ផ្តើមពី ........................................ ទំព័រ ៦២

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី: លោកស្រី សៀង ចាន់ថី** (2-TCCP-1015)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៦៩

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ ទំព័រ ៧១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ ថ្ងៃស្អែក និងថ្ងៃខានស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់នូវសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលអះអាងថា ខ្លួនបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធនឹងអង្គហេតុការប្រព្រឹត្តទៅលើក្រុមគោលដៅជាក់លាក់ រួមមាន ចំពោះជនជាតិចាម ចំពោះជនជាតិវៀតណាម និងចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលសរុបនៅក្នុងបណ្ដាអង្គហេតុទាំងនេះ មានចំនួនប្រាំរូប ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1013, 2-TCCP-263, 2-TCCP-1014 ហើយនិង 2-TCCP-1015, 2-TCCP-259។ ដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មមុនគេនៅព្រឹកនេះ គឺដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1013។

ក្រឡាបញ្ជីសវនាការលោកស្រី សេ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៥:០០]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះនៃរឿងក្ដីនេះមានវត្តមាន។ លើកលែងតែលោក វ៉ិចទ័រ កូប៉េ មេធាវីអន្តរជាតិការពារក្ដីឲ្យលោក នួន ជា អវត្តមានដោយមិនមានមូលហេតុ។ ហើយលោកស្រី អង់តា ហ្គីសសេ មេធាវីការពារក្ដីឲ្យលោក ខៀវ សំផន អវត្តមានដោយមានធុរៈផ្ទាល់ខ្លួន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាព

ព្យសនកម្មនៅថ្ងៃនេះ មានចំនួនពីររូប គឺដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1013 និង 2-TCCP-263។ នៅក្នុងអំឡុងពេលនៃការថ្លែងទុក្ខសោកនេះ គឺមានបុគ្គលិកអង្គការ ធី.ភី.អូ លោក លឹម ប៊ុនហួរ -- ប៊ុន លឹមហួរ អង្គុយក្បែរដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយដើមបណ្ដឹងរដ្ឋប្បវេណី និង បុគ្គលិកអង្គការ ធី.ភី.អូ មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភ័ស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៧:០៧]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាព ជនជាប់ចោទនៅអ.វ.ត.ក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈ ឈឺចង្កេះ វិលមុខ ពេលអង្គុយយូរ និងពេលធ្វើចលនា ងាកចុះងាកឡើង និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន ៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពី

បន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ បង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1013 រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្ម រៀបរាប់អំពីទុក្ខសោកវេទនានៅចំពោះមុខអង្គជំនុំជម្រះក្នុងសាលសវនាការនេះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:៤៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក ម៉ី ពៅ៖**

**ឆ៖** ខ្ញុំឈ្មោះ ម៉ី ពៅ នៅភូមិក្រោលក្របី ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** លោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ? លោកអាចប្រាប់តុលាការបានទេ?

**ឆ៖** ខ្ញុំកើតនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៦១។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបរអីដែរ សព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំប្រកបមុខរបរកសិករ។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះខ្ញុំ -- ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ អ៊ុស្នាអែល។ ម្តាយខ្ញុំឈ្មោះ ឡស់ណុប។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ ម៉ាន អ៊ុស្នាក់។ កូនមានបួននាក់។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះសូមបញ្ជាក់បន្ថែម ជម្រាបភាគី និងសាធារណជនថា នៅក្នុងអំឡុងពេលនៃការស្ដាប់សេចក្ដីថ្លែងទុក្ខរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានសម្របសម្រួលជាមួយនឹងអង្គការ ធី.ភី.អូ រៀបចំឱ្យមានបុគ្គលិកអង្គការ ធី.ភី.អូ ម្នាក់អង្គុយនៅក្បែរដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីជួយសម្រួលផ្នែកអារម្មណ៍ដល់គាត់ ដើម្បីឱ្យគាត់មានស្មារតីនឹងនរ ក្នុងការថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់គាត់ នៅចំពោះមុខអង្គជំនុំជម្រះ។ ហើយនាពេលនេះគឺមានវត្តមានលោក ប៊ុន លឹមហួរ ភេទប្រុស ដែលជាបុគ្គលិកអង្គការ ធី.ភី.អូ ដែលអង្គុយក្បែរនៅជិតជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[០៩:១២:០៣]

លោក ម៉ី ពៅ ក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ លោក អង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅលោក ដើម្បីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោក ជាអាទិ៍ ខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ សម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យផ្ទាល់ពីបទឧក្រិដ្ឋដែលកើតមានឡើងពិតប្រាកដរហូតដល់ពេលសព្វថ្ងៃនេះ ដែលនាំឱ្យលោកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ដែលបានប៉ះពាល់ដោយផ្ទាល់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ហើយជាពិសេស គឺពាក់ព័ន្ធទៅនឹងអង្គហេតុប្រព្រឹត្តទៅលើក្រុមគោលដៅជាក់លាក់ចំពោះមុខអង្គជំនុំជម្រះ ចំពោះមុខ -- គោលដៅជាក់លាក់ចំពោះជនជាតិចាម ជនជាតិវៀតណាម ហើយនិងចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ នេះជាកម្មវត្ថុចម្បងនៃការធ្វើសក្ខីកម្មចំពោះអង្គហេតុដែលបាន ដែលពាក់ព័ន្ធដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនាពេលនេះ។

ហើយជាដំបូងនេះ អង្គជំនុំជម្រះសួរទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អំពីរបៀបរបបនៃការថ្លែងទុក្ខសោកវេទនានេះ តើឱ្យគាត់ថ្លែងទុក្ខសោកវេទនាដោយខ្លួនគាត់ ឬក៏លោករៀបចំនូវបែបបទក្នុងការតាំងសំណួរដូចអ្វីដែលធ្លាប់បានស្នើសុំពីមុនមក? បញ្ជាក់ឱ្យបានច្បាស់លាស់ដើម្បីអង្គជំនុំជម្រះគ្រប់គ្រងនីតិវិធីឱ្យប្រព្រឹត្តទៅបានល្អ។

[០៩:១៣:៤៦]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណីបួនរូបផ្សេងទៀត ដែលនឹងថ្លែងសក្ខីកម្មពាក់ព័ន្ធទៅនឹងការឈឺចាប់ និងព្យសនកម្មផ្សេងៗនោះ យើងខ្ញុំសូមលោកប្រធានអនុញ្ញាត ដើម្បីឲ្យការប្រព្រឹត្តទៅនៃការថ្លែងនេះ ជាបែបការសួរឆ្លើយ។ ហើយសូមបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នឹងមានសំណួរនៅពេលចុងក្រោយដែរ ហើយនឹងត្រូវធ្វើពេលឆាប់ៗនេះជូនទៅអង្គជំនុំជម្រះ។ ហើយអ្នកដែលនឹងសួរឆ្លើយ សួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ នេះគឺសូមអនុញ្ញាតលោកប្រធាន ឲ្យលោក វ៉ែន ពៅ -- ឡោ ជុនធី ជាអ្នកសួរ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រម និងតាមសំណួរសូមនេះ ហើយនិងផ្តល់វេទិកាជូនទៅមេធាវីនាំមុខតំណាង -- សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិ អាចធ្វើការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មុនគេ។ សូមអញ្ជើញ!

[០៩:១៥:០៤]

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះទាំងមូល សូមគោរពភាគី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** នៅពេលនេះខ្ញុំបាទសូមធ្វើការសួរទៅលោក ម៉ី ពៅ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីរបស់លោកផងដែរ។ នៅពេលនេះចង់ជម្រាបសួរទៅលើហេតុការណ៍ដែលលោកបានទទួលរងទុក្ខសោកពីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះគឺកំណត់យកចាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ តាមបទពិសោធន៍របស់លោកដែលបានឆ្លងកាត់ក្នុងរយៈកាលនេះ ហើយក្នុងនាមលោកដែលជាជនជាតិចាមផងដែរ ខ្ញុំបាទសុំសួរទៅលោកថា តើនៅក្នុងអំឡុងពេលដែលលោកបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកបានទទួលនូវរងការឈឺចាប់យ៉ាងណាខ្លះដែរ?

**លោក ម៉ី ពៅ៖**

**ឆ៖** អឺចឹងខ្ញុំសូមអរគុណ។ កាលពីឆ្នាំ១៩៧៥ របបខ្មែរក្រហមចូលកាន់កាប់ គេបានធ្វើបាបជនជាតិចាម ឲ្យជនជាតិចាមលះបង់សាសនា ឲ្យជនជាតិលះបង់ទ្រព្យសម្បត្តិ ឲ្យជនជាតិចាមលះបង់ភូមិកំណើត ញាតិមិត្ត សាច់សាលោហិត។ អឺចឹងជម្លៀសខ្ញុំចេញពីភូមិកំណើត។ ហើយពេលនោះខ្ញុំទៅរបបខ្មែរក្រហមឲ្យចេញពីគ្រួសារ ព្រាត់ប្រាសបងប្អូន ព្រាត់ប្រាសសាច់ញាតិ ព្រាត់ប្រាសភូមិកំណើតខ្លួនឯងផ្ទាល់។ អឺចឹងជីវភាពក៏គ្មាន សាលារៀនក៏គ្មាន សាសនាក៏គ្មាន ឪពុកម្ដាយក៏គ្មាន បងប្អូនក៏គ្មាន រស់នៅតាមអង្គការកំណត់។ អង្គការប្រើប្រាស់ខ្ញុំ ឲ្យហូបអាហារពុំគ្រប់គ្រាន់ ឲ្យញុំាចំណីមិនគ្រប់គ្រាន់ ធ្វើការតាមអង្គការកំណត់ ទាំងយប់ទាំងថ្ងៃ ហើយស្គមស្បែកដណ្ដប់ឆ្អឹង ហើយបបរតែមួយវែក។ បើសិនមិនធ្វើការបានសម្រេចតាមផែនការទេ អង្គការនឹងដករបបយើងបន្ថែមទៀត។ ហេតុនេះហើយបានជាទុក្ខសោកវេទនា បើសិនជាខ្ញុំរៀបរាប់គឺពិបាកខ្លាំង។ កម្លាំងខ្ញុំក្មេងអាយុ១៣ឆ្នាំ ១៤ឆ្នាំ បាត់បងឪពុកម្ដាយ ឈឺថ្កាត់ ដេកក្រោមដើមឈើម្នាក់ឯង ជម្រកផ្ទះសម្បែងក៏គ្មាន ដេកហាលភ្លៀង ហាលផ្គរ មូស ខាំ សាច់ញាតិក៏គ្មាន។ អ្វីៗទាំងអស់នេះហើយបានជាខ្ញុំពិបាក។

[០៩:១៩:២២]

**ស៖** បាទ អរគុណ។ ដោយសាររឿងហេតុនេះហើយ អម្បាញ់មិញលោកបានលើកឡើងថា គឺពាក់ព័ន្ធនឹងជនជាតិចាមត្រូវបានគេបំបែកចេញពីគ្រួសារ។ ខ្ញុំបាទជម្រាបសួរថាតើការបំបែកចេញពីគ្រួសារហ្នឹងយ៉ាងដូចម្ដេចដែរ?

**ឆ៖** សូមអរគុណ។ ការបំបែកជម្លៀសចេញពីគ្រួសារឲ្យទៅនៅតាមសមរភូមិ ឲ្យធ្វើការងារអ្វីក៏ដោយឲ្យតែអង្គការកំណត់ ហើយឲ្យលះបង់សាសនា គឺមិនឲ្យគោរពសាសនា ហើយមិនឲ្យប្រើភាសាចាមជាភាសាដើមទេ បើអ្នកណាហើយនិយាយ អង្គការនឹងយកទៅប្រហារជីវិត។ នេះហើយធ្វើឲ្យខ្ញុំមានការភ័យភិត មានការតក់ស្លុត គ្មានអ្វីទីពឹង។

**ស៖** បាទ អរគុណ។ ចំណុចដែលលោកបានលើកឡើងហ្នឹងគឺពាក់ព័ន្ធ អម្បាញ់មិញខ្ញុំបានលើកសំណួរ ថាតើការដែលលោកបានលើកឡើងអម្បាញ់មិញ ថាមានបំបែកមានការហាមឃាត់ទៅលើសាសនាហ្នឹង តើមានការប្រកាសចេញពីខាងណាដែរ ឬមួយអត់ទេ?

**ឆ៖** អរគុណ។ ខ្ញុំសូមត្រឡប់ខាងដើមវិញថា កាលពីឆ្នាំ១៩៧៥ គឺសហករណ៍បានប្រកាសឲ្យសាសនាអ៊ីស្លាម -- ឲ្យជនជាតិចាមកាត់សក់ខ្លី មិនឲ្យទទូរក្បាល មិនឲ្យគោរពប្រពៃណីរបស់អ៊ីស្លាម

ហើយក៏មិនឲ្យជនជាតិចាមរស់នៅជាក្រុម ឬមួយជាពួកដែរ។ ជម្លៀសពីភូមិមួយទៅភូមិមួយ ពីសហករណ៍មួយទៅសហករណ៍មួយ ពេលនោះហើយខ្ញុំមិនបានដឹងឮដំណឹងអ្វីពីសាច់ញាតិទាល់តែសោះ។

[០៩:២២:០១]

**ស៖** បាទ អរគុណ។ សំណួរបន្ទាប់ទៀត គឺថាតើការប្រកាសហ្នឹង តើប្រកាសនៅកន្លែងណា? នៅភូមិអី ឃុំអី ដែលលោកបានទទួលព័ត៌មានថាប្រកាសពីបញ្ហាហាមឃាត់នេះ?

**ឆ៖** អរគុណ។ ការប្រកាសនៅភូមិអន្ទាក់គួយ ឃុំខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ ការប្រកាសឲ្យលះបង់របស់របបខ្មែរក្រហម។ ហើយជម្លៀសខ្ញុំជាគ្រួសារមួយតូចមកនៅក្នុងសហករណ៍ត្រាំសេះ។ ពេលនោះហើយ ខ្ញុំក៏នៅក្នុងសហករណ៍ហ្នឹងមិនបានប៉ុន្មានថ្ងៃផង ខ្ញុំចាំមិនច្បាស់ គឺអង្គការបញ្ជូនខ្ញុំទៅឲ្យជីប្រឡាយ និងលើកទំនប់។

**ស៖** បាទ អរគុណ។ ចំណុចដែលថាក្រោយពីប្រកាសហ្នឹងហើយ តើវាមានឥទ្ធិពលប៉ះពាល់ទៅលើរូបលោកផ្ទាល់ ពីការអនុវត្តលើសាសនានេះ? តើការអនុវត្តលើសាសនាហ្នឹង វាប៉ះពាល់ទៅលើជនជាតិចាម ដូចជារូបលោកហ្នឹង យ៉ាងដូចម្ដេចខ្លះ?

**ឆ៖** អរគុណ។ ការប៉ះពាល់ជនជាតិចាម គឺសំខាន់បំផុត គឺគាត់របបខ្មែរក្រហមឲ្យហូបសាច់ជ្រូក។ អ្វីៗដែលខ្មែរធ្វើទៅបាន គឺឲ្យជនជាតិចាមធ្វើតាមទាំងអស់។ នេះហើយហៅថាការលំបាកវេទនាអាហារក៏គ្មាន សាសនាក៏គ្មាន អ្វីៗក៏គ្មាន ហើយស្គមកំព្រឹងរីងរៃ ហើយអង្គការកំណត់ឲ្យហូប ធ្វើបាបទុក្ខទោស បុកម្នេញគ្រប់សព្វបែបយ៉ាង។ បើនិយាយពីរឿងការលំបាកនេះ រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃនេះ ខ្ញុំពិបាកខ្លាំងណាស់។

[០៩:២៤:៣៧]

ទី១ ខ្ញុំជាកុមារ បាត់បង់កម្លាំងកាយ បាត់បង់កម្លាំងចិត្ត ហើយពួកវាបានភ្ជង់ខ្ញុំ ចោទថាខ្ញុំក្បត់នឹងអង្គការ។ កាំភ្លើងអា.កាបីដើម អឹម.សីពីរដើម ខ្ញុំកំពុងតែភ្ជួររាស់ ពួករបបខ្មែរ -- ពួកឈ្លបបានព័ទ្ធខ្ញុំជុំវិញ ហើយចោទប្រកាន់ខ្ញុំថា ពួកខ្ញុំជាខ្មាំង ក្បត់នឹងអង្គការ លួចបួតស្រូវ។ តែធាតុពិតខ្ញុំមិនបានធ្វើអ្វីទាំងអស់ ខ្ញុំចេះតែពីធ្វើការ។ ហើយរហូតដល់វាយដំច្រំធាក់ វៃខ្ញុំតាមអំពើចិត្ត រហូតដល់ប៉ះពាល់ទៅលើស្នារាល់ថ្ងៃ គ្រេចចង្កេះរាល់ថ្ងៃ។ ហើយពេលនោះវាចងសេកខ្ញុំហើយ ហើយវាបណ្ដើរខ្ញុំ ពួកវាជិះសេះបើខ្ញុំរត់មិនទាន់សេះទេ ពួកវាវៃ។ ហើយបញ្ជូនខ្ញុំទៅដល់ត្រាចក្រោល វាធ្វើទុក្ខទោស បុកម្នេញ វាយកខ្ញុំទៅចូលក្នុងមន្ទីរ ហើយអាហារក៏គ្មាន។ បបរមានតែទឹក ឲ្យខ្ញុំធ្វើពលកម្ម ឲ្យខ្ញុំជីកដី គាស់គល់ឈើ

ហើយវ៉ៃខ្ញុំថែមទៀត។ ហើយអ្នកណា ហើយដើរដួល ដែលអស់កម្លាំងវាវ៉ៃថែមឲ្យងើប បើអ្នកណាងើបមិនរួចវាយវ៉ៃទាល់តែយើងក្រោក។ នេះហើយជាទុក្ខលំបាកវេទនា ដែលខ្ញុំជាកុមារមួយដ៏តូចរស់នៅក្នុងគុក ម្នាក់ឯងគត់អត់មានសាច់ញាតិ។ បើសិនជាយើងនិយាយគ្នា វាថាយើងចង់បំផុស។ បើសិនណាយើងមិននិយាយគ្នា ប្រហែលអ្នកជាប់គុកជាមួយគ្នា ខ្ញុំមិនដែលស្គាល់ឈ្មោះមួយម៉ាត់ទេ ហៅតែមិត្ត។ បើមិនហៅមិត្តទេ វាវ៉ៃចោលទៀត។ ហេតុដូច្នេះហើយ បានជាការលំបាករបស់ខ្ញុំ ខ្ញុំពិបាកនិយាយរៀបរាប់។ ហើយពេលនោះ ពេលដែលវាចង់ធ្វើបាបយើង ធ្វើបាបផ្លូវចិត្តយើង វាយកមនុស្សមក វាធ្វើជាមិទ្ទីង វាសម្លាប់នៅនឹងមុខ ហើយវាឲ្យយើងមើលជាក់ស្តែងថា ចំណុចណាដែលមិត្តឯងប៉ាន់តែក្បត់នឹងអង្គការ អ្នកនោះហើយត្រូវតែស្លាប់ ដូចមិត្តនោះ។ អ៊ីចឹងខ្ញុំជាក្មេងតូច ខ្ញុំមានភ័យតក់ស្លុត ខ្លាច បើនិយាយរាល់ថ្ងៃនេះ ខ្ញុំនៅតែភ័យបារម្ភ ហាក់បីដូចជាអ្វីៗមកនៅនឹងភ្នែកខ្ញុំទាំងអស់។ ពេលនោះហើយខ្ញុំដេកចាំតែថ្ងៃស្លាប់ទេ ខ្ញុំអត់មានអ្វីសង្ឃឹមទាល់តែសោះ។ ឪពុកម្តាយ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ខ្ញុំមិនដែលជួបគាត់ ឮតែដំណឹងថាគាត់សម្លាប់ ដោយរបបខ្មែរក្រហមបង្អត់អាហារគាត់ ដោយសារគាត់មិនលះបង់ ឲ្យហុតបបរតែមួយវែកសុទ្ធតែទឹក ម្ល៉ោះហើយរហូតដល់គាត់ដាច់ខ្យល់។ ឪពុកទាំងមូលអត់បានទៅមើលទៀត ខ្លួនជាប់គុកទៀត។ ហើយពេលនោះ អ្វីៗក៏ខ្ញុំលះបង់អស់ដែរ តែប្រហែលសាច់ជ្រូកក៏ខ្ញុំហូបដែរ អ្វីក៏ដោយឲ្យតែអង្គការកំណត់ គឺខ្ញុំហូបទាំងអស់ ឲ្យតែជីវិតរស់។

[០៩:២៨:១២]

**ស៖** បាទ អរគុណ។ លោកបានលើកឡើងអម្បាញ់មិញ ថាតើការឈឺចាប់ដែលបណ្តាលមកពីសាច់ញាតិស្លាប់ តើក្នុងសម័យនោះលោកមានសាច់ញាតិស្លាប់ហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** សូមអរគុណ។ សាច់ញាតិខ្ញុំស្លាប់ ទាំងយាយ ទាំងតា ទាំងម្តាយ អ៎! ទាំងឪពុក ទាំងមីងទាំងមា ១៧នាក់ មិនដែលឃើញមុខទេ។ តែក្មួយបង្កើតជាទីស្រឡាញ់ក៏ស្លាប់ ដោយរបបប្រល័យ -- ដោយរបបខ្មែរក្រហមដែរ។ ហេតុដូចនេះហើយបានថា ការទុក្ខសោករបស់ខ្ញុំ នៅតែមានដក់ជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំរហូតដល់ពេលសព្វថ្ងៃនេះ។

**ស៖** បាទ អរគុណ។ អម្បាញ់មិញលោកបានលើកឡើងថា អ្នកដែលបានស្លាប់នោះ១៧នាក់។ ខ្ញុំចង់ដឹងថា តើឪពុករបស់លោកស្លាប់ដោយមូលហេតុអីដែរ?

**ឆ៖** អរគុណ។ ឪពុកខ្ញុំស្លាប់ដោយសារមូលហេតុគាត់ជាជនជាតិចាម គាត់កាន់សាសនាអ៊ីស្លាម ហើយគាត់គឺជឿជាក់ទៅលើសាសនា គាត់មិនធ្វើតាមអង្គការកំណត់ ពេលនោះគេយកសាច់

ជ្រូកមកឲ្យគាត់ពិសា តែគាត់មិនព្រមទេ។ អ៊ីចឹងអង្គការបានដាក់ផែនការឲ្យគាត់ "បើមិត្តមិនហូបសាច់ជ្រូកទេ អង្គការមានសាច់ជ្រូកឲ្យមិត្តហូប ហើយបើមិត្តមិនហូបទេ អង្គការមិនដឹងជារកអ្វីឲ្យមិត្តឯងហូបទេ។" អ៊ីចឹងហើយពេលនោះ ឪពុកខ្ញុំ គាត់ហូបតែទឹក ហើយគាត់រកលួចលាក់បេះឈើ បេះស្លឹកឈើ ស្លឹកព្រៃរស់ រស់ទាំងត្រដរ។ រហូតការវេទនារបស់គាត់នេះ កាលពីសម័យនោះ ខ្ញុំគិតថា បើគេសម្លាប់គាត់ល្អជាជាងទុកឲ្យគាត់ ធ្វើទារុណកម្មគាត់បែបនេះ។ តែពួកខ្មែរក្រហមវាមិន -- របបខ្មែរក្រហមគឺមិនធ្វើទេ អ្វីដែលថានេះគឺទុក្ខឲ្យវេទនាហ្នឹងហើយ ជាគំរូរបស់អ្នកក្រោយៗមកទៀត។ ពេលនោះហើយ គាត់រស់នៅដោយស្បែកនិងដណ្ដប់ឆ្អឹង ឪកូន ក៏ព្រាត់ប្រាស ប្រពន្ធក៏ព្រាត់ប្រាស សាច់ញាតិក៏ព្រាត់ប្រាស រហូតដល់គាត់ស្លាប់តែឯង។ អត់មានអ្នកណាមើលមុខគាត់ជាលើកចុងក្រោយ ឬមួយគាត់ ដឹងគេកប់ផ្នូរនៅឯណា។ ពេលនោះខ្ញុំសុំច្បាប់អង្គការដែរ គ្រាន់គេឲ្យដំណឹងទេ ការណ៍ដំណឹងនេះគឺជាបញ្ឈើលើសដើម ថែមឲ្យខ្ញុំទុក្ខសោកបន្ថែមទៀត។ វាថា ពុកមិត្តឯងងាប់ហើយ ដល់តែខ្ញុំថា បើពុកខ្ញុំងាប់ហើយ ខ្ញុំសុំអង្គការ សុំមេកងឲ្យទៅមើលគាត់បានអត់? គាត់ថា មិនមែនខ្ញុំអង្គភាពអ្នកកប់ខ្មោចទេ អ៊ីចឹងទុកឲ្យគេអ្នកកប់ទៅ មិត្តឯងដឹងតែពីធ្វើការទៅ។ អ៊ីចឹងក៏គេ អត់ឲ្យច្បាប់ខ្ញុំទៅដដែលទេ។ ប៉ុន្តែគ្រាន់តែដំណឹង ឮដំណឹងពីមេកងថា ពុកយើងស្លាប់ហើយ តែប៉ុណ្ណោះ។

[០៩:៣២:២៦]

**ស៖** បាទ អរគុណ។ ក្រោយពីលោកឪពុករបស់លោកបានស្លាប់ទៅហ្នឹង តើលោកបានទទួលដំណឹងថា ខាងសាច់ញាតិហ្នឹងបានធ្វើបុណ្យធ្វើអីតាមសាសនាឲ្យគាត់ដែរអត់ទេ?

**ឆ៖** អរគុណ។ ពេលដែលគាត់ស្លាប់ អត់មានអ្នកណាម្នាក់ទៅនៅក្បែរគាត់ទេ។ អត់មានអ្នកណាទៅធ្វើបុណ្យឲ្យគាត់ទេ ពីព្រោះអីពេលនោះរបបនោះ អត់មានបុណ្យអត់មានសាសនា អត់មានប្រពៃណី អត់មានទំនៀមទម្លាប់ទេ។ អ៊ីចឹងបើគាត់ស្លាប់ មានកងកប់ខ្មោចផ្សេងទៅ ហើយបើខ្ញុំធ្វើការអ្វី ឲ្យខ្ញុំទៅធ្វើការហ្នឹងទៅ។ អ៊ីចឹងអ្នកស្លាប់គឺមានកងគេផ្សេង។ សាច់ញាតិបងប្អូនខ្ញុំទាំងអស់ គ្មានអ្នកណាដឹងថាគាត់ ខ្លះមកអត់ដឹងថា គាត់ស្លាប់ផងក៏មានដែរ។ ការព្រាត់ប្រាសវេទនាណាស់។

**ស៖** បាទ អរគុណ។ សូមលោកអាចរៀបរាប់បន្ថែមទៀតដែលពាក់ព័ន្ធនឹងសាច់ញាតិសំខាន់ណាដែលលោកបានដឹងថា គេយកគាត់ទៅធ្វើបាប ឬសម្លាប់នោះ។ តើលោកមានបានដឹងព័ត៌មានបន្ថែមទេ?

**ឆ៖** អរគុណ។ ឪពុកមាខ្ញុំបង្កើត គេចោទប្រកាន់ថា ឪពុកមាខ្ញុំក្បត់នឹងអង្គការ។ គេចាប់គាត់

យកទៅសម្លាប់។ តែមិនមែនសម្លាប់តាមធម្មតាទេ គឺគេអង្កន់សាច់គាត់ទាំងរស់ ហើយគេយកគាត់ប្រឡាក់អំបិល ទម្រាំដាច់ខ្យល់។ នេះអ្នកដឹងឮ គឺកូនគាត់បង្កើត ឈ្មោះ ទ័ម អាឡី។ ឪពុកមាខ្ញុំបង្កើតផ្តាប់រស់នៅថ្នាក់ថ្នមខ្ញុំ បីបម គាំពារគ្នាទៅវិញទៅមក។ ពេលនោះហើយ បានថាការធ្វើទារុណកម្មចំពោះរូបគាត់ គឺវេទនាណាស់ លំបាកណាស់មុននឹងស្លាប់ ទម្រាំស្លាប់។

[០៩:៣៥:២៦]

**ស៖** បាទ អរគុណ។ ថាតើការដែលគេធ្វើទារុណកម្មគាត់ហ្នឹង នៅភូមិដែលលោករស់នៅដែរ ឬមួយនៅក្នុងខេត្តណាដែរ?

**ឆ៖** ការធ្វើទារុណកម្មចំពោះរូបគាត់ នៅភូមិតាលោ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** អរគុណ។ តើលោកអាចរៀបរាប់បន្ថែមទៀតទេ នៅពេលដែលគេចាប់លោកទៅដាក់គុកហ្នឹង តើគុកហ្នឹងជាគុកអ្វីដែរ?

**ឆ៖** អរគុណ។ ពេលគេយកខ្ញុំទៅដាក់គុកមន្ទីរត្រាចក្រោល ពេលនោះខ្ញុំឃើញច្បាស់ជឿជាក់នឹងភ្នែក គឺការសម្លាប់មនុស្ស ស្ត្រីម្នាក់។ ថ្ងៃមួយពួកខ្ញុំចេញទៅធ្វើការ វាចោទប្រកាន់ថាស្ត្រីជាសីលធម៌ អ៊ីចឹងស្ត្រីនោះ គេឲ្យអាក្រាតអស់ ហើយគេវះពីខ្លាសមករហូតដល់ស្បូន។ ស្ត្រីបានស្រែកឈឺចាប់ ខ្លោចផ្សា។ ហើយខ្ញុំជាកុមារ ជាអ្នកជាប់ទោស គេឲ្យយើងឈរមើល គេធ្វើមិទ្ទីងមួយ សម្រាប់មិនឲ្យពួកយើងទាំងអស់គ្នាសីលធម៌ ដូចបែបបទនារីនោះ តែធាតុពិតខ្ញុំមិនបានឃើញច្បាស់ ថាតើមានគភ៌នៅក្នុងហ្នឹង ឬមួយមិនមែនមានគភ៌ ខ្ញុំអត់បានឃើញទេ ព្រោះអីពេលនោះ ឈាមវាច្រើនពេក ហើយខ្ញុំកំពុងតែស្លុតដែរ។ ហើយពេលនោះក៏វាយវះយកថ្លើមមក វាយកមកឆាស៊ី។ វាថា “បើមិត្តឯងក្បត់ គឺថ្លើមអ្នកឯង ត្រូវតែអញស៊ីអ៊ីចឹង។” នេះហើយហៅថា ការភ័យខ្លាច ការរន្ធត់ដែលខ្ញុំនៅតូចផង។ អ៊ីចឹងហើយពេលនោះអ្វីៗក៏ខ្ញុំលះបង់ដែរ។ ប្រហែលតែឈ្មោះខ្លួនឯង ក៏ខ្ញុំប្តូរអស់ដែរ គឺកាលពីមុនខ្ញុំឈ្មោះ អែល មហាម៉ាត់ តែចុងក្រោយមក ខ្ញុំដាក់ឈ្មោះ ម៉ុី ពៅ។ អ៊ីចឹងអាឈ្មោះនេះ គឺខ្ញុំរស់លាក់ប្រវត្តិ ខ្ញុំខ្លាចអង្គការ គេតាមដានដឹង ព្រោះអីខ្ញុំជាពិរុទ្ធជនរបស់គេ។ បើគេដឹងថា ខ្ញុំចាមទៅទៀត រឹតតែពួកវាធ្វើបាបខ្ញុំ។ អ៊ីចឹងពេលនោះហើយ ខ្ញុំអ្វីៗក៏ខ្ញុំលះបង់អស់ សូម្បីតែអ្វីក៏ដោយ ឲ្យតែជីវិតបានរស់ ទ្រាំរស់ ហើយចេញទៅធ្វើការ។ យប់ឡើងដេកជាប់ខ្នោះ ថ្ងៃឡើងជាប់ច្រវាក់ ទៅធ្វើការ។ ហើយខ្ញុំនៅតូច ខ្ញុំដើរអត់ទាន់គេច្រើនតែគេវាយខ្ញុំពីក្រោយ គេបង្ខំខ្ញុំដូចជាសត្វពាហនៈ លើសពីសត្វពាហនៈទៅទៀត។ តែធ្វើម៉េចខ្ញុំត្រូវរស់ ប្រឹងប្រែង ខាំធ្មេញ សង្កត់ចិត្ត។

[០៩:៣៩:១៦]

មិនមែនត្រឹមប៉ុណ្ណឹងទេ អ្វីៗក៏ដោយដែលនៅក្នុងគុក គឺគេសម្លាប់មនុស្ស ដែលល្បួបសម្លាប់មនុស្ស គ្មានមានហេតុផលទេ គឺឲ្យតែសម្លាប់ គឺវាឲ្យយើងឈរមើលហើយ។ បើយើងមិនឈរមើលទេ គេថាយើងហ្នឹងស៊ុមគ្រលុំជាមួយខ្មាំងទៀត ម្ល៉ោះហើយខំប្រឹងឈរញ័រជើង ញ័រដៃ។ បើថាយើងហើយធ្វើភ័យភិត យើងអាណិតយំ ក៏វាវាយយើងចោលដែរ។ ម្ល៉ោះហើយពេលនោះឯង យើងទប់ទឹកភ្នែក និងទប់អារម្មណ៍ ដើម្បីទ្រាំរស់ ខ្លាចលោអង្គការគេដឹងថា យើងសាច់ញាតិ សាច់ឈាមអី។ ឲ្យតែពេលវាសម្លាប់មនុស្សម្តងៗ គឺវាហៅយើងទៅមើលហើយទាំងអស់ ក្នុងគុក។ មិនថាចាស់ មិនថាក្មេងទេ មិនថាតូច មិនថាធំ។ រឺបើថាចេញទៅធ្វើការវិញ បើយើង គេហូតខ្នោះរនុកយើងហើយ បើយើងមិនស្ទុះស្ទាទេ គេវៃបង្ខំយើង គេទាត់យើងចេញពីទ្វារគុក។ ហើយពេលដេកជើងជាប់ខ្នោះ ខ្លួនដេកនឹងដី នឹងកម្រាលគេចាក់សាប។ ពោះអត់ឆ្អែត អត់ហ៊ាននិយាយគ្នា បើអ្នកនិយាយគ្នា វាឮ វាថាយើងរកល្បួចហែកគុក។ ពេលនោះប្រហែលអ្នកនៅជាមួយគ្នាប្រហែល៤០នាក់ ខ្ញុំមិនដែលស្គាល់ឈ្មោះអ្នកណាម្នាក់ទេ ហើយក៏ខ្ញុំមិនដែលស្គាល់មុខគ្នាដែរ។

**ស៖** បាទ អរគុណ។ ចាតើអ្វីដែលលោកបានរៀបរាប់អម្បាញ់មិញហ្នឹង វាកើតនៅកន្លែងណា? ហើយបើលោកអាចបញ្ជាក់បានអាចថាឆ្នាំណាដែរ?

**ឆ៖** អរគុណ។ កាលពីពួកវា ខ្ញុំ កាលពីឆ្នាំ១៩៧៧ ចុងឆ្នាំ១៩៧៧ ដើមឆ្នាំ១៩៨០ ពេលនោះហើយពួកវាចាប់ខ្ញុំយកទៅដាក់មន្ទីរឃុំឃាំងត្រាចក្រោល នៅសហករណ៍ត្រាង។

**ស៖** បាទ អរគុណ។ លោកអម្បាញ់មិញបានបញ្ជាក់ឆ្នាំថា ចុងឆ្នាំ១៩៧៧ ហើយដើមឆ្នាំមួយប្រាំបួនរយប៉ុន្មាន លោកលើកឡើងអម្បាញ់មិញ?

[០៩:៤២:១២]

**ឆ៖** ចុងឆ្នាំ១៩៧៧ ដើមឆ្នាំ១៩៧៨។

**ស៖** បាទ អរគុណ។ លោកអម្បាញ់មិញបានបញ្ជាក់ថា ត្រូវគេចាប់ទៅដាក់នៅក្នុងគុកនោះយប់ឡើងគេដាក់ខ្នោះ ថាពេលថ្ងៃគេដាក់ច្រវាក់ ឬមួយយ៉ាងម៉េចសូមឲ្យបញ្ជាក់អង្គជំនុំជម្រះបានស្តាប់ផងបាទ?

**ឆ៖** បាទ អរគុណ។ ពេលយប់ឡើងគេដាក់ខ្នោះខ្ញុំ ពេលថ្ងៃឡើងគេបញ្ចេញយើងទៅធ្វើការ គេទាក់ច្រវាក់យើង គឺជើងម្ខាង ហើយម្នាក់ទៀតជើងម្ខាង។

**ស៖** បាទ អរគុណ។ អ៊ីចឹងមានន័យថា ពេលដែលគេបញ្ចេញទៅធ្វើការក៏គេដាក់ច្រវាក់ដែរ? មានន័យអ៊ីចឹង ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ អរគុណ។ ពេលយប់ឡើងខ្ញុំជាប់ខ្នោះ ពេលថ្ងៃឡើងខ្ញុំទៅធ្វើការ ខ្ញុំជាប់ច្រវាក់។ ច្រវាក់មួយខ្សែហ្នឹងគឺពីរនាក់។ បើសិនជាអ្នកហើយដើរដួល ឬមួយទាក់គល់ឈើដួលទាំងពីរ គឺពេលនោះឯងពួកវើឱ្យយើងក្រោក។ ថ្ងៃជាប់ច្រវាក់ យប់ជាប់ខ្នោះ ទាំងធ្វើការទៀត។

**ស៖** បាទអរគុណ។ ថាតើលោកបានដឹង ទី១ពាក់ព័ន្ធទៅនឹងទីតាំង តើច្បាស់លាស់ទេ ហើយខ្ញុំចង់បន្ថែមទៀតថា តើនៅពេលនោះ គេផ្តល់អាហារទៅអ្នកដែលជាប់ក្នុងគុកហ្នឹងយ៉ាងដូចម្តេចដែរ?

[០៩:៤៤:៤៩]

**ឆ៖** ទីតាំងគេចាប់ខ្ញុំពីសហករណ៍ត្រាង មកជាប់គុកនៅសហករណ៍ អ៎! មកជាប់គុកនៅត្រាចក្រោល ចម្ងាយដីពីភូមិប្រហែលជា១០គីឡូម៉ែត្រ។ ហើយពេលម្ហូប របបគឺខ្ញុំមិនដែលស្គាល់ទេជាតិអង្ករ ខ្ញុំស្គាល់តែជាតិទឹក មួយវែក គេធ្វើមកអំពីវែក គេធ្វើអំពីត្រឡោកដូង មួយវែក។ ពេលនោះបើសិនជាអ្នកណាម្នាក់ហ៊ានតវ៉ា ហ៊ានថាមិនឆ្អែត គឺអ្នកនោះឯង គឺក្បត់នឹងអង្គការ។ ហើយពេលនោះឯង បើសិនជាអ្នកក្បត់នឹងអង្គការ គឺគេចាប់យកមកវាយប្រហារធ្វើជាមិទ្ទីងមួយ។ ម្ល៉ោះហើយពេលហ្នឹងឯង ខ្ញុំខិតខំប្រឹងប្រែងដើម្បីរិះរក ឱ្យតែមានអាយុជីវិតរស់។ ពេលនោះពេលដែលខ្ញុំលះបង់អ្វីៗទាំងអស់ សូម្បីតែអ្វីក៏ដោយ ក៏ខ្ញុំលះបង់ដែរ។

**ស៖** អរគុណ។ ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច ថាតើនៅក្នុងរបបនុំងលោកនៅក្មេង តើលោកបានទទួលការរៀនសូត្រដែរឬទេ?

**ឆ៖** អរគុណ។ កាលពីនៅរបបនោះ សាលារៀនក៏គ្មាន លោកគ្រូអ្នកគ្រូក៏គ្មាន ឪពុកម្តាយក៏គ្មាន បងប្អូនក៏គ្មាន សាច់ញាតិក៏គ្មាន មានតែធ្វើពលកម្ម។ ហេតុនេះហើយបានថា ការលំបាកផ្លូវចិត្ត ខ្ញុំគិតឃើញថា ប្រហែលគេជិតខាងគេកំពុងតែស្លៀកពាក់ស ហើយខោខៀវ តែចំណែករូបខ្ញុំវិញកំពុងតែវែកដី កំពុងតែធ្វើពលកម្មជូនអង្គការ។ ចំណេះដឹងក៏គ្មាន អ្វីក៏គ្មាន មានតែកម្លាំង មានតែពលកម្ម តែស្បែកក៏ស្គម នៅសល់តែឆ្អឹង ពេលនោះហើយបានខ្ញុំគិតថា ការពិចារណាយប់ក៏គេងមិនបាន ថ្ងៃក៏មិនបានសម្រាក អ៊ីចឹងហើយហេតុនេះ បានថាខ្ញុំមានការសោកស្តាយខ្លាំងណាស់ ដែលអ្វីៗដែលមកប៉ះពាល់ទៅដល់ជីវភាពក្រុមគ្រួសារខ្ញុំដល់រហូតដល់បច្ចុប្បន្ន។ នេះហើយវាជារឿងមួយគួរតែបងប្អូនគិតវេទនា។

[០៩:៤៨:០០]

**ស៖** បាទ អរគុណ។ ថាតើពាក់ព័ន្ធនឹងការសិក្សានេះ លោកនៅពេលនោះ បានន័យអត់មានសាលារៀនទេ តើការបន្សល់នៃការដែលមិនបានរៀនបានសូត្រហ្នឹង វាមានផលអ្វីមកដល់បច្ចុប្បន្ននេះដែរឬទេ?

**ឆ៖** អរគុណ។ ការមិនបានរៀនសូត្រនេះ គឺមានផលប៉ះពាល់ក្នុងសង្គមគ្រួសារមួយដែលតូចប៉ះពាល់ដល់សង្គមធំ អ៊ីចឹងជីវភាពក៏ខ្សត់ខ្សោយជាងគេ ចំណេះដឹងក៏អត់មាន។ នេះហើយធ្វើឱ្យប៉ះពាល់រហូតតាំងពី៧៩ រហូតដល់មកសម័យឥឡូវក៏មិនទាន់ដឹងថា នេះហើយហៅថារយៈពេលយូររហូតដល់ពេលនេះ។ ហើយខ្ញុំពេលនេះ ខ្ញុំសោកស្ដាយខ្លាំងណាស់ដែលការបាត់បង់ចំណេះដឹង ធ្វើឱ្យជីវភាពអន់ថយដល់កម្រិតសូន្យ។ អ៊ីចឹងហើយបានថា ខ្ញុំស្ដាយណាស់ដែលខ្លួនមិនបានរៀន គឺទោះបីជាយើងខំប្រឹងដល់ណាក៏ដោយ យើងខំធ្វើដល់ក៏ដោយ ក៏មិនដូចគេអ្នកមានចំណេះដឹងដែរ។ បានតែតស៊ូនឹងជីវិតកំសត់ក្រលំបាកនេះឯង ព្រោះអីយើងអត់ចំណេះដឹង។

**ស៖** បាទ អរគុណ។ ចំណុចសំខាន់មួយទៀត ដែលលោកបានលើកឡើងថា មានការប្រកាសពីការបំបែកជនជាតិចាម។ ថាតើលោកនៅចាំដែរឬទេ នរណាដែរ នរណាជាអ្នកប្រកាសនៅពេលនោះ? ហើយការបំបែកហ្នឹង គេបំបែកយ៉ាងដូចម្ដេច លោកអាចជម្រាបបានទេទៅអង្គជំនុំជម្រះ?

[០៩:៥០:៣៦]

**ឆ៖** បាទ អរគុណ។ កាលពីសម័យដែលគេប្រកាស អ៊ីចឹងខ្ញុំមិនចាំឈ្មោះទេ គ្រាន់តែខ្ញុំ ព្រោះខាងដើមមក គេនិយាយថា ប្រធានសហករណ៍ប្រកាស គេហៅយើងប្រជុំតែម្ដង គេអត់ប្រាប់ឈ្មោះអត់ប្រាប់នាមយើងទេ។ អ៊ីចឹងប្រធានសហករណ៍ គ្រាន់គេប្រាប់ថា គេប្រធានសហករណ៍ អ៊ីចឹងគេជម្លៀស គេឱ្យយើងលះបង់ចេញពីភូមិកំណើត ទ្រព្យសម្បត្តិ ផ្ទះសម្បែង សាច់ញាតិ ដីធ្លី អ្វីៗទាំងអស់ទុកតែចបជាមួយនឹងខ្លួនទេ ដែលជាកម្មសិទ្ធិមួយដែលតូច។ អ៊ីចឹងអ្វីៗ ទ្រព្យសម្បត្តិរបស់ខ្ញុំ ឪពុកម្ដាយខ្ញុំបានត្រៀមទុកសម្រាប់ឱ្យកូនចៅរបស់គាត់ គឺរបបខ្មែរក្រហមបានរឹបអូស រឹបយកអស់ហើយរហូតដល់ខ្ញុំធ្លាក់ បាត់បង់ជីវភាពរហូតដល់កម្រិតនេះ។ ទាក់ទងមកដល់សព្វថ្ងៃនេះ គេរមរកគតខ្ញុំមិនបានទទួលស្គាល់ទាល់តែសោះ ទោះបីតែអ្វីក៏ដោយ។

**ស៖** បាទ អរគុណ។ ថាតើពេលនោះ គេបានចាត់ថា ក្រុមគ្រួសាររបស់លោកហ្នឹងជាប្រជាជនអ្វីដែរ?

**ឆ៖** អរគុណ។ គេបានចាត់ទុកថា ក្រុមគ្រួសាររបស់ខ្ញុំគឺជាជនជាតិចាមម្នាក់ ហើយគឺជានាយទុនម្នាក់ បានជាគេធ្វើបាបក្រុមគ្រួសាររបស់ខ្ញុំ។ គេជម្លៀស គេពង្រត់បង្រាស ប៉ុន្តែធាតុពិត មិនមានជានាយទុនអីទេ ផ្ទះដូចតែគេ ដូចតែឯងទេ។ ក៏ប៉ុន្តែពេលនោះពួកវាឲ្យតែឃើញ របបខ្មែរក្រហមឲ្យតែឃើញយើងមានគោក្របីច្រើន ដែលគាត់ត្រៀមបម្រុងទុកសម្រាប់ខ្ញុំ កេរមរកតខ្ញុំគឺគេថានាយទុន។ អ៊ីចឹងគេឲ្យយើងលះបង់ ធ្វើម៉េចពួកនាយទុនលះបង់ទ្រព្យសម្បត្តិឲ្យអស់។

**ស៖** បាទ អរគុណ។ ថាតើគេចាត់ថា ប្រជាជនអ្វីដែលជាក្រុមគ្រួសាររបស់លោកហ្នឹងអាចជាប្រជាជនចាស់ ដូចគេ ឬមួយជាប្រជាជនប្រភេទណា?

[០៩:៥៣:៣៦]

**ឆ៖** អរគុណ។ ជនជាតិចាមនេះ របបខ្មែរក្រហមបានចាត់ទុកក្រុមគ្រួសារខ្ញុំ ក្រោម១៧ ពីព្រោះខ្ញុំក្រុមគ្រួសារខ្ញុំរស់នៅរបៀបអង្គការតាមដាន ពីព្រោះអីបានអ៊ីចឹង ពីព្រោះគេដាក់ថា គ្រួសារខ្ញុំមួយនេះ គឺជានាយទុនសក្តិភូមិ ប្រតិកិរិយា។ ខ្ញុំកាលហ្នឹងមិនដឹងថា គេថាយ៉ាងម៉េចទេ ភាសាហ្នឹង។ ខ្ញុំនៅក្មេង ឮគេថាអ៊ីចឹង ខ្ញុំកំពុងតែអរ។ ពេលនោះក្រុមគ្រួសារខ្ញុំបានគេជម្លៀសចេញពីភូមិ ទៅនៅសហករណ៍ត្រាំសេះ តែមួយគ្រួសារតែប៉ុណ្ណោះ អត់មានជនជាតិចាមណាមកនៅក្បែរ គឺអត់។

**ស៖** អ៊ីចឹងមានន័យថា អង្កាល់មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកនៅក្នុងភូមិមួយដែលសុទ្ធតែជាបងប្អូនចាមទាំងអស់ ឬមួយនៅលាយឡំដែរ?

**ឆ៖** អរគុណ។ ពេលនោះស្រុកកើតសង្គ្រាម ពួកខ្ញុំបានរត់ទៅនៅជុំគ្នាដែល ក៏ប៉ុន្តែគ្រាន់តែថាយើងគេចពីគ្រាប់នៅនឹងនោះ ជុំគ្នាទាំងអស់ មានសាសនា មានប្រពៃណី មានវប្បធម៌ត្រឹមត្រូវ។

**ស៖** បាទ អរគុណ។ មានន័យថា ក្រោយពីថ្ងៃ១៧ មេសា ប្រជាជនដែលនៅភូមិរបស់លោកហ្នឹង គេឲ្យចេញពីភូមិហ្នឹងទាំងអស់ ឬមួយយ៉ាងណាដែរ ដែលជាប្រជាជនចាមហ្នឹង?

**ឆ៖** អរគុណ។ ក្រោយថ្ងៃ១៧ មេសា មករួច ប្រជាជនសាច់ញាតិបងប្អូនខ្ញុំដែលនៅក្នុងភូមិ គឺលះបង់ទាល់តែអស់ អត់មានអ្នកណាម្នាក់ហើយនៅក្នុងភូមិកំណើតរបស់ខ្លួនទេ ព្រោះអីពេលនោះអង្គការកំណត់ឲ្យជនជាតិចាម ចាកចេញពីភូមិមួយទៅភូមិមួយ ហើយឲ្យជនជាតិចាមលះបង់ ជាស្ត្រីគឺកាត់សក់ឲ្យខ្លី ធ្វើម៉េចគឺឲ្យបានដូចជាជនជាតិខ្មែរ។ ហើយជនជាតិចាមធ្វើម៉េច បើខ្មែរហូបអីបាន ជនជាតិចាមហូបហ្នឹងឲ្យបាន។ បើថាហូបមិនបានទេ អ្នកហ្នឹងអត់លះបង់ជូនអង្គការបក្សទេ។ ហើយបើអ្នកមិនលះបង់ទ្រព្យសម្បត្តិទេ អ្នកនោះមិនចេញពីភូមិទេ អ្នកនោះក្បត់នឹងអង្គការ អង្គការត្រូវយកទៅ

សម្លាប់។

[០៩:៥៦:៥៤]

**ស៖** បាទ អរគុណ។ អម្បាញ់មិញខ្ញុំចង់សួរសំណួរបញ្ជាក់បន្តិចថា តើពេលដែលគេបញ្ជូនប្រជាជនចាមដែលនៅក្នុងភូមិរបស់លោកហ្នឹង បានន័យថា គេឱ្យទៅនៅបែកៗគ្នាទាំងអស់ ឬមួយទៅនៅមួយភូមិសុទ្ធតែប្រជាជនចាមដែរ ឬមួយយ៉ាងណា?

**ឆ៖** អរគុណ។ ការជម្លៀសនេះ មិនមែនគេឱ្យទៅនៅម្ដុំទេ ដូចជាគ្រួសារខ្ញុំទៅនៅភូមិត្រាំសេះម្នាក់អ៊ីចឹងទៅ អ្នកនោះទៅនៅគ្រួសារនោះ មួយសហករណ៍ម្នាក់អ៊ីចឹងទៅ មួយភូមិម្នាក់ មួយភូមិមួយគ្រួសារ មួយភូមិមួយគ្រួសារ។ ហើយពេលនោះក៏គេមិនឱ្យនៅគ្រួសារតែមួយគ្រួសារដែរ គឺគេបែងចែកមុខសញ្ញាឱ្យយើងធ្វើ ពលកម្មរៀងៗខ្លួន។ បើអ្នកនោះកងចល័ត គឺគេត្រូវទៅកងចល័ត បើឪពុកនោះចាស់ជរា គេត្រូវធ្វើការតាមកន្លែងៗ។ ពេលនោះគឺមានតែគ្រួសារទេទៅនៅសហករណ៍ ក៏ប៉ុន្តែនៅក្នុងសហករណ៍រួច គឺត្រូវតែចេញ បែងចែកគ្នារហូត អត់មានអ្នកណានៅជុំគ្នាម្នាក់ទេ។

**ស៖** បាទ អរគុណ។ សំណួរខ្ញុំចុងក្រោយ គឺខ្ញុំចង់ដឹងថា តើអ្វីខ្លះដែលលោក ឥឡូវហ្នឹងលោកបានទទួល នៅតែទទួលការឈឺចាប់មកដល់បច្ចុប្បន្ននេះ ហើយពាក់ព័ន្ធទៅនឹងរឿងអ្វីខ្លះ?

**ឆ៖** អរគុណ។ ទី១ ដែលប៉ះពាល់មកដល់បច្ចុប្បន្នរាល់ថ្ងៃនេះ ទី១ ការងារចំណេះដឹង។ ទី២ គឺមរតក ទ្រព្យសម្បត្តិដែលឪពុកម្ដាយខំសន្សំទុកសម្រាប់កូនចៅជំនាន់ក្រោយ។ អ៊ីចឹងខ្មែរក្រហមឱ្យលះបង់ឱ្យអស់។ ហើយចំណេះដឹងនេះ ហើយគឺជាកត្តាមួយដែលសំខាន់សម្រាប់មនុស្សគ្រប់រូប។ តែរីឯខ្ញុំវិញ អត់មានចំណេះដឹងទាល់តែសោះ នេះហើយធ្វើឱ្យខ្ញុំមានការបារម្ភរហូតមកដល់បច្ចុប្បន្ន សព្វថ្ងៃនេះ។

[០៩:៥៩:៥១]

**ស៖** បាទ ចុះពាក់ព័ន្ធទៅនឹងផ្នែកផ្លូវចិត្តរបស់លោក នៅតែអន្ទោលតាមប្រាណមកដល់បច្ចុប្បន្នហ្នឹង យ៉ាងដូចម្ដេចដែរ?

**ឆ៖** អរគុណ។ ដែលជាស្រមោលនៅអន្ទោលតាមប្រាណខ្ញុំរាល់ថ្ងៃនេះ កត្តាទី១ គឺជាចំណេះដឹងដែលខ្ញុំស្ដាយបំផុត រហូតមកដល់ហួសវ័យ។ កត្តាទី២ ដែលពួករបបខ្មែរក្រហមបានយកខ្ញុំទៅដាក់មន្ទីរឃុំឃាំង ហើយយកមនុស្សមកសម្លាប់ជាក់ៗស្ដែង ផ្ទាល់ៗ ធ្វើឱ្យខ្ញុំបិទភ្នែកក៏ឃើញអតីតកាល បើកភ្នែកក៏ឃើញអតីតកាល។ អ៊ីចឹងហេតុដូច្នេះហើយបានខ្ញុំនៅតែបារម្ភ នៅតែភ័យ នៅតែខ្លាច។

**សៈ** បាទ អរគុណ។ តើលោកបច្ចុប្បន្ន នៅចេះភាសាចាមដែរអត់ទេ?

**ឆៈ** អរគុណ។ ខ្ញុំភាសាចាម បើនិយាយសាមញ្ញធម្មតា ចេះតិចជាងភាសាខ្មែរ។

**លោក ឡោ ជុនធី៖**

បាទ លោកប្រធាន ខ្ញុំបាទអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតទៅនេះអង្គជំនុំជម្រះ ផ្ដល់វេទិកាជូនទៅភាគីដទៃទៀត ពាក់ព័ន្ធនឹងរឿងក្ដី។ ដំបូងនេះផ្ដល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរសំណួរពាក់ព័ន្ធជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន។ សូមអញ្ជើញ!

[១០:០២:២៨]

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ ដែលមានវត្តមានក្នុងសវនាការនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**សៈ** សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំបាទឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ខ្ញុំបាទមានសំណួរមួយចំនួនដែលចង់ជម្រាបសួរទៅលោក ពាក់ព័ន្ធទៅនឹងការសម្លាប់នានា ទៅនឹងកិច្ចការដែលលោកបានដឹង បានឮ នៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ តាមដែលលោកបានជម្រាបជូនអង្គសវនាការ តាមរយៈសំណួររបស់មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី លោកថា លោកធ្លាប់ត្រូវបានជម្លៀសទៅកាន់សហករណ៍ត្រាំសេះ តើនៅពេលដែលលោកត្រូវបានជម្លៀសទៅសហករណ៍ត្រាំសេះហ្នឹង នៅក្នុងឆ្នាំណាដែរ?

**លោក ម៉ី ពៅ៖**

**ឆៈ** អរគុណ។ កាលពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំបានគេជម្លៀសចេញពីភូមិ ស្រុកនៅឆ្នាំ១៩៧៥ ទៅនៅសហករណ៍ត្រាំសេះ។

**សៈ** តើលោកនៅទីនោះ អស់រយៈពេលប៉ុន្មាន ឬទើបៗត្រូវបានផ្លាស់ទៅកន្លែងផ្សេងទៀត ឬក៏លោកនៅទីនោះរហូត ចាប់តាំងពីឆ្នាំ១៩៧៥ រហូតដល់ចប់ ដល់ឆ្នាំ១៩៧៩?

**ឆ៖** អរគុណ។ ឆ្នាំ១៩៧៥ ចុងឆ្នាំ១៩៧៥ គេជម្លៀសគ្រួសារខ្ញុំ ទៅនៅសហករណ៍មេទឹក។

[១០:០៤:៣២]

**ស៖** ចុះសហករណ៍ត្រាំសេះហ្នឹង ស្ថិតនៅក្នុងភូមិអី ឃុំអី ស្រុកអី និងខេត្តអីដែរ?

**ឆ៖** សហករណ៍ត្រាំសេះ ខ្ញុំទទួលស្គាល់ថា បើនិយាយឃុំដើម ខ្ញុំចង់និយាយថា សហករណ៍ត្រាំសេះ ឃុំខ្នារពីដើម តែប៉ុល ពត ខ្ញុំមិនដឹង សម័យខ្មែរក្រហម ខ្ញុំមិនដឹងទេ គ្រាន់តែថាសហករណ៍ត្រាំសេះ ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** ដូចគ្នានេះដែរ លោកបានជម្រាបទៅអង្គសវនាការថា លោកធ្លាប់បានឃើញការសម្លាប់មនុស្សដោយផ្ទាល់ភ្នែកច្រើនលើក តាមរយៈការធ្វើមីទ្ទីងរបស់ខ្មែរក្រហម ដើម្បីជាការគំរាមកំហែងដល់ផ្លូវចិត្តដល់អ្នកដែល -- ដើម្បីបង្ហាញថាអ្នកដែលប្រព្រឹត្តខុសនឹងទទួលបានទណ្ឌកម្មបែបនេះ។ ចង់ជម្រាបសួរលោកថា នៅពេលក្រៅពីៗការដែលបង្ហាញឲ្យមើលឃើញផ្ទាល់ភ្នែកអ៊ីចឹង តើលោកធ្លាប់ឃើញការសម្លាប់មនុស្សបែប -- ការសម្លាប់មនុស្សដោយពុំមានការបង្ហាញអ៊ីចឹងទេ?

**ឆ៖** អរគុណ។ ពេលនោះគ្រាន់តែឃើញជាសាកសព ខ្ញុំធ្លាប់បានឃើញ តែមិនដឹងអ្នកណាសម្លាប់ ឬមួយកំហុសទោសអ្វី ខ្ញុំមិនបានដឹង។

**ស៖** ចុះចំពោះក្នុងអំឡុងពេលដែលលោកនៅ ស្ថិតនៅក្នុងសហករណ៍ត្រាំសេះ តើលោកធ្លាប់បានឃើញការសម្លាប់មនុស្សដែរឬទេ?

**ឆ៖** នៅក្នុងសហករណ៍ត្រាំសេះ ខ្ញុំគ្រាន់តែដឹងថាជនជាតិចាមនៅស្រុកភ្នំពេញនេះក៏មិនដឹងដឹងអីទេ គេជម្លៀសទៅក្នុងនៅសហករណ៍ត្រាំសេះ តែគេយកគាត់ទៅសម្លាប់មួយគ្រួសារទាំងអស់។

**ស៖** តើលោកឃើញការសម្លាប់ហ្នឹងនៅកន្លែងណាដែរ?

[១០:០៧:២៥]

**ឆ៖** ខ្ញុំអត់បានឃើញគេសម្លាប់ផ្ទាល់ទេ តែពេលនោះ ខ្ញុំទៅធ្វើការឃើញសាកសពគាត់នៅក្នុងវាលស្រែ។

**ស៖** តាមរយៈឯកសារលេខ E319/13.3.41 ត្រង់សំណួរចាប់ពីសំណួរទី២៤ រហូតដល់សំណួរទី៣០ ជាពិសេសត្រង់សំណួរទី -- ដល់សំណួរទី៣០ លោកបាននៅ -- លោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា គេសួរថា៖ “សំណួរទី២៤ នៅក្នុងឆ្នាំ១៩៧៥ តើមានក្រុមប្រជាជន ឬក្រុមនុស្សណាដែលត្រូវខ្មែរក្រហមកំណត់ទិសដៅដើម្បីធ្វើបាប

ដែរឬទេ? ឆ្លើយ៖ មានមូស្លីមត្រូវបានជម្លៀសពីភ្នំពេញ ប្រហែលជាមកពីគីឡូម៉ែត្រលេខ៩ បានមកដល់ទីនេះ ហើយត្រូវបានចោទប្រកាន់ថាក្បត់អង្គការ និងត្រូវបានយកទៅសម្លាប់។ សំណួរទី២៥៖ តើព្រឹត្តិការណ៍នេះកើតឡើងនៅសហករណ៍ត្រាំសេះ នៅឆ្នាំ៧៥ មែនទេ? ឆ្លើយ៖ បាទ។ ដល់សំណួរទី២៨សួរថា៖ តើលោកបានឃើញអ្វីខ្លះនៅពេលនោះ? លោកបានឆ្លើយថា៖ ខ្ញុំបានឃើញខ្មែរក្រហមវ៉ៃសម្លាប់មនុស្ស ប៉ុន្តែខ្ញុំពុំបានមើលយូរទេ គឺគេចចេញពីកន្លែងនោះតែម្ដង។”

អ៊ីចឹងតាមៗរយៈចម្លើយរបស់លោកនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយនេះ ច្បាស់ណាស់ថាលោកបានឃើញ។ អ៊ីចឹង ហើយអម្បាញ់មិញលោកបានថាអត់បានឃើញវិញ។ អ៊ីចឹងលោកជួយបញ្ជាក់បន្តិចមើល តើនៅពេលនោះលោកបានឃើញ ឬមិនបានឃើញ? ហើយតើចម្លើយមួយណា ដែលលោករក្សា ដែលលោកគិតថាជាចម្លើយ ដែលលោកប្រកាន់ថាត្រឹមត្រូវ?

[១០:០៩:៥៩]

**ឆ៖** បាទអរគុណ។ ខ្ញុំសូមបញ្ជាក់ថា រឿងគ្រួសារមូស្លីមដែលនៅគីឡូលេខ៦ គ្រួសារមួយនោះគឺគេយកទៅសម្លាប់ ខ្ញុំមិនបានឃើញទេ។ តែគ្រួសារផ្សេងទៀត ក្រៅពីហ្នឹងខ្ញុំបានឃើញ តែមិនដឹងជាមួយណាអ្នកសម្លាប់ទេ ពីព្រោះអីពេលនោះខ្ញុំគ្រាន់តែបានមួយឃើញ រួចខ្ញុំរត់ចេញ ព្រោះអីខ្លាចពួកឈ្លបរបស់ខ្មែរក្រហមតាមដានខ្ញុំ ហើយយកខ្ញុំទៅសម្លាប់។

**ស៖** អ៊ីចឹងត្រង់នេះបញ្ជាក់ថា លោកបានឃើញហេតុការណ៍នៃការសម្លាប់មនុស្សទៅលើគ្រួសារមូស្លីមហ្នឹងពីរដងផ្សេងគ្នា។ ទី១ ទៅលើគ្រួសារដែលប្រហែលជាមកពីគីឡូម៉ែត្រលេខ៩ មួយគ្រួសារ និងមួយទៀត លោកគ្រាន់តែបានឃើញសកម្មភាពហ្នឹងបន្តិច ហើយលោកចាកចេញទៅ។ តើអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីជាតិការពារក្ដីលោក នួន ជា!

**លោក លីវ សុវណ្ណា៖**

ខ្ញុំបានសូមជំទាស់នឹងសំណួររបស់សហព្រះរាជអាជ្ញារងជាតិ ពីព្រោះអម្បាញ់មិញដើមបណ្ដឹងរដ្ឋប្បវេណី គាត់បញ្ជាក់ហើយថា គ្រួសារដែលជម្លៀសពីគីឡូម៉ែត្រលេខ៦ គាត់អត់បានឃើញការសម្លាប់ទេ។ គាត់ឃើញគ្រួសារផ្សេងទៀត។ អ៊ីចឹងសំណួររបស់សហព្រះរាជអាជ្ញារងថា គាត់បានឃើញពីរគ្រួសារ។ អ៊ីចឹងខ្ញុំបាទ សូមជំទាស់នឹងសំណួរនេះបាទ។

[១០:១១:៤៤]

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ខ្ញុំសូមរៀបចំសំណួរខ្ញុំឡើងវិញ ត្រង់នេះ។ អ៊ីចឹងខ្ញុំសួរលោកឡើងវិញ សូមលោកជួយបញ្ជាក់បន្តិចមើល បើតាមអ្វីដែលលោកបានឆ្លើយជម្រាបជូនអង្គជំនុំជម្រះថា លោកបានឃើញការសម្លាប់ក្រុមមូស្លីមមួយក្រុម និង ឃើញសាកសពជនមូស្លីមមកពី ប្រហែលជាមកពីគីឡូម៉ែត្រលេខ៦ មួយគ្រួសារ។ តើអ៊ីចឹងមែនទេ?

**លោក ម៉ី ពៅ៖**

**ឆ៖** អរគុណ។ ខ្ញុំថា មូស្លីមមួយគ្រួសារដែលនៅសហករណ៍ត្រាំសេះ ឆ្នាំ១៩៧៥ ដែលមកគេជម្លៀសមកជាមួយខ្ញុំ មកជាមួយជុំគ្នា មកជាមួយភូមិខ្ញុំពីរនាក់ អ៊ំ! ពីរគ្រួសារនេះ។ គ្រួសារទី១ គឺគេយកគាត់ទៅសម្លាប់។ ទី២ ខ្ញុំបានឃើញជនមូស្លីមមួយក្រុមទៀត ពួករបបខ្មែរក្រហមកំពុងតែសម្លាប់។ ពេលនោះខ្ញុំមិនបានមើលច្បាស់ទេ តែគ្រាន់តែខ្ញុំចេះដឹងជាឯកសណ្ឋានមានឃើញសារុង ឃើញអី ខ្ញុំគេចទៅ។ ខ្ញុំមិនហ៊ាននៅក្បែរទៀត ខ្លាចលោណ្ណបរបស់របបខ្មែរក្រហមឃើញខ្ញុំ និងសម្លាប់ខ្ញុំ។

**ស៖** ពាក់ព័ន្ធនឹងចំណុចនេះ ចំពោះ សូមលោករៀបរាប់តែអ្វីដែលលោកបានឃើញគឺ តើលោកឃើញនៅកន្លែងណា?

**ឆ៖** អរគុណ។ ចំណុចដែលខ្ញុំឃើញកន្លែងហ្នឹងគេហៅទួលស្ដែង។ ចំណុចមួយទៀតនៅនឹងវាលស្រែក្បែរនោះដែរ។

[១០:១៣:៤៨]

**ស៖** ខ្ញុំចង់បញ្ជាក់ជម្រាបលោក ក្នុងលក្ខខណ្ឌមួយច្បាស់លាស់ថា មួយលោកបានឃើញ គ្រាន់តែឃើញសាកសព។ មួយទៀតលោកបានឃើញសកម្មភាពនៃការវ៉ៃសម្លាប់។ អ៊ីចឹងអ្វីដែលខ្ញុំចាប់ផ្ដើមសួរលោកនៅពេលនេះ គឺសួរតែអំពីអ្វីដែលលោកបានឃើញសកម្មភាពនៃការវ៉ៃសម្លាប់។ អ៊ីចឹងសូមលោកជួយជម្រាបអង្គជំនុំជម្រះថា តើការ ព្រឹត្តិការណ៍នេះកើតឡើងនៅកន្លែងណា? ព្រឹត្តិការណ៍ដែលលោកបានឃើញហ្នឹង តើកើតឡើងនៅកន្លែងណា?

**ឆ៖** អរគុណ។ ខ្ញុំដែលខ្ញុំបានឃើញនេះ ថាខ្ញុំបានឃើញដោយចៃដន្យទៅចុះ នៅទួលស្ដែង។ ហើយខ្ញុំឃើញពេលនោះ ក៏ខ្ញុំមិនហ៊ានមើលយូរដែរ ព្រោះអីការមើលយូរខ្ញុំខ្លាចលោពួកឈ្លបខ្មែរក្រហមឃើញខ្ញុំ និង ចោទប្រកាន់ខ្ញុំថា ខ្ញុំក្បត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងជាតិ។ បាទឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការតុលាការ ទៅណាបាត់ហើយ? សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:២១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** មុនពេលឈប់សម្រាក លោកបានជម្រាបអង្គជំនុំជម្រះថា កន្លែងកើតហេតុនោះគឺនៅទួលស្លែង។ តើទួលស្លែង ស្ថិតនៅក្នុងភូមិណា ឃុំណាដែរ?

**លោក ម៉ី ពៅ៖**

**ឆ៖** បាទ អរគុណ។ គឺទួលស្លែងនៅឃុំខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** ចំពោះហេតុការណ៍នេះដែរ តើតាមអ្វីដែលលោកឃើញហ្នឹង តើហេតុការណ៍ហ្នឹងបានកើតឡើងនៅៗក្នុងអគារ ផ្ទះ ឬក៏នៅទីវាល?

**ឆ៖** អរគុណ គឺនៅក្នុងព្រៃ។

[១០:៣៣:៤៦]

**ស៖** ហើយហេតុការណ៍ហ្នឹងកើតឡើងនៅពេលណាដែរ ថ្មើរណាដែរ មានន័យថា ពេលថ្ងៃ ឬក៏ពេលយប់?

**ឆ៖** អរគុណ។ ប្រហែលជាម៉ោងបីរសៀល។

**ស៖** ចុះចម្ងាយពីកន្លែងដែលលោកស្ថិតនៅ ហើយនិងកន្លែងកើតហេតុហ្នឹង មានចម្ងាយប្រហែលប៉ុន្មានពីគ្នាដែរ?

**ឆ៖** អរគុណ។ ប្រហែល ចម្ងាយប្រហែលជា៥០ម៉ែត្រ។

**ស៖** នៅពេលនោះលោកបានមើលឃើញច្បាស់ដែរ ៥០ម៉ែត្រ? ហើយលោកឃើញអ្វីដែរ?

**ឆ៖** ពេលនេះ ខ្ញុំមិនមើលពុំច្បាស់ទេ ព្រោះអីពេលនោះ គេកំពុងតែវាយចោល ហើយខ្ញុំគ្រាន់តែក្រឡេកឃើញ គឺខ្ញុំដើរចេញ។

**ស៖** សូមលោកជួយរៀបរាប់អំពីព្រឹត្តិការណ៍ហ្នឹងបន្តិច។ តើលោកបានឃើញអ្វីខ្លះក្នុងៗខណៈដែលលោកបានឃើញហ្នឹង? រយៈពេលខ្លីហ្នឹង តើលោកឃើញអីខ្លះ សកម្មភាពនោះ មានអ្វីខ្លះ?

**ឆ៖** អរគុណ។ ពេលនោះខ្ញុំមិនដឹងច្បាស់ទេ ពីព្រោះអីពេលនោះវាព្រៃផងអីផង ហើយឆ្ងាយក៏ឆ្ងាយដែរ អ៊ីចឹងខ្ញុំមើលពុំបានច្បាស់ទេ មិនដឹងជាមានស្អីខ្លះដែលឈ្លបកំពុងតែវាយប្រហារមនុស្សនោះ។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា លោកថា វាយប្រហារហ្នឹងវាយយ៉ាងម៉េច? អ្វីខ្លះដែលលោកបានឃើញនៅពេលនោះ?

[១០:៣៦:០៧]

**ឆ៖** អរគុណ។ ពេលនោះខ្ញុំឃើញវាយនឹងព្រនង់ តែមិនដឹងជាព្រនង់ហ្នឹងដើមឈើ ឬមួយគល់ឫស្សី ខ្ញុំមិនបានដឹង។

**ស៖** ចុះក្រុមៗអ្នកប្រព្រឹត្តហ្នឹងជាអ្នកណាដែរ?

**ឆ៖** អរគុណ។ ខ្ញុំមិនបានដឹងច្បាស់ថាជាក្រុមអ្នកណា គ្រាន់តែខ្ញុំដឹងថា ជាឈ្លបរបស់របបខ្មែរក្រហម។

**ស៖** នៅពេលហ្នឹងលោកឃើញឈ្លបហ្នឹង មានគ្នាប៉ុន្មាននាក់?

**ឆ៖** អរគុណ។ ខ្ញុំបានឃើញពីចម្ងាយ ខ្ញុំនឹងធ្វើការសន្និដ្ឋានថា ប៉ុន្មាននាក់បានឡើយ។

**ស៖** ចុះក្រៅពីសកម្មភាពនេះ លោកបានឮសូរសំឡេងអីទេ ចេញពីកន្លែងកើតហេតុហ្នឹង?

**ឆ៖** អរគុណ។ ពេលនោះខ្ញុំក៏មិនបានឈរមើលយូរដែរ ខ្ញុំអត់បានឮសម្រែក សំឡេងសម្រែកអីទេ ព្រោះអីខ្ញុំដើរចេញបាត់ទៅហើយ។

**ស៖** ចុះជនរងគ្រោះនៅពេលនោះ លោកឃើញមានជន ចំនួនប៉ុន្មាននាក់ដែរ?

**ឆ៖** អរគុណ។ ពេលនោះខ្ញុំមិនបានដឹងជាចំនួននាក់ទេ ព្រោះអីខ្ញុំអត់ហ៊ានទៅក្បែរហ្នឹងផង។ ខ្ញុំមិនបានដឹងច្បាស់។

**ស៖** លោកអត់ដឹងចំនួនជាក់លាក់ ប៉ុន្តែលោកអាចប្រមាណបានទេថា ប្រហែលប្រមាណមួយក្រុមហ្នឹង ប្រមាណពីរបីនាក់ ឬក៏បួននាក់ តាមៗដែលលោកឃើញជាក់ស្តែងនៅពេលហ្នឹង?

**ឆ៖** អរគុណ។ ពេលនោះពេលដែលខ្ញុំឃើញប្រហែលជាចាប់ពីប្រាំនាក់ឡើងទៅ។

[១០:៣៨:៥១]

**ស៖** លោកបានបញ្ជាក់ពីខាងដើមថា ជនមូស្លីមមួយក្រុម តើលោកម៉េចបានសម្គាល់ថា ពួកគាត់ហ្នឹងជាជនមូស្លីម?

**ឆ៖** អរគុណ។ ខ្ញុំឃើញសម្លៀកបំពាក់របស់គាត់ដែលនៅកន្លែងនោះ។

**ស៖** សូមលោកបញ្ជាក់កន្លែងនេះឲ្យច្បាស់បន្តិច គឺខ្ញុំសួរៗចំពោះហេតុការណ៍ដែលលោកឃើញអ៊ីចឹងពេលលោកមើលឃើញហ្នឹង គឺឃើញសម្លៀកបំពាក់ដែលគាត់ស្លៀកពាក់ ឬៗក៏យ៉ាងណា?

**ឆ៖** អរគុណ។ ពេលនោះខ្ញុំមិនបានៗឃើញគាត់ស្លៀកពាក់ទេ ពីព្រោះអីពេលនោះគេយកបង្ខិចគាត់ដាក់នៅរាយប៉ាយពេញហ្នឹង អ៊ីចឹងឃើញកាតឹបស ឃើញក្រមា ឃើញកន្សែងអី បានជាខ្ញុំថាជាមូស្លីម។

**ស៖** ដោយឡែកហេតុការណ៍មួយទៀត គឺពាក់ព័ន្ធនឹងហេតុការណ៍ដែលលោកបានឃើញសាកសពប្រជាជនមួយគ្រួសារ ដែលលោកបានបញ្ជាក់ពីខាងដើមថា ប្រហែលជាមកពីគីឡូម៉ែត្រលេខ៦។ តើលោកឃើញសាកសពប៉ុន្មាននាក់?

**ឆ៖** អរគុណ។ ពេលនោះសាកសពគ្រួសារនោះ ប្រហែលជាបួនប្រាំនាក់ដែរ ហើយខ្ញុំក៏មិនដឹងច្បាស់ត្រង់ចំណុចមួយថា ប៉ុន្មាននាក់លើហ្នឹងទៅទៀត ខ្ញុំមិនបានដឹង។ តែខ្ញុំគ្រាន់តែឮកុមារដូចគ្នាប្រាប់ខ្ញុំថា ជនជាតិនៅផ្ទះក្បែរបងឯងហ្នឹងហើយ គេយកមកសម្លាប់។

[១០:៤១:២០]

**ស៖** សូមលោកជួយរៀបរាប់អំពីហេតុការណ៍ដែលលោកបានឃើញនៅពេលនុ៎ង ហេតុការណ៍

ដែលលោកឃើញសាកសពហ្នឹង តើសាកសពហ្នឹងយ៉ាងម៉េច បានលោកឃើញ? គេមិនមានរៀបចំកប់ស្រួលបួល ឬយ៉ាងក៏ម៉េច ក៏បានលោកទៅសម្គាល់ឃើញថាជាសាកសពជនជាតិម៉ូស្លីមបាទ?

**ឆ៖** បាទអរគុណ។ ពីព្រោះសម័យហ្នឹងការសម្លាប់មនុស្ស ដែលរបៀបរបបហ្នឹងចោទថាក្បត់ គឺគេអត់កប់ទេ គឺគេវែកណ្តាលវាលស្រែ ឬមួយកណ្តាលព្រៃ ដាក់ចោលធម្មតា។

**ស៖** ចុះសាកសពដែលលោកឃើញហ្នឹង ឃើញនៅកន្លែងណា?

**ឆ៖** អរគុណ។ ខ្ញុំឃើញនៅក្បែរទួលស្តែងហ្នឹងដែរ ពីព្រោះអីទួលស្តែងហ្នឹងហើយ ជាកន្លែងដែលគេយកមនុស្សទៅវាយប្រហារ។

**ស៖** ចុះចំពោះទីតាំងវិញ លោកឃើញនៅវាលស្រែ ក្នុងព្រៃ ឬក៏ក្នុងអគារណាមួយ?

**ឆ៖** ទីតាំងទួលស្តែងហ្នឹងមានស្រែក្បែរហ្នឹងដែរ តែដែលសាកសពដែលគេយកទៅវាយប្រហារគ្រួសារហ្នឹង គេយកទៅវែនៅនឹងវាលស្រែ។

**ស៖** ខ្ញុំសូមឆ្លងចូលមកប្រធានបទមួយទៀត គឺពាក់ព័ន្ធនឹងហេតុការណ៍ដែលលោកបានដឹងឮហ្នឹងដែរ។ តើនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកដឹងថាមានអ្វីកើតឡើងចំពោះមេដឹកនាំសាសនាអ៊ីស្លាម ក៏ដូចជាអ្នកដែលមានចេះចំណេះដឹងខ្ពង់ខ្ពស់ក្នុងសាសនាអ៊ីស្លាម?

[១០:៤៣:៥០]

**ឆ៖** អរគុណ។ អ្នកដែលមានចំណេះដឹងខ្ពស់ខ្ពស់នៅក្នុងសាសនាអ៊ីស្លាម គឺរបបខ្មែរក្រហម គឺគេយកទៅសម្លាប់ ក៏ប៉ុន្តែមិនដឹងយកទៅសម្លាប់កន្លែងណា ឬមួយយកទៅដាក់ទោសទណ្ឌត្រង់ណា គឺខ្ញុំមិនបានដឹង។ តែបើសិនជាគេស៊ើបដឹងថា អ្នកណាហើយចេះដឹងខាងផ្នែកកាន់សាសនាអ៊ីស្លាម គឺត្រូវតែគេយកទៅសម្លាប់។ បាទ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើលោកមាន អាចមានដឹងបុគ្គលជាក់លាក់ណាមួយដែលគាត់ជាអ្នកចេះដឹងខាងសាសនាអ៊ីស្លាម ហើយលោកបានដឹងថា គាត់ត្រូវបានគេយកទៅសម្លាប់?

**ឆ៖** បាទ អរគុណ។ ដែលខ្ញុំនិយាយពីរឿងគ្រួសារអម្បាញ់មិញ ខ្ញុំសូមនិយាយត្រឡប់ក្រោយបន្តិច។ គ្រួសារហ្នឹង ដែលគេយកគាត់ទៅសម្លាប់ទាំងគ្រួសារហ្នឹង ដែលនៅក្បែរខ្ញុំហ្នឹង ពីព្រោះអីគ្រួសារមួយដែលចេះដឹងពីរឿងវប្បធម៌របស់សាសនាអ៊ីស្លាម ទើបពេលនោះហើយ បានគេយកគាត់ទៅសម្លាប់។

**ស៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហ្វូន!

**សួរដោយលោក ស្រ៊ា រតនះ៖**

**ស៖** នៅក្នុងឯកសារដដែល គឺឯកសារលេខ E319/13.3.41 ត្រង់សំណួរ ចាប់ពីសំណួរទី៣៦ រហូតដល់សំណួរទី៣៩។ កាលនោះអ្នកស៊ើបអង្កេតសួរលោកថា៖ "ចុះចំពោះក្រុមអ្នកជឿសាសនាអ៊ីស្លាមនៅក្នុងរបបខ្មែរក្រហម តើមានអ៊ីម៉ាប់ដែរឬទេ? លោកឆ្លើយថា៖ ពេលនោះខ្មែរក្រហមបានលុបបំបាត់ចោលអស់ហើយ បើអ្នកណាដែលមានចំណេះដឹងខាងអ៊ីម៉ាប់ និងតួន គឺនឹងត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលទាំងអស់។ អ៊ីម៉ាប់ មានន័យថាជាអ្នកចេះដឹង និងដឹកនាំ។ ចំណែកតួន គឺជាគ្រូបង្រៀនខាងសាសនា។ សំណួរទី៣៧៖ តើលោកធ្លាប់ឃើញខ្មែរក្រហមចាប់ខ្លួនអ៊ីម៉ាប់ ឬក៏តួនដែរឬទេ? ចម្លើយ៖--"

[១០:៤៦:២៨]

**លោក គង់ សំអុន៖**

ខ្ញុំសូមអធ្យាស្រ័យ។ សូមកាត់ដោយសារក្នុងឯកសារនេះ សរសេរថា "អ៊ីមុាំ" មិនមែនអ៊ីម៉ាប់ទេ។ អ៊ីចឹងក្រែងមានការភ័ន្តច្រឡំ។ បាទ សូមអធ្យាស្រ័យ។

**លោក ស្រ៊ា រតនះ៖**

បាទ សូមអរគុណ។ ខ្ញុំអត់ដឹងថាភាសាត្រឹមត្រូវហ្នឹងអានថាម៉េចទេ ចាំៗលោកកែតម្រូវខ្ញុំបន្ថែមទៀត ប៉ុន្តែខ្ញុំសូមអានថា "អ៊ីមុាំ" តាមលោកមេធាវីអ៊ីចឹង ព្រោះអានខ្មែរឃើញអ៊ីមុាំ។

**សួរដោយលោក ស្រ៊ា រតនះ៖**

**ស៖** លោកបានឆ្លើយថា៖ "ខ្ញុំពុំឃើញដោយផ្ទាល់ភ្នែកទេ ប៉ុន្តែសាច់ញាតិរបស់ខ្ញុំដែលជាអ្នកចេះដឹងខាងសាសនាអ៊ីស្លាម គឺស្លាប់អស់ហើយក្នុងរបបខ្មែរក្រហម។ សំណួរសួរទៀតថា បន្តទៀត៖ តើសាច់ញាតិរបស់លោកស្លាប់នៅឯណា? ខ្ញុំដឹងរឿងនេះក្រោយរបបខ្មែរក្រហម គឺយកទៅសម្លាប់នៅដំរីស។ សំណួរ៖ តើដំរីសស្ថិតនៅឯណា? ដំរីសនៅស្រុកកណ្តៀង។" អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា ត្រង់ដែលលោកថា សាច់ញាតិរបស់ខ្ញុំ ដែលអ្នកចេះដឹងខាងសាសនាអ៊ីស្លាមហ្នឹង គឺស្លាប់អស់ហើយហ្នឹង បានន័យថា ពួកគាត់ជាតួន ឬក៏អ៊ីមុាំហ្នឹងមែនទេបាទ?

[១០:៤៨:០០]

**លោក ម៉ើ ពៅ៖**

**ឆ៖** អរគុណ។ ខាងសាសនាអ៊ីស្លាមគឺអ៊ីម៉ាំ គឺអ្នកដឹកនាំគាំពារសាសនា ពេលថ្វាយបង្គំព្រះ គាត់ឈរពីមុខគេ។ ពេលថាតួន ជាគ្រូបង្រៀន។ ពេលនោះពួកគាត់បានឃើញជម្លៀសចេញ ដែលដឹង ដំណឹងចុងក្រោយនៅដំរីស។ អ៊ីចឹងគេយកគាត់សម្លាប់អស់ហើយ។ ខ្ញុំពុំបានឃើញច្បាស់ទេ ប៉ុន្តែខ្ញុំដឹង ពេលវេលាចុងក្រោយ។

**ស៖** អ៊ីចឹងបានន័យថា ពីមុននោះលោករៀបរាប់ៗជូនអង្គសវនាការដែរថា លោកមានបាត់បង់ បងប្អូនសាច់ញាតិទាំងនោះ ១៧នាក់។ អ៊ីចឹងបងប្អូនដែលជាតួន និង អ៊ីម៉ាំហ្នឹងស្ថិតនៅក្នុងចំណោម១៧ នាក់ហ្នឹងដែរ ឬក៏អ្នកផ្សេងទៀតបាទ?

**ឆ៖** បាទ អរគុណ។ សាច់ញាតិដែលខ្ញុំថា បាត់បង់បងប្អូនសាច់ញាតិ១៧នាក់ គឺជាប់នៅក្នុង អ្នកដឹកនាំគឺជាអ៊ីម៉ាំ តួន ទាំងអស់ហ្នឹងឯង។

**ស៖** យើងខ្ញុំសូមបន្តនូវវិធានបទមួយទៀត គឺពាក់ព័ន្ធនឹងអតីតទាហាន លន់ នល់ តើលោកបាន ដឹងអំពីហេតុការណ៍ដែលកើតឡើងចំពោះទាហាន លន់ នល់ ដែរឬទេ ក្នុងសម័យ ក្នុងរបបកម្ពុជាប្រជា ធិបតេយ្យ ដែលលោកបានឆ្លងកាត់នោះ?

**ឆ៖** អរគុណ។ ពេលនោះខ្ញុំនៅក្មេងពេក ហើយក៏ខ្ញុំមិនបានចាប់អារម្មណ៍ពីរឿងអ្វីដែលថា លន់ នល់ គ្រាន់តែថា ចាំមិនយកធ្វើជាការពិតបានទេបាទ។

[១០:៥០:១៥]

**ស៖** តើលោកបានជួបហេតុការណ៍ណាមួយដែលពាក់ព័ន្ធនឹងៗទាហាន់ លន់ នល់ ដែរទេ? លោកធ្លាប់ឃើញ ឬក៏ធ្លាប់ជួបប្រទះ ធ្លាប់មានទំនាក់ទំនងអីជាមួយនឹងខាងទាហាន លន់ នល់ ទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំដូចមិនដឹង។

**ស៖** ក្នុងឯកសារដដែល គឺ E319/13.3.41 ត្រង់សំណួរទី៤0 អ្នកស៊ើបអង្កេតបានសួរលោក ថា៖ “ចុះចំពោះមន្ត្រីរដ្ឋការលន់នល់ អតីតទាហានលន់នល់ ឬអ្នកដែលពាក់ព័ន្ធនឹងរបបលន់នល់ តើមាន រឿងអីកើតឡើងចំពោះមនុស្សទាំងអស់នោះ ពេលដែលខ្មែរក្រហមឡើងគ្រប់គ្រងអំណាច? លោកបាន ឆ្លើយថា៖ ខ្ញុំបានឃើញសាកសពប្រហែល៣០ទៅ៤០នាក់។” លោកបានឆ្លើយជាមួយនឹងអ្នកស៊ើប អង្កេតថាដូច្នេះ។ តើលោកបានៗឃើញមែន ឬក៏ចម្លើយដែលលោកឆ្លើយកាលនោះ យ៉ាងម៉េច?

**ឆ៖** បាទ ពេលនោះខ្ញុំបានឃើញជាឯកសណ្ឋានទាហានប៉ាវ៉ា ឃើញមួកដែក ឃើញអី។ តែពួកគាត់ត្រូវគេសម្លាប់ ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់នូវអ្វីដែលថាជាអាវុធ ឬមួយជាព្រនង់ ខ្ញុំអត់បានដឹងទេ ពីព្រោះអីពេលនោះសាកសពស្អុយហើយ ខ្ញុំ អង្គការគេឲ្យឃ្វាលក្របីនៅក្នុងសហករណ៍ត្រាំសេះ ទួលកោះតាកនហ្នឹងដដែល។ ខ្ញុំគ្រាន់តែបានឃើញសាកសពស្អុយរលួយ ហើមអស់ហើយ ខ្ញុំមើលពុំស្គាល់។

**ស៖** លោកឃើញសាកសពហ្នឹងនៅទួលៗកោះតាកនហ្នឹង នៅឃុំណា ភូមិណាដែរ?

**ឆ៖** អរគុណ។ គឺនៅក្នុងសហករណ៍ត្រាំសេះដដែល ឃុំខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ដដែល ប៉ុន្តែគ្រាន់ជាទួលមួយគឺទួល គេហៅទួលកោះតាកន។

[១០:៥២:៥៥]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងជាតិ អង្គជំនុំជម្រះបានបែងចែកខាងភាគីពាក់ព័ន្ធផ្សេងទៀតហ្នឹងមានពេលតែ២៥នាទីទេ ហើយការប្រើប្រាស់ពេលវេលារបស់លោក ដូចជាលើសច្រើនហើយ។

**លោក ស្រ៊ា រតនៈ៖**

អឺចឹងជម្រាបសួរលោកប្រធាន តើខ្ញុំអាចនៅសល់សំណួរប៉ុន្មានទៀត ឬក៏អស់ហើយបាទ?

**ប្រធានអង្គជំនុំ៖**

លោកប្រើពេលវេលាលើសការចែកជូនហើយ ចែកជូនឲ្យតែ២៥នាទីទេក្នុងភាគីផ្សេងទៀតណា។

បាទ តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ដំបូងនេះផ្តល់វេទិកាជូនក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន។ សូមអញ្ជើញ!

**លោក លីវ សុវណ្ណា៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាក្រុមមេធាវីជាតិការពារលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួន សួរបញ្ជាក់លោកបន្ថែម។ ទី១ សំណួរខ្ញុំទី១ មុននេះគឺ

លោកបានរៀបរាប់ថា លោកត្រូវបានគេបំបែកពីឪពុកម្ដាយ ទៅនៅកងកុមារ។ អ៊ីចឹងសំណួរខ្ញុំសួរថា តើកុមារខ្មែរផ្សេងទៀតនោះ ត្រូវបានគេបំបែកដូចលោកដែរឬទេ?

[១០:៥៤:៣៥]

**លោក ម៉ី ពៅ៖**

**ឆ៖** បាទ អរគុណ។ កុមារខ្មែរផ្សេងទៀតក៏ត្រូវបំបែកដែរ ក៏ប៉ុន្តែកុមារ គេនៅជាមួយខ្មែរ តែកុមារខ្ញុំចាម នៅម្នាក់ឯង។

**ស៖** សូមលោកបញ្ជាក់មើល នៅម្នាក់ឯង គេដាក់លោកនៅម្នាក់ឯង ឬក៏នៅជាមួយកងជាមួយនឹងកុមារខ្មែរផ្សេងទៀតដែរ?

**ឆ៖** បាទ អរគុណ។ គឺកុមារខ្មែរគេជម្លៀសចេញពីម៉ែឪទៅ គេនៅជាមួយកុមារខ្មែរ។ រីឯខ្ញុំជនជាតិចាមម្នាក់ឯង ទៅរស់នៅជាមួយកុមារខ្មែរដែរ។ តែគ្រាន់តែម្នាក់ឯង អត់មានចាមដូចគ្នាទៀត។

**ស៖** បាទ អរគុណ។ អ៊ីចឹងសូមលោកបញ្ជាក់មើល មូលហេតុដែលលោកមានចាមកុមារចាមតែម្នាក់ឯង ដោយសារក្នុងភូមិនោះពុំមានគ្រួសារចាមផ្សេងទៀតក្រៅពីគ្រួសារលោក ឬក៏មានមូលហេតុអីផ្សេង?

**ឆ៖** អរគុណ។ ពេលនោះរបបខ្មែរក្រហម មិនថាចាស់ ឬមួយក្មេង ឬមួយកុមារទេ គឺដាច់ខាតឲ្យតែជនជាតិចាម ត្រូវតែគេបំបែកពីក្រុម គេមិនឲ្យនៅជុំគ្នាទេ។

[១០:៥៦:២០]

**ស៖** បាទ សំណួររបស់ខ្ញុំអំមិញលោកបានបញ្ជាក់ថា កុមារខ្មែរក៏ត្រូវនៅកងកុមារខ្មែរ ឯលោកក៏ត្រូវបានបំបែកពីឪពុកម្ដាយទៅនៅកងកុមារជាមួយនឹងកុមារខ្មែរ។ អ៊ីចឹងលោកថា ចាមគឺមានតែលោក អ៊ីចឹងសំណួររបស់ខ្ញុំសួរថា តើមូលហេតុដែលគេបំបែកលោកទៅនៅជាមួយកុមារខ្មែរនេះ ដោយសារតែនៅក្នុងសហករណ៍របស់លោករស់នៅហ្នឹង វាមានកុមារចាមតែលោកម្នាក់ឯង ឬក៏កុមារចាមផ្សេងទៀត គេនៅក្នុងសហករណ៍មានកុមារចាមផ្សេងទៀត ហើយគេប្រព្រឹត្តយ៉ាងណា?

**ឆ៖** បាទ អរគុណ។ កុមារចាមមានច្រើន ក៏ប៉ុន្តែអង្គការកំណត់ មិនឲ្យចាមនៅរស់នៅជុំគ្នាទេ ទោះបីជាមានច្រើន ក៏កុមារចាមនៅតែគេបំបែកតែដដែលទេ ព្រោះអីនៅតាមគ្រូនីមួយៗ គឺមានតែចាមតែខ្ញុំម្នាក់អ៊ីចឹងទៅ ហើយចាមអ្នកដទៃទៀត ក៏ម្នាក់អ៊ីចឹងទៅ គេអត់ឲ្យជុំគ្នាជាក្រុមទេ។

**ស៖** តើសហករណ៍របស់លោក មានកងកុមារប៉ុន្មានក្រុមដែរ?

**ឆ៖** ពេលនោះខ្ញុំមិនដឹងថាជាហេដ្ឋារចនាសម្ព័ន្ធរបស់របបខ្មែរក្រហម គេរៀបចំថាយ៉ាងម៉េចទេ ប៉ុន្តែគ្រាន់តែថានៅគ្រួរបស់ខ្ញុំមានបីនាក់ ហើយកុមារខ្ញុំគឺនៅភូមិត្រាំសេះហ្នឹង មានតែម្នាក់ខ្ញុំជាកុមារចាម។

**ស៖** អ៊ីចឹងនៅក្នុងសហករណ៍ត្រាំសេះហ្នឹង គឺកុមារចាមមានតែលោកម្នាក់ទេ។ អ៊ីចឹងតើមែនទេ ដែលខ្ញុំនិយាយអ៊ីចឹង?

**ឆ៖** អរគុណ។ មានតែខ្ញុំម្នាក់ទេដែលថាជាចាមម្នាក់ តែកុមារផ្សេងៗទៀតសុទ្ធតែជាខ្មែរ។

[១០:៥៨:៣៤]

**ស៖** អ៊ីចឹងបើខ្ញុំអាចសង្ខេបបានថា មូលហេតុដែលនៅក្នុងកងកុមារមានតែលោកជាចាមកុមារចាមតែម្នាក់ដោយសារក្នុងភូមិនោះ គឺមានកុមារចាមតែម្នាក់លោក។ បើខ្ញុំសង្ខេបអ៊ីចឹងត្រឹមត្រូវដែរឬទេបាទ?

**ឆ៖** អរគុណ។ ខ្ញុំមិនទាន់ទទួលយកបានថា ព្រោះកុមារចាមដែលនៅក្នុងសហករណ៍មិនដឹងជាមានប៉ុន្មានភូមិទេ ក៏ប៉ុន្តែកុមារចាមមិនអាចប្រមូលផ្តុំគ្នាបានត្រង់ចំណុចមួយថា ចាមគឺនៅតែម្នាក់ឯងម្នាក់ឯង ដូចជាគ្រួសារក៏នៅម្នាក់ឯង ដូចជាកុមារក៏នៅម្នាក់ឯង ដូចនៅកងផ្សេងៗក៏នៅបែកតែឯងដែរ គេមិនឲ្យចាម រស់នៅជុំជាក្រុមទេ។

**ស៖** ខ្ញុំអំមិញសួរមិនមែនសួរដល់សហករណ៍ផ្សេងទៀតទេ ខ្ញុំសួរតែសហករណ៍ត្រាំសេះ ដែលលោករស់នៅ។ អ៊ីចឹងសហករណ៍ត្រាំសេះហ្នឹង លោកអំមិញបញ្ជាក់ថា កុមារចាមមានតែលោកម្នាក់ទេដែល ហើយក៏បានទៅរស់នៅជាមួយកុមារខ្មែរ។ ខ្ញុំអត់បានសួរទៅលើសហករណ៍ផ្សេងទៀត ក្រៅពីសហករណ៍ត្រាំសេះទេ។ អ៊ីចឹងខ្ញុំសួរថា តើលោកថាបំបែកកុមារចាមហ្នឹង អត់ឲ្យនៅជាមួយកុមារចាម ប៉ុន្តែជាក់ស្តែង នៅក្នុងសហករណ៍ត្រាំសេះនេះ គឺមានតែចាម កុមារចាមតែលោកម្នាក់ទេ។ អ៊ីចឹងបើខ្ញុំសួរថា តើអាការដែលលោកមានម្នាក់ឯងនៅក្នុងសហករណ៍កងកុមារ សហករណ៍ត្រាំសេះនេះដោយសារតែកុមារចាមមានតែលោកម្នាក់ ឬយ៉ាងណា?

**ឆ៖** អរគុណ។ ពេលនោះគឺនៅក្នុងកុមារជាមួយខ្ញុំ មានតែខ្ញុំម្នាក់គត់ តែមិនដឹងជាចាមមានប៉ុន្មានទៀត ខ្ញុំមិនបានដឹងទេ ប៉ុន្តែខ្ញុំដឹងថាខ្ញុំជាចាមម្នាក់ឯង។

[១១:០០:៤៣]

**ស៖** តើគិតមកត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលនោះលោកមានអាយុប៉ុន្មានហើយ?

**ឆ៖** អរគុណ។ ខ្ញុំកើតឆ្នាំ១៩៦១ អ៊ីចឹងបើគិតមកខ្ញុំអាយុ១៣, ១៤ឆ្នាំ មិនលើសខ្វះទេ។

**ស៖** តើពីមុនឆ្នាំ១៩៧៥ លោកបានរៀនដែរទេ? ហើយបើរៀន រៀនដល់ថ្នាក់ទីប៉ុន្មានបាទ?

**ឆ៖** អរគុណ។ ពេលនោះខ្ញុំបានរៀនត្រឹមថ្នាក់ បើថានិយាយឥឡូវនេះសម័យឥឡូវ ថ្នាក់ទី១។

**ស៖** លោកអាចបញ្ជាក់បាន ហេតុអីបានជាលោកអាយុ១៤ឆ្នាំហើយ លោករៀនបានត្រឹមថ្នាក់ទី១?

**ឆ៖** បាទ អរគុណ។ មូលហេតុបានថាខ្ញុំមិនសូវបានរៀន ពីព្រោះអីខ្ញុំរៀនថ្នាក់ទី១ កាលពីសម័យនោះ ការខ្វះខាតសាលារៀន អត់មានអ្នកណាឃ្វាលគោ អត់មានអ្នកណាឃ្វាលអី ម្ល៉ោះហើយខ្ញុំមិនបានរៀនបាទ។

**ស៖** មុននេះលោកបានថ្លែងថា មូលហេតុដែលលោកពុំមានចំណេះដឹងរហូតដល់សព្វថ្ងៃ ដោយសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យពុំឲ្យលោករៀន។ ចុះឥឡូវក្នុងរបប មុនរបបកម្ពុជាប្រជាធិបតេយ្យដែរនោះ លោកមិនបានរៀនដែរ តើលោកយល់យ៉ាងម៉េច? តើលោក មូលហេតុអីបានជាលោកមិនបានដែរ? ហើយតើការបាត់បង់ចំណេះដឹងរបស់លោក មួយផ្នែកលោកទទួលស្គាល់ទេថា មួយផ្នែកគឺវាកើតឡើងមុនឆ្នាំ១៩៧៥ ទៅទៀត?

**ឆ៖** បាទ អរគុណ។ ដែលខ្ញុំមិនបានរៀនឆ្នាំ១៩៧០គត់មកទល់នឹងឆ្នាំ១៩៧៥ ពីព្រោះអី កាលហ្នឹងទាក់ទងទៅនឹងការសង្គ្រាម បានខ្ញុំមិនបានរៀន។

[១១:០៣:២៨]

**ស៖** មុននេះលោកបានបញ្ជាក់ថា គ្រួសាររបស់លោកត្រូវបានជម្លៀសនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ អ៊ីចឹងក្រៅពីគ្រួសារលោក តើមានគ្រួសារខ្មែរណាដែលនៅក្នុងភូមិរបស់លោក ត្រូវបានជម្លៀសដូចគ្នាដែរទេ?

**ឆ៖** អរគុណ។ ដែលនៅក្បែរជិតខាងខ្ញុំ មិនមែនថាជម្លៀសតែគ្រួសារខ្ញុំទេ ក៏ប៉ុន្តែដែលគ្រួសារខ្មែរដែលជម្លៀសដែលគេជាមូលដ្ឋាន គេជម្លៀសទៅដឹកនាំពួកខ្ញុំដដែលទេ។ តែបើពួកខ្ញុំជម្លៀសៗចាកចេញពីភូមិ ទៅធ្វើ១៧មេសា។

**ស៖** អ៊ីចឹងមានន័យថា ការជម្លៀសចេញពីភូមិកំណើតរបស់លោក គឺជម្លៀសទាំងខ្មែរទាំងចាម តើអ៊ីចឹងមែនទេ?

**ឆ៖** អរគុណ។ ការជម្លៀសចេញពីភូមិ មានខ្មែរមានចាម។ ក៏ប៉ុន្តែខ្មែរមូលដ្ឋានគេជម្លៀសឲ្យ

ទៅដឹកនាំអ្នក១៧ ដូចជារូបខ្ញុំផ្ទាល់។ ហើយប្រជាជន១៧ទូទៅ គេជម្លៀស ក៏ប៉ុន្តែជម្លៀសឲ្យគ្នា ឲ្យពួកគាត់ទៅធ្វើពលកម្ម ហើយជម្លៀសពួកគាត់មួយផ្នែកទៀតជាមូលដ្ឋាន គឺឲ្យទៅធ្វើមេសហករណ៍ ឲ្យទៅធ្វើគណៈតំបន់ ឲ្យទៅធ្វើការមេកង សម្រាប់ត្រួតត្រាពួក១៧នេះឯង។

**ស៖** មុននេះលោកបានបញ្ជាក់ថា ករណីឪពុកលោក គឺអង្គការបានយកសាច់ជ្រូកឲ្យគាត់ហូប ប៉ុន្តែគាត់បានប្រកែក ហើយអង្គការបានប្រាប់ថា អង្គការមានតែសាច់ជ្រូកទេ បើមិនហូបអង្គការគ្មានអ្វីឲ្យហូបទេ។ អ៊ីចឹងគេអត់បានយកឪពុកលោកទៅសម្លាប់ ដោយសារមូលហេតុដែលគាត់បានប្រកែកមិនហូបសាច់ជ្រូកហ្នឹងទេ មែនទេ?

[១១:០៦:០០]

**ឆ៖** អរគុណ។ ពេលនោះអង្គការមិនបានយកគាត់ទៅសម្លាប់មែន ក៏ប៉ុន្តែអង្គការបានធ្វើទារុណកម្មមិនឲ្យគាត់សម្លាប់ មិនឲ្យគាត់រស់ ពេលនោះហើយជាលំបាករបស់គាត់ ស្គម ហើយដល់ពេលគេថា អង្គការមានតែសាច់ជ្រូក យកមកឲ្យគាត់ហូប គាត់អត់ហូប។ ពេលនោះឯងអង្គការធ្វើបាបគាត់ ឲ្យគាត់រស់ ក៏ប៉ុន្តែរស់ទាំងវេទនា រស់ទម្រាំស្លាប់។ ការសម្លាប់នេះតែដដែលទេ ក៏ប៉ុន្តែមួយសម្លាប់យូរ ទុកឲ្យយូរបានស្លាប់។

**ស៖** ខ្ញុំចង់បញ្ជាក់ចំណុចដែលលោកថា លោកបានឃើញមានសាកសពគ្រួសារមូស្លីមមួយដែលរស់នៅជិតផ្ទះរបស់លោក នៅវាលស្រែជិតទួលស្តែង។ អ៊ីចឹងខ្ញុំ -- ហើយលោកអំមិញក៏បានបញ្ជាក់ថា មានកុមារផ្សេងទៀត បានប្រាប់លោកថា គ្រួសារនេះហើយជាគ្រួសារដែលចាម ដែលរស់នៅជិតផ្ទះលោក។ អ៊ីចឹងដែលពេលដែលលោកឃើញសាកសពនោះ ពេលហ្នឹងតើលោកដឹងថាជាគ្រួសារចាមហ្នឹង ឬក៏លោកដឹងដោយសារកុមារផ្សេងបានប្រាប់លោក?

**ឆ៖** បាទ អរគុណ។ ខ្ញុំដឹងមិនមែនដោយសារកុមារប្រាប់ខ្ញុំទេ។ ខ្ញុំឃើញនឹងភ្នែកផ្ទាល់ តែការសម្លាប់រួច ហើយព្រមទាំងកុមារមួយទៀតមកប្រាប់ខ្ញុំថា “តាចាមហ្នឹងគេយកនៅហ្នឹងឯង អ្ហែងឃើញអត់?” បាទប៉ុណ្ណឹង។

**ស៖** ពេលដែលលោកឃើញហ្នឹង តើសាកសពហ្នឹងហើមរលួយហើយ ឬក៏មិនទាន់ទេ?

[១១:០៨:០០]

**ឆ៖** អរគុណ។ ពេលនោះសាកសពអស់ពីហើមហើយ រាងស្វិតបន្តិចទៀត បន្តិចហើយ អាចយើងស្គាល់ចំណាំសម្លៀកបំពាក់របស់គាត់ដែលនៅក្បែរគ្នា ដូចជាសារុង ដូចជាស្អី១អ៊ីចឹង។ ធម្មតាអ្នក

កាន់សាសនាអ៊ីស្លាម ទៅណាគាត់ស្លាយរបស់គាត់ទៅអ៊ីចឹង។ ម៉្លោះហើយឯកសណ្ឋានហ្នឹងខ្ញុំស្គាល់អាចស្គាល់ ខ្ញុំអាចសម្គាល់បាន។

**ស៖** តើឯកសណ្ឋានហ្នឹង ឯកសណ្ឋានដែលជាប់នៅលើខ្លួនគាត់ដែលគាត់ស្លៀកពាក់ជាប់នៅលើខ្លួន ឬមួយឯកសណ្ឋានដែលនៅផ្សេងពីកន្លែងសាកសព?

**ឆ៖** ទី១ ឯកសារសណ្ឋានដែលនៅជាប់នឹងខ្លួន។ ទី២ អានៅសាកសពហ្នឹងឃើញសារុងឃើញអីថែមទៀត ហើយនិងកាតឹបស ដូចខ្ញុំពាក់នេះឯង ហើយនិងអាវបំពង់វែង ប្រពន្ធគាត់អីនៅហ្នឹងដែលជាស្ត្រី ដូចជា កន្សែង ដូចជាអី។

**ស៖** ពេលនោះ តើលោកចាំបានទេ នៅក្នុងដែលលោកឃើញហ្នឹង ក្នុងខែណា ឆ្នាំណាដែរ?

**ឆ៖** សូមទោស ខ្ញុំដូចចាំមិនបានច្បាស់ទេ លោកប្រធាន។

**ស៖** លោកឃើញនោះ ឃើញក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហ្នឹងប៉ុន្មានខែដែរ តាមការកត់សម្គាល់របស់លោក?

**ឆ៖** អរគុណ។ ខ្ញុំឃើញ ខ្ញុំមិនចាំខែទេ ហើយខ្ញុំមិនចាំថ្ងៃទេ គឺខ្ញុំឃើញពួកគាត់ស្លាប់ហ្នឹង គឺនៅក្នុងឆ្នាំ១៩៧៥។

[១១:១០:០៧]

**ស៖** អ៊ីចឹងនៅក្នុងតំបន់លោក ជនជាតិចាមយើង គេនៅឲ្យស្លៀកសម្លៀកបំពាក់ប្រពៃណីដែរឬបានជាលោកឃើញសាកសពមានសម្លៀកបំពាក់ប្រពៃណី?

**ឆ៖** អរគុណ។ មិនមែនជាសម្លៀកបំពាក់ប្រពៃណីទេ តែខ្ញុំចំណាំសម្លៀកបំពាក់របស់គាត់ដែលនៅជាជិតគ្នា ហើយសម្លៀកបំពាក់ប្រពៃណីនេះ ខ្ញុំឃើញដែលបង្ខិចគាត់រាត់វាយទេ។

**ស៖** អំមិញលោកបញ្ជាក់មុនហ្នឹងបន្តិចថា នៅលើសាកសពមានពាក់កាតឹប ហើយនិងមានស្លៀកសារុងប្រពៃណី ហើយមានក្រមារុំ។ អ៊ីចឹងបានខ្ញុំសួរបញ្ជាក់ថា តើអ្នកដែលស្លាប់នុ៎ង គាត់នៅស្លៀកសម្លៀកបំពាក់ប្រពៃណី ឬក៏មិនមែន ហើយឥឡូវលោកថា អត់ទេ ឃើញនៅជិតហ្នឹងវិញ។ អ៊ីចឹងតើសម្ដីមួយណាដែលត្រឹមត្រូវ លោក?

**ឆ៖** អរគុណ។ ខ្ញុំអំមិញភ្លេចបញ្ជាក់។ ដែលពេលដែលគាត់ស្លាប់ ឯកសណ្ឋានខោអាវរបស់គាត់ គឺខ្ញុំចំណាំ តែអារឿងសម្លៀកបំពាក់ជាសាសនាដែលនៅក្នុងបង្ខិច នៅក្បែរនោះទេ មិនមែនគាត់ស្លៀកបំពាក់ជាឯកសណ្ឋានទេ។

**ស៖** អ៊ីចឹងលោកឆ្លើយមុនហ្នឹង តើដែលថាឃើញគាត់ពាក់កាតឹប ពាក់អីហ្នឹង តើលោកយល់យ៉ាងម៉េចដែរ? បើលោកទើបនឹងឆ្លើយហើយមុនហ្នឹង ឥឡូវលោកដូរជំហរវិញ តើលោកអាចបញ្ជាក់មូលហេតុបានទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំគ្រាន់តែថា មិនបានបញ្ជាក់ ខ្ញុំបើថានិយាយ ដូចយើងរាងលឿនបន្តិច។ ពេលដែលខ្ញុំចំណាំឯកសណ្ឋានរបស់គាត់ គាត់ស្លៀកពាក់ជាខោអាវធម្មតាទេ ដែលគេយកគាត់ទៅសម្លាប់។ ហើយពេលដែលបង្ខិចខោអាវជាកាតឹប ជាអាវបំពង់វែង ជាកន្សែងអី គឺពួកគាត់បានយកជាប់ទៅជាមួយខ្លួន ហើយដល់ពេលគេសម្លាប់ពួកគាត់ របស់របរហ្នឹងនៅហ្នឹង ជាភស្តុតាង។

[១១:១២:៣៧]

**ស៖** ខ្ញុំចង់បញ្ជាក់មួយទៀត លោកមុននេះក៏លោកបានថ្លែងថា លោកបានឃើញក្រុមជនមូស្លីមមួយក្រុម ត្រូវបានសម្លាប់នៅទួលស្លែង។ អ៊ីចឹងលោកថា មូលហេតុដែលលោកគិតថា គាត់ជាក្រុមមូស្លីម ដោយសារឃើញសម្លៀកបំពាក់ហ្នឹងនៅរាយប៉ាយនៅនុ៎ង គឺសម្លៀកបំពាក់ដែលមានជាសម្លៀកបំពាក់សម្គាល់ជាជនជាតិចាម។ ហើយលោកក៏បានបញ្ជាក់ថា ទួលនោះគឺកន្លែងសម្លាប់មនុស្ស។ អ៊ីចឹងខ្ញុំចង់បញ្ជាក់លោកឲ្យច្បាស់ថា ថ្ងៃដែលលោកឃើញគេសម្លាប់នោះ ពេលនុ៎ង តើជាជនជាតិខ្មែរ ឬក៏ជាជនជាតិចាម ឬក៏ជាជនជាតិខ្មែរលាយជនជាតិចាម? ហើយការដែលសម្លៀកបំពាក់ដែលលោកឃើញរាត់រាយនៅទីនោះ ជាសម្លៀកបំពាក់ដែលលោកឃើញគេដោះចេញពីជនរងគ្រោះសម្លាប់ពេលហ្នឹងផ្ទាល់ ឬមួយក៏ជាសម្លៀកបំពាក់ដែលលោកឃើញនៅទីនោះហើយស្រាប់ហើយ?

**ឆ៖** បាទ អរគុណ។ ពេលនោះខ្ញុំគ្រាន់តែដឹងថា ជាជនជាតិចាមមួយក្រុមដែលគេត្រូវយកទៅសម្លាប់ហ្នឹង នៅនឹងព្រៃទួលស្លែងហ្នឹង។ ខ្ញុំមិនបានទៅឈរមើលដោយច្បាស់ទេ។ អ៊ីចឹងគ្រាន់តែជាសម្គាល់មួយដែលជារបស់របររាត់រាយនោះទេ។

**ស៖** ហេតុអីបានជាលោកគិត លោកឆ្លើយថា របស់របររាត់រាយជារបស់ដែលជនរងគ្រោះដែលគេកំពុងតែ -- លោកឃើញគេសម្លាប់នុ៎ង? ហេតុអីបានជាលោកគិតថា ជារបស់គាត់ ព្រោះទីនោះគឺមានការសម្លាប់ពីមុនមកហើយ?

**ឆ៖** បាទ សូមអរគុណ។ ពេលនោះបានជាខ្ញុំថាពួកគាត់ ពីព្រោះថ្ងៃនោះ ថ្ងៃមិនមែនជាគាត់ គេយកទៅសម្លាប់ក្រោយគេទេ ពីព្រោះទួលស្លែងនេះ គឺគេយកគាត់ យកទៅសម្លាប់ឆ្នាំ៧៥។ អ៊ីចឹងគឺមានគាត់ទៅមុនគេ អត់មានគេទៅមុនគាត់ទេ។ អ៊ីចឹងបានជាខ្ញុំហ៊ានធ្វើការសន្និដ្ឋានថា របស់នេះ គឺជារបស់

អ៊ីស្លាម។

[១១:១៥:១៤]

**ស៖** ខ្ញុំចង់បញ្ជាក់លោកមួយទៀត តើលោកជាប់នៅក្នុងមន្ទីរត្រាចក្រោលហ្នឹង ប៉ុន្មានខែដែរ?

**ឆ៖** អរគុណ។ ខ្ញុំជាប់មន្ទីរត្រាចក្រោល ចុងឆ្នាំ១៩៧៧ ដើមឆ្នាំ១៩៧៨។

**ស៖** អ៊ីចឹងលោកជាប់ពីចុងឆ្នាំ១៩៧៧ រហូតដល់ដើមឆ្នាំ១៩៧៨។ មានន័យអ៊ីចឹង ឬក៏យ៉ាងម៉េចដែរលោក?

**ឆ៖** បាទ។

**ស៖** លោកជាប់នៅទីនោះ ដោយសារមូលហេតុអីដែរ?

**ឆ៖** អរគុណ។ ខ្ញុំបានគេចោទប្រកាន់ ពួកឈ្លបបានចោទប្រកាន់ខ្ញុំថា ខ្ញុំធ្វើការ ខ្ញុំធ្វើអ្វីមួយក្បត់នឹងអង្គការ។ ចោទប្រកាន់ខ្ញុំថាខ្ញុំលួចស្រូវរបស់អង្គការ ចោទប្រកាន់ខ្ញុំថាខ្ញុំខ្មាំង ទើបបានគេចាប់ខ្ញុំដាក់គុក។

**ស៖** ហើយគេដោះលែងលោកនៅដើមឆ្នាំ១៩៧៨ គេដោះលែងហ្នឹង គេប្រាប់លោកថាម៉េចដែរបានគេដោះលែងលោក?

**ឆ៖** អរគុណលោកប្រធាន។ ខ្ញុំអត់មានអ្នកណាដោះលែងទេ តែខ្ញុំមិនចង់និយាយ។ ទាល់ឆ្នាំ១៩៧៩ គេវៃបែក បានខ្ញុំត្រូវពួកប្រជាជនដូចគ្នាមកកាត់ខ្នោះឲ្យទេ។

**ស៖** មុននេះលោកបានឆ្លើយថា លោកជាប់នៅមន្ទីរត្រាចក្រោលហ្នឹង ពីចុងឆ្នាំ១៩៧៧ ដល់ដើមឆ្នាំ១៩៧៨ តែឥឡូវលោកថាដល់ក្រោយថ្ងៃទី០៧ មករា ៧៩បានលោកត្រូវរួចខ្លួន។ អ៊ីចឹងលោកបញ្ជាក់មើល អានេះហេតុការណ៍នេះយ៉ាងម៉េចដែរ?

[១១:១៧:៥៨]

**ឆ៖** អរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់លោកប្រធានថា គេចោទប្រកាន់ខ្ញុំនៅចុងឆ្នាំ១៩៧៧ គេយកខ្ញុំទៅដាក់គុកនៅឆ្នាំ១៩៧៨ រហូតដល់ឆ្នាំ១៩៧៩ ដែលខ្ញុំចេញខ្លួនឯង។ ខ្ញុំជាប់គុកជាង១ឆ្នាំ។

**ស៖** ខ្ញុំសូមអនុញ្ញាតឯកសារទម្រង់បែបបទរបស់ដើមបណ្តឹងរដ្ឋប្បវេណី បែបបទព័ត៌មានពីជនរងគ្រោះហ្នឹង នៅឯកសារ D22/1078 ទំព័រទី៥ មានតែភាសាខ្មែរ គឺលោកបានឆ្លើយថា៖ "នៅខែ១០ នាពេលស្រូវចេញស្តាបសេកឆ្នាំ១៩៧៨ នៅសហករណ៍ត្រាង នៅភូមិត្រាង ឃុំមេទឹក ស្រុកបាកានខេត្តពោធិ៍សាត់ ខ្ញុំបានឃើញគេបូតស្រូវ តែខ្ញុំពុំបានរាយការណ៍ឲ្យគេ។ ឈ្លបបានចាប់អ្នកបូតស្រូវយក

ទៅបាត់។ ហើយខ្ញុំត្រូវឈ្លបឈ្មោះ អឿង ចាប់ ដោយចោទថាមិនរាយការណ៍ជូនអង្គការ។ ហើយឈ្លបឈ្មោះ ប៉ូច បានចាប់បញ្ជូនខ្ញុំដាក់មន្ទីរត្រាចក្រោល។" អ៊ីចឹងសូមបញ្ជាក់មើល អំមិញ ព្រោះតាមអ្វីដែលលោកបានបំពេញបែបបទមក គឺខែ១០ ឆ្នាំ៧៨ ហេតុការណ៍បានគេចាប់លោក។ ហើយមូលហេតុ មិនមែនដោយសារលោកលួចគេទេ ដោយសារលោកមិនបានរាយការណ៍ ឃើញគេលួចបូតស្រូវមិនបានរាយការណ៍។ អ៊ីចឹងចម្លើយទាំងពីរហ្នឹងខុសគ្នា តើលោកយល់ថាម៉េចដែរបាទ?

**ឆ៖** បាទ អរគុណ។ ខ្ញុំសូមបញ្ជាក់ម្តងទៀត។ ពេលនោះ ខ្ញុំកំពុងតែធ្វើការ ខ្ញុំធ្វើការ ខ្ញុំធ្វើ -- ខ្ញុំថា គេចាប់ខ្ញុំចុងឆ្នាំ១៩៧៧ គឺខែ១០ ព្រោះអី ខ្ញុំចាំបានថា ខែស្រូវទុំស្គាបសេកគឺខែ១០។ អ៊ីចឹងពេលនោះខ្ញុំបានឃើញគេលួចបូតស្រូវមែន ហើយខ្ញុំក៏មិនបានរាយការណ៍ដែរ ព្រោះអីខ្ញុំកំពុងតែធ្វើការភ្ជួររាស់។ ពេលនោះគេតាមដានខ្ញុំតាំងពីថ្មើរម៉ាន ថ្មើរម៉ាន ខ្ញុំមិនដឹងទេ។ ពេលនោះខ្មែរក្រហមចោទប្រកាន់ពួកខ្ញុំថាពួកខ្ញុំគប់គិតនឹងខ្មាំង ហើយក្បត់នឹងអង្គការចាត់តាំង បានឃើញខ្មាំងបូតស្រូវអត់បានរាយការណ៍។

[១១:២០:៣៩]

**ស៖** ដោយសារពេលវេលាខ្លី ខ្ញុំសូមបញ្ជាក់សំណួរមួយចុងក្រោយ។ ក្នុងចំណោមសមាជិកបងប្អូនបង្កើតរបស់លោកមានប៉ុន្មាននាក់ដែរ?

**ឆ៖** អរគុណ។ បងប្អូនបង្កើតរបស់ខ្ញុំមានបួននាក់។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ អ្នកទាំងបួន គាត់នៅរស់ ឬក៏គាត់ត្រូវស្លាប់?

**ឆ៖** អរគុណ។ គាត់នៅរស់ ស្លាប់តែឪពុក។

**ស៖** តើស្លាប់ -- ដែលលោកនៅក្នុងចម្លើយរបស់លោក ថាសមាជិកគ្រួសារ១៧នាក់ រួមមានមីងថ្លៃ មីងអីសរុបហ្នឹង តើភាគច្រើនគាត់ស្លាប់ដោយសារជំងឺ ស្លាប់ដោយសារអត់អាហារ ឬក៏ស្លាប់ដោយសារមូលហេតុអីផ្សេង?

**ឆ៖** ក្នុងរង្វង់១៧នាក់ មានអ្នកខ្លះគាត់ស្លាប់ដោយអត់អាហារ មានអ្នកខ្លះគាត់ស្លាប់ដោយសារជំងឺគ្រុនចាញ់ មានអ្នកខ្លះត្រូវសម្លាប់ដោយវះប្រឡាក់អំបិល។

**លោក លីវ សុវណ្ណា៖**

បាទដោយសារពេលវេលាអស់ ខ្ញុំបាទអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ អរគុណលោកប្រធាន។

[១១:២២:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ ខ្ញុំបាទ គង់ សំអុន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** តទៅនេះខ្ញុំមានសំណួរតែមួយទេទាក់ទងទៅនឹងទីតាំងដែលលោកត្រូវបានគេចាប់ដាក់ឃុំ។ លោកបានបញ្ជាក់តាមសំណួរដើម ជាពិសេសក៏មាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកមុនៗ ហើយដូចពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក។ លោកបញ្ជាក់ថា លោកត្រូវបានគេឃុំខ្លួននៅមន្ទីរសន្តិសុខត្រាចក្រោល។ លោកអាចបញ្ជាក់ពីទីតាំងជាក់លាក់បានទេ ថាស្ថិតនៅកន្លែងណាដែរ?

**លោក ម៉ី ពៅ៖**

**ឆ៖** បាទ អរគុណ។ ព្រោះកន្លែងមន្ទីរត្រាចក្រោល ពេលនោះខ្ញុំមិនទាន់ដឹងថា ជាឃុំអ្វី ជាអីអ្វីទេ ព្រោះមន្ទីរត្រាចក្រោលគឺជាវត្ត ហើយខ្ញុំចាំថា ទីតាំងច្បាស់គឺស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** ហេតុដូចម្តេចបានជាលោកដឹងថា វាជាមន្ទីរសន្តិសុខ? លោកអាចបញ្ជាក់បានទេ?

**ឆ៖** អរគុណ។ ពីព្រោះកន្លែងហ្នឹង មានកន្លែងគេឃាមកាមតឹងតែងណាស់ ហើយកន្លែងហ្នឹងគឺកន្លែងឃុំឃាំងខ្លួនខ្ញុំផ្ទាល់តែម្តង។

[១១:២៤:៣០]

**ស៖** បាទសូមអរគុណ។ លោកអាចបញ្ជាក់បានទេថា ទីតាំងមន្ទីរសន្តិសុខត្រាចក្រោលនេះមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង០០២ នេះដែរទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំមិនបានដឹង--

**លោក ពេជ អង្គ៖**

លោកប្រធាន!

**លោក ម៉ី ពៅ៖**

**ឆ៖** បាទ អរគុណ។ ខ្ញុំអត់--

**លោក ពេជ អង្គ៖**

សូមៗឈប់បន្តិច។

**ប្រធានអង្គជំនុំ៖**

អំម៉េចទៅ? អញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន អម្បាញ់មិញលោកមេធាវី គង់ សំអុន បានសួរថាមន្ទីរសន្តិសុខត្រាចក្រោលនេះ មានស្ថិតនៅក្នុងដីកាស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតដែរឬទេ? ខ្ញុំគិតថា ដើមបណ្ដឹងរដ្ឋប្បវេណីនេះ មិនអាចដឹងអំពីខ្លឹមសារនៃដីកាចាត់ពីវិសាលភាពនៃការស៊ើបអង្កេតទេ។ ដូច្នេះសំណួរនេះ មិនគួរសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីទេ។ អ៊ីចឹង ខ្ញុំសូមជំទាស់។

[១១:២៥:៤១]

**លោក គង់ សំអុន៖**

ខ្ញុំសូមឆ្លើយតបដោយខ្លី លោកប្រធាន ដោយសារដើមបណ្ដឹងរដ្ឋប្បវេណី គឺជាភាគីម្នាក់នៅក្នុងសំណុំរឿង០០២នេះ។ ដូច្នេះការតាំងសំណួរនេះ វាសមស្របបំផុតហើយ ពីព្រោះលោក គឺជាអ្នកដែលតាំងខ្លួនថាជាដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះបើថារឿងហ្នឹងវាទាក់ទងទៅនឹងខ្លួន ឬអត់នោះ មិនដឹងអានេះ ខ្ញុំសូមឲ្យលោកប្រធានពិចារណាចុះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះអាចសួរបាន។ បដិសេធសេចក្ដីជំទាស់ ហើយដើមបណ្ដឹងរដ្ឋប្បវេណីអាចឆ្លើយតបនឹងសំណួរបើសិនជាលោកយល់ដឹង ហើយបើមិនយល់ដឹងទេ គឺលោកឆ្លើយតាមដំណើររឿងណា។

**លោក ម៉ី ពៅ៖**

**ឆ៖** បាទ អរគុណ។ ខ្ញុំអត់បានដឹងដែរ។ ខ្ញុំអត់បានដឹងទេ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ឥឡូវបើខ្ញុំបញ្ជាក់ជូនលោកថា នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតនៃសំណុំរឿង០០២នេះ មិនមានចែងអំពីមន្ទីរសន្តិសុខត្រាចក្រោលនេះទេ។ តើលោកមានប្រតិកម្មឆ្លើយតបយ៉ាងម៉េចដែរ ចំពោះអ្វីដែលជាការរកឃើញរបស់ខាងក្រុមយើង?

**ឆ៖** អរគុណ។ ពីព្រោះអ្នកដែលនៅក្បែរហ្នឹង ក៏គាត់ទទួលស្គាល់ថា មន្ទីរត្រាចក្រោលកាលពី

សម័យរបបខ្មែរក្រហមដែរ។ ខ្ញុំអត់មានប្រតិកម្មអីទេ ក៏ប៉ុន្តែមានសាក្សី មានកន្លែងហើយស្រាប់។

[១១:២៧:២៧]

**ស៖** បើខ្ញុំជម្រាបជូនលោកមុននេះៗ គឺមិនមែនទាក់ទងទៅនឹងការបដិសេធចំពោះសក្ខីកម្មរបស់លោកដែលថា មន្ទីរត្រាចក្រោលជាមន្ទីរសន្តិសុខទេ។ ក៏ប៉ុន្តែខ្ញុំចង់បញ្ជាក់ជូនលោកថា មន្ទីរត្រាចក្រោលនេះមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២នេះតែម្តង ហើយពីព្រោះវាអត់មាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតនៃសំណុំរឿងនេះ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ពីផលប៉ះពាល់របស់លោកដែលខ្ញុំមើលពិនិត្យឃើញថា វាមិនជាប់ទាក់ទងទៅនឹងសាច់រឿងរបស់លោកនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលស្ថិតនៅក្នុងដើម គេហៅថា មន្ទីរសន្តិសុខត្រាចក្រោលនេះ។ លោកមានប្រតិកម្មអីទេ?

**ប្រធានអង្គជំនុំ៖**

នោះជាកិច្ចការផ្លូវច្បាប់ដែលវាស៊ីជម្រៅ មិនអាចគប្បីធ្វើដូច្នោះទេ។ បើលោកចង់ជំទាស់ជំទាស់តាំងពីដើមទី នូវសំណួរ និងចម្លើយសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីគ្រប់ទីកន្លែងទាំងអស់ដែលបានដាក់ពាក្យប្តឹង ហើយបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតរួចហើយនោះ គឺកំណត់ថា ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ អាចសួរបាន។

បញ្ហាទី២ ចំពោះអង្គហេតុដែលមានការពាក់ព័ន្ធ គឺសួរដើម្បីផ្ទៀតផ្ទាត់អំពីការអនុវត្តគោលនយោបាយទូទៅអំពីការប្រព្រឹត្តរបស់កម្ពុជាប្រជាធិបតេយ្យចំពោះជនជាតិចាម ជាពិសេសដែលពាក់ព័ន្ធជាមួយនឹងគោលនយោបាយទូទៅប៉ុណ្ណោះ។ នេះជាអង្គហេតុដែលអង្គជំនុំជម្រះបានស្តាប់សេចក្តីទុក្ខសោកវេទនា និងស្តាប់អំពីការផ្តល់សក្ខីកម្មមួយចំនួនពាក់ព័ន្ធនឹងការសួរដោយភាគីសហព្រះរាជអាជ្ញារងអន្តរជាតិ។ ដូច្នេះ មិនមែនជាកាតព្វកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការឆ្លើយតបនឹងសំណួរលោកបែបនេះទេ។

[១១:២៩:២៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយជាចុងក្រោយនេះ យ៉ាងម៉េចទៅលោកដើមបណ្ដឹងរដ្ឋប្បវេណី ម៉ើ ពៅ យើងបានទទួលព័ត៌មានមួយថា លោកមានបំណងតាំងសំណួរទៅចំពោះជនជាប់ចោទ។ បើសិនលោកមានបំណងលោកអាចធ្វើបាន នូវសេចក្ដីថ្លែងរៀបរាប់ចុងក្រោយ និងការតាំងសំណួរនេះ។ ហើយការតាំងសំណួរលោកត្រូវប្រុងប្រយ័ត្ន គប្បីធ្វើសំណួរហ្នឹងតាមរយៈយើងប្រធានអង្គជំនុំជម្រះ លោកមិនអាចធ្វើការតាំងសំណួរផ្ទាល់ទៅជនជាប់ចោទបានទេ។ អង្គជំនុំជម្រះអនុញ្ញាត បើសិនជាលោកមានបំណងធ្វើដូច្នេះ។

អត់ទាន់!

**លោក ម៉ើ ពៅ៖**

សូមគោរពលោកប្រធាន។ ខ្ញុំមានសំណួរពីរ។ ខ្ញុំចង់សួរជនជាប់ចោទ តើដូចម្ដេច តើធ្វើដូចម្ដេចបានជាគេធ្វើបាបជន -- បានជាជនជាប់ចោទធ្វើបាបជនជាតិចាមម្ល៉េះ? ហើយមូលហេតុអីបានជាគាត់បិទសាសនា? បាទ អរគុណ។

[១១:៣០:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបលោក ម៉ើ ពៅ ថាតាមបទប្បញ្ញត្តិនៃវិធាន២១ (១) ចំណុច(ឃ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា៖ “នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះត្រូវប្រាប់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរដល់ជនជាប់ចោទ។” ហើយនៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះសួរ ហើយសាក្សីបាន -- ជនជាប់ចោទទាំងពីរនាក់បានឆ្លើយបញ្ជាក់ពីការដែលពួកគាត់សុំរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរ។ សវនាការនៅពេលនោះ អង្គជំនុំជម្រះបានកំណត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់ នៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលព័ត៌មានជាក់លាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្ដីជនជាប់ចោទ។

នៅក្នុងសវនាការថ្ងៃនោះ អង្គជំនុំជម្រះក៏បានកំណត់ឱ្យជនជាប់ចោទ និង/ឬសហមេធាវីការពារក្ដីជនជាប់ចោទ ត្រូវមានការទទួលខុសត្រូវក្នុងការជូនដំណឹងមកអង្គជំនុំជម្រះឱ្យបានទាន់ពេល

វេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទសម្រេចចិត្តលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបទៅនឹងសំណួរដែលអង្គជំនុំជម្រះ ឬដោយភាគីពាក់ព័ន្ធទៅនឹងដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។

[១១:៣២:៣០]

រហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបនឹងសំណួរនៅឡើយទេ។ សូមលោកជ្រាប។ ហើយអង្គជំនុំជម្រះមិនអាចបង្ខំឲ្យជនជាប់ចោទឆ្លើយតបទៅនឹងសំណួរទេ ដរាបណាគាត់មិនយល់ព្រមឆ្លើយតប គាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយ គឺច្បាប់មិនចែងអំពីសិទ្ធិអំណាចរបស់អង្គជំនុំជម្រះបង្ខំឲ្យបុគ្គលជនជាប់ចោទឆ្លើយតបទៅនឹងសំណួរទេនេះនៅក្នុងកិច្ចនីតិវិធីព្រហ្មទណ្ឌ។

បាទ អង្គជំនុំជម្រះសូមអរគុណលោក ម៉ី ពៅ។ សវនាការស្តាប់សក្ខីកម្មរបស់លោក និងថ្លែងសេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មក្នុងឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណីដែលលោកអះអាងថា បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ បានដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ វត្តមានរបស់លោកនៅអ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ ហើយសូមលោកមានសុខភាពល្អ ទទួលជួបតែសំណាងល្អ បានសេចក្តីសុខសេចក្តីចម្រើន ហើយលោកអាចសម្រាកបានហើយ។

[១១:៣៣:៥៦]

ហើយអង្គជំនុំជម្រះអរគុណលោក លឹម ប៊ុនហួរ បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយគាំទ្រដល់អង្គជំនុំជម្រះ សម្រួលដំណើរការសវនាការស្តាប់ការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ ក្នុងរយៈពេលមួយព្រឹកនេះ។ ហើយអង្គជំនុំជម្រះក៏សូមបញ្ជាក់ថែមដែរថា លោក លឹម ប៊ុនហួរ បុគ្គលិកអង្គការធី.ភី.អូហ្នឹង ក៏ត្រូវនៅអង្គុយក្បែរដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-263 ដែលនឹងថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មនៅរសៀលនេះដែរ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នក

ជំនាញជូនលោក ម៉ី ពៅ វិលកាន់ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបថា នៅរសៀលនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-263។ បាទ សូមភាគីជ្រាប។ ហើយឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឱ្យមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ បង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-263 រួចទាំងបុគ្គលិកអង្គការ ធី.ភី.អូ ចូលមកកាន់កន្លែងថ្លែងរៀបរាប់ទុក្ខសោកវេទនានៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកឈ្មោះអី?

**លោក ម៉ាន ស្តេះ៖**

**ឆ៖** បាទខ្ញុំឈ្មោះ ម៉ាន ស្តេះ។

**ស៖** អរគុណលោក ម៉ាន ស្តេះ។ តើលោកកើតនៅថ្ងៃ ខែ ឆ្នាំណា លោកចាំដែរទេ?

**ផ៖** ខ្ញុំចាំតែឆ្នាំ ខែថ្ងៃ ខ្ញុំអត់ចាំ។ កើតនៅឆ្នាំ១៩៤៥។

**ស៖** បាទ អរគុណ។ ហើយទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ផ៖** នៅភូមិ៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។

[១៣:៣៤:៤៤]

**ស៖** សព្វថ្ងៃនេះ តើលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ផ៖** ខ្ញុំបាទមនុស្សចាស់ ធ្វើការអីអត់កើតទេ បានកូនជួយចិញ្ចឹម។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ផ៖** ឪពុកខ្ញុំឈ្មោះ តាំ ម៉ាន។ ម្ដាយឈ្មោះ សុះ ស្លាម៉ាស់។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ផ៖** ប្រពន្ធខ្ញុំឈ្មោះ ម៉ាត់ ខចះ។ មានកូនពីរនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបញ្ជាក់ដដែល គឺថាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គឺមានលោក ប៊ុន លឹម ហួរ បុគ្គលិកអង្គការ ធី.ភី.អូ អង្គុយនៅក្បែរ ដើម្បីជំនួយស្មារតីក្នុងការ ក្នុងអំឡុងពេលដែលគាត់ថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និង ស្ថានភាពព្យសនកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

លោក ម៉ាន ស្លេះ ក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនលោកដើម្បីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលកើតមានចំពោះលោកជាអាទិ៍ គឺខាងផ្លូវកាយ ផ្លូវចិត្ត និងសម្ភារៈដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យផ្ទាល់ពីបទឧក្រិដ្ឋដែលកើតមានឡើងពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅរឿងក្ដីនេះ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង ខៀវ សំផន ដែលលោកអះអាងថា ថាបានប៉ះពាល់ដោយផ្ទាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

[១៣:៣៧:០៤]

ហើយនៅក្នុងកិច្ចដំណើរការសវនាការនេះ ដោយអង្គជំនុំជម្រះបានទទួលយកនូវសំណូមពររបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសួរសំណួរ ធ្វើជាសំណួរក្នុងការសួរទៅ

ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដូច្នេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីសួរចំពោះដើមបណ្ដឹងរដ្ឋរូបនេះ អំពីស្ថានភាពព្យសនកម្ម និង ទុក្ខសោកវេទនារបស់គាត់ពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់ ជាពិសេសពាក់ព័ន្ធនឹងការប្រព្រឹត្តក្រុមគោលដៅជាក់លាក់ចំពោះជនជាតិចាម។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធានសាជាថ្មី សូមលោកប្រធានអនុញ្ញាតឲ្យលោក គឹម ម៉េងឃី ជាអ្នកសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ហើយលោក ម៉េងឃី គឺជាមេធាវីផ្ទាល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោក ម៉េងឃី!

[១៣:៣៨:០៥]

**លោក គឹម ម៉េងឃី៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក គឹម ម៉េងឃី៖**

**ស៖** ខ្ញុំបាទ គឹម ម៉េងឃី ជាមេធាវីតំណាងឲ្យលោកអ៊ំ ម៉ាន ស្លេះ សូមតាំងសំណួរមួយចំនួនទាក់ទងទៅនឹងទុក្ខសោកវេទនារបស់ជនជាតិចាមនៅក្នុងសំណុំរឿងនេះ។ ក៏ប៉ុន្តែមុននឹងតាំងសំណួរទៅខ្ញុំសូមបញ្ជាក់ជាមួយលោកអ៊ំបន្តិច ដោយសារថា កាលដែលយើងជួបគ្នាមុនហ្នឹងបន្តិចលោកអ៊ំថា មានបញ្ហាឈឺក្នុងពោះ ក៏ប៉ុន្តែសួរថា តើបញ្ហាឈឺហ្នឹងអាចធ្វើឲ្យប៉ះពាល់ដល់ចម្លើយរបស់លោកអ៊ំនៅក្នុងសវនាការដែរឬទេ? សូមលោកអ៊ំបញ្ជាក់កន្លែងហ្នឹង។

**លោក ម៉ាន ស្លេះ៖**

**ឆ៖** អរគុណ។ ខ្ញុំអាចទ្រាំទ្របាន ព្រោះខ្ញុំចង់ធ្វើសក្ខីកម្មជម្រាបដល់អង្គតុលាការអំពីរឿងរ៉ាវដែលខ្មែរក្រហមបានបង្កើតឡើង។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ដូច្នេះខ្ញុំសូមតាំងសំណួរខ្លីៗ ហើយសូមលោកអ៊ំផ្ដង់អារម្មណ៍នៅក្នុងការឆ្លើយ ដើម្បីឲ្យបានច្បាស់ទាក់ទងទៅនឹងចំណុចនេះ។ សំណួរទី១ ខ្ញុំសូមសួរលោកអ៊ំថា តើ

នៅក្នុងហេតុការណ៍ជាសោកនាដកម្មដែលកើតឡើងចំពោះជនជាតិចាម នៅក្នុងភូមិ៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាមហ្នឹង នៅក្នុងអំឡុងឆ្នាំ១៩៧៥ ហ្នឹងមានអ្វីខ្លះ?

[១៣:៤០:០៦]

**ឆ៖** សូមអរគុណ។ បន្ទាប់ពីហ្នឹងពួកខ្មែរក្រហមបានចូលមកដល់ភូមិខ្ញុំ សហការជាមួយប្រធានភូមិ បានប្រជុំហាមប្រាមមិនឲ្យជនជាតិខ្ញុំ ខាងមីងៗឲ្យកាត់សក់ កាត់សក់ខ្លី ទី១។ ទី២ មិនឲ្យសំពះយ៉ាំង។ ទី៣ មិនឲ្យឡើងលើផ្ទះរើគម្ពីរគូរ៉អាន ដែលជាគម្ពីរសាសនាអ៊ីស្លាម។

**ស៖** ចុះមានចំណុចអ្វីផ្សេងៗទៀត ដែលជាទុក្ខសោកនាដកម្មដែលកើតឡើងចំពោះលោកអ៊ំផ្ទាល់នៅពេលនោះ ហើយនិងបងប្អូនជនជាតិចាមផ្សេងទៀត?

**ឆ៖** នៅពេលនោះពួកខ្មែរក្រហមបានរឹតបន្តឹង មិន -- ចាប់អ្នកថ្នាក់ដឹកនាំខាងសាសនា ដូចជាហាគីម ហាជី ភូឈ្នួយ តួនៗ នៅក្នុងនោះមានឪពុកខ្ញុំមួយផងដែរ។

**ស៖** ពាក់ព័ន្ធទៅនឹងការចាប់ចង ខ្ញុំផ្តោតសំខាន់ទៅលើការចាប់ចងរបស់ឪពុករបស់លោកអ៊ំ។ តើនៅពេលនោះ អ្វីខ្លះដែលលោកអ៊ំយល់ថា តើមានកំហុសអ្វី ហើយនិងប៉ះពាល់អ្វីខ្លះដល់ទាំងខ្លួនក្រុមគ្រួសារលោកអ៊ំផ្ទាល់ ផ្លូវចិត្តលោកអ៊ំផ្ទាល់ ទាក់ទងទៅនឹងការចាប់ចងឪពុកដែលជាសាច់ញាតិរបស់លោកអ៊ំនៅពេលនោះ?

**ឆ៖** នៅពេលនោះឪពុកខ្ញុំកំពុងតែធ្វើចម្ការនៅក្រោយភូមិ ស្រាប់តែខ្មែរក្រហមចាប់ចងស្លាបសេកដាក់រទេះសេះយកទៅសាលាស្រុក។ បន្ទាប់មកទៀតពួកខ្ញុំនិងម្តាយ និងប្អូនមានការសោកសង្រេងយំក្តុកក្តួលក្នុងចិត្ត តែយំនៅក្នុងពេលយប់ មិនឲ្យអ្នកជិតខាងដឹងឮ។

**ស៖** នៅពេលដែលការចាប់ខ្លួនឪពុករបស់លោកអ៊ំយកទៅឃុំ សម្រាប់ខ្លួនលោកអ៊ំផ្ទាល់ ហើយនិងក្រុមគ្រួសារគេយកទៅណាដែរ?

[១៣:៤៣:២៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាល់ទាន់!

**លោក ម៉ាន ស្លេះ៖**

**ឆ៖** នៅពេលនុ៎ងគេចាប់យកទៅសាលាស្រុក ហើយបាត់រហូតមិនដែលវិលមកទល់ឥឡូវសព្វថ្ងៃ។ ពួកខ្ញុំតែងតែនឹកដល់ពួកគាត់។ ពេលដែលគេធ្វើបុណ្យទាន គេតែងតែជួបជុំ ឯចំណែកគ្រួសារខ្ញុំ

បាត់បង់ឪពុកជាមេគ្រួសារធំ។

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** ក្រៅពីការចាប់ឃុំឪពុកលោកអ៊ំ តើមានការធ្វើទុក្ខបុកម្នេញអ្វីផ្សេងទៀតជាបន្តបន្ទាប់ដែរ ឬទេ នៅពេលនោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ម៉ាន ស្ទេះ៖**

**ឆ៖** នៅពេលនោះមានក្រុមយុវជនបានទូងស្គរ និងវ៉ៃប៉ោត វ៉ៃធុង ដើម្បីបះបោរតទល់នឹងពួកខ្មែរក្រហម។ ព្រោះអ្វី? ព្រោះថា យើងរស់ក៏រស់មិនបានសុខ ដើម្បីប្រឆាំងនឹងវា ដើម្បីស្លាប់ទៅក៏ដើម្បីសាសនាហ្នឹង។

[១៣:៤៥:១៩]

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** ចុះបើបន្ទាប់ពីធ្វើការបះបោរ តើការបះបោរហ្នឹងទទួលបាននូវការតបស្នង ឬក៏ការបង្ក្រាបយ៉ាងដូចម្ដេចដែរនៅពេលនោះ?

**ឆ៖** នៅពេលនោះ ខ្ញុំក៏បានចូលរួមកាន់កាំបិត ចូលរួមជាមួយគេដែរ គ្រាន់ខ្ញុំនៅជួរក្រោយ ឃើញអ្នកស្លាប់ជាច្រើនទាំងសងខាង តែពួកខ្មែរក្រហមបានស្លាប់តិចជាង ព្រោះអាវុធយើងខ្លី អាវុធគេវែង។ ហើយនៅពេលនុ៎ងបានតស៊ូបានមួយថ្ងៃមួយយប់ ពេលនុ៎ងបានទម្លាក់អាវុធចុះចាញ់ ឃើញមនុស្សស្លាប់ច្រើនពេក ចុះចាញ់ប្រគល់អាវុធ។ ពួកខ្មែរក្រហមបានកៀរពួកខ្ញុំយកទៅដាក់ក្នុងឡថ្នាំ ឯខាងស្រីៗ និងក្មេងតូចៗដាក់នៅវត្តដើមជ្រៃ។ នៅពេលនុ៎ងពួកខ្ញុំគេបង្អត់អាហារ មួយថ្ងៃគេឲ្យបបររាវតែមួយចានចង្កឹះ។ ភ្នែកស្ពេកស្លាំង ខ្ញុំតែងតែនឹកដល់គ្រួសារខ្ញុំដែលនៅឯវត្ត។ ពិបាកវេទនា ឬក៏យ៉ាងណា ឬក៏គេបង្អត់ដូចខ្ញុំដែរ ឬយ៉ាងណា ខ្ញុំពុំដឹង ព្រោះនៅឆ្ងាយពីគ្នា។

**ស៖** បាទ អរគុណលោកអ៊ំ។ លោកអ៊ំថាគេចាប់យកទៅដាក់នៅឡថ្នាំ តើលោកអ៊ំអាចរៀបរាប់បានទេ ថាតើគេដាក់ហ្នឹងយ៉ាងម៉េច ឲ្យមានការស្នាក់នៅស្រួលបួលទេ មានអនាម័យទេ ឬក៏ជាកន្លែងបិទជិតចង្អៀត ឬក៏ធំ? លោកអ៊ំអាចពន្យល់ឲ្យច្បាស់កន្លែងហ្នឹងបន្តិចទេ?

[១៣:៤៧:៥៣]

**ឆ៖** នៅកន្លែងឡូថ្នាំ មិនចង្អៀតប៉ុន្មានទេ តែគ្មានអនាម័យ សុទ្ធតែកម្ទេចថ្នាំ អាចម៍ឆ្អែរអាចម៍ឆ្មា នៅក្នុងនុំង។ ហើយនៅពេលនុំងពួកខ្មែរក្រហមបានកត់ប្រវត្តិរូបម្ដងមួយៗ មួយយប់មានពីរបីនាក់ តែទៅបាត់រហូត សំណាងល្អ ខ្ញុំគេអត់ហៅ។

**ស៖** បាទ អរគុណលោកអ៊ំ។ លោកអ៊ំថា គេហៅទៅកត់ប្រវត្តិរូប បន្ទាប់មកបាត់ខ្លួន។ តើហេតុការណ៍ហ្នឹងធ្វើឲ្យលោកអ៊ំស្រមៃគិតថា មានអ្វីនឹងកើតឡើងទាក់ទងទៅនឹងការកត់ប្រវត្តិរូបហ្នឹង នៅពេលនោះ?

**ឆ៖** អរគុណ។ ពេលដែលកត់ប្រវត្តិរូបហ្នឹង គេស្រាវជ្រាវតែមេ រកមេធំៗដែលបះបោរធ្វើបាតុកម្មហ្នឹង។ ដូចខ្ញុំនិយាយអម្បាញ់មិញ ខ្ញុំសំណាងល្អ គេមិនហៅ បានរស់រានមានជីវិតដល់សព្វថ្ងៃ។

**ស៖** ក៏ប៉ុន្តែនៅក្នុងស្ថានភាពនោះ លោកអ៊ំបានការព្រួយបារម្ភទេ ដែលគេថាគេនឹងហៅយើងយកទៅធ្វើប្រវត្តិរូបដូចអ្នកផ្សេងដែរនោះ?

**ឆ៖** នៅក្នុងពេលនុំងយើងនៅក្នុងអន្ទាក់ពួកវាហើយ តែខ្ញុំលែងគិតពីខ្លួនឯងហើយ អាណិតទៅដល់គ្រួសារដែលនៅវត្ត ហើយមានកូនខ្ចី៣ខែ។ ពេលនុំងខ្ញុំស្រក់ទឹកភ្នែក អាណិតពួកគាត់ ខ្លាចគេធ្វើបាបដូចពួកខ្ញុំដែរ បង្អត់អាហារដូចខ្ញុំ។

**ស៖** ហើយអារម្មណ៍ដែលលោកអ៊ំខ្លាចអំពីគ្រួសារហ្នឹង ពេលណាដែលៗចាប់ផ្ដើមបានធូរស្បើយវិញ នៅពេលណាដែរទៅ?

**ឆ៖** នៅពេលដែលធូរស្បើយវិញ នៅក្នុងរយៈពេល១០ថ្ងៃ ឬក៏១៥ថ្ងៃ គេឲ្យមកជួបជុំគ្នាវិញ។ នៅពេលហ្នឹងគេជម្លៀសទៅស្រុកៗស្ទឹងត្រង់ ភូមិសូភាស តែទៅបានតែបីនាក់ប្រពន្ធនិងកូន៣ខែ ឯម្ដាយខ្ញុំគេជម្លៀសទៅផ្សេង និងប្អូនខ្ញុំបីនាក់ទៀត នៅរកាខ្នុរ។ មិនឲ្យជួបជុំគ្នាទេ។

[១៣:៥១:៥៣]

**ស៖** លោកអ៊ំមានប្រសាសន៍ថា ពេលរាងធូរស្បើយបន្តិចពេលដែលៗចេញមកវិញហ្នឹង ក៏ប៉ុន្តែស្ថានភាពរាងកាយរបស់លោកអ៊ំ ហើយនិងក្រុមគ្រួសារលោកអ៊ំ តើលោកអ៊ំសង្កេតឃើញយ៉ាងម៉េចដែរ មានសភាពល្អ ឬក៏យ៉ាងម៉េច?

**ឆ៖** ដូចខ្ញុំបានជម្រាបអម្បាញ់មិញហ្នឹង ពេលនុំងខ្លួនខ្ញុំក៏ដូចជាប្រពន្ធនិងកូនខ្ញុំដែរ មានភ្នែកស្លេកស្លាំង ស្បែកដណ្ដប់ឆ្អឹង ឯកូនខ្ញុំក្បាលធំជាងខ្លួន។

**លោក ប៊ុន លឹមហួរ៖**

ដោះវ៉ែនតាចេញ។ បន្ធូរអារម្មណ៍។

**លោក ម៉ាន ស្តេះ៖**

**ឆ៖** នៅពេលហ្នឹងបានជម្លៀសខ្ញុំនៅភូមិស្វាសហ្នឹង ខាងស្រុកស្ទឹងត្រង់ហ្នឹង។ នៅពេលនុំង អង្គការនៅខាងហ្នឹងគេសួរខ្ញុំថា "យើងនៅពីដើមធ្លាប់ធ្វើអី? ខ្ញុំថា ខ្ញុំមិនធ្វើអីទេ ខ្ញុំជាអ្នកនេសាទរកត្រី"។ ឯប្រពន្ធនិងកូនខ្ញុំ ប្រពន្ធខ្ញុំគេឲ្យទៅធ្វើស្រែ ដកស្ទូងដូចអ្នកដទៃដែរ។ ឯកូនខ្ញុំ៣ខែដាក់ការដ្ឋានខាងយាយៗគាត់មើល។

[១៣:៥៤:០២]

**លោក គីម ម៉េងឃី៖**

**ស៖** ពេលដែលលោកអ៊ំបានទៅធ្វើការនៅខាងស្រុកស្ទឹងត្រង់ហ្នឹង លោកអ៊ំមានទំនាក់ទំនងបានមានសិទ្ធិអាចទំនាក់ទំនងជាមួយប្រពន្ធកូន ហើយនិងអាចមកមើលកូន ឬក៏មកលេងប្រពន្ធជាទៀងទាត់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

ស្តាប់សំណួរសិនទៅ! បង្អង់បន្តិចទៅ ស្តាប់ត្រៀមខ្លួន ត្រៀមពាក្យពេចន៍ ដើម្បីឆ្លើយតបឲ្យបានត្រឹមត្រូវ។

**លោក ប៊ុន លឹមហួរ៖**

ចាំសំណួរទេ?

**លោក ម៉ាន ស្តេះ៖**

**ឆ៖** ចាំ។ ពេលដែលគេឲ្យខ្ញុំទៅនៅនេសាទ ខាងដងទន្លេមេគង្គយើងហ្នឹង ហើយនៅពេលហ្នឹងគេឲ្យជួបមួយឆ្នាំ ម្តងឬពីរដងយ៉ាងច្រើន ពីរដង។ ហើយក្នុងពេលជួបហ្នឹង ជួបតែពេលយប់ទេ កូនក៏អត់ដែលជួបដែរ ជួបតែពេលយប់ ពីព្រោះអីប្រពន្ធខ្ញុំគាត់ទៅធ្វើការពីព្រលឹមទល់ព្រលប់ ជួបតែពេលយប់ទេ។ ហើយគាត់ក៏ស្គមស្គាំងដូចខ្ញុំដែរ មើលមិនយល់ថា មនុស្សឈឺ។ ឯកូនខ្ញុំដូចខ្ញុំមានប្រសាសន៍អំមិញហ្នឹង ធំតែក្បាលទេ ធំជាងខ្លួនក្បាល។

[១៣:៥៥:៥៧]

**សួរដោយលោក គឹម ម៉េងឃី៖**

**ស៖** បាទ អរគុណលោកអ៊ំ។ ទាក់ទងទៅនឹងលោកអ៊ំថា មួយឆ្នាំជួបម្តង ហើយជួបពេលយប់ ពេលអីហ្នឹង ពេលដែលលោកអ៊ំជួបហ្នឹង លោកអ៊ំមានការបារម្ភភ័យខ្លាច ឬក៏យ៉ាងម៉េច? លោកអ៊ំគិតយ៉ាងម៉េចដែរចំពោះអនាគតនៅពេលនោះ?

**ឆ៖** នៅពេល--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដែលលោកមេធាវីបានឲ្យដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយអំពីអ្វីដែលជាការគិតរបស់គាត់នៅក្នុងអតីតកាល អំពីអនាគតនៅក្នុងអតីតកាល។ ហើយដែលយើងនិយាយទីនេះ គឺនិយាយអំពីផលប៉ះពាល់ដោយផ្ទាល់របស់កាត់ជាជាងនិយាយអំពីអ្វីដែលជាការគិតនេះបាទ។ សូមអរគុណ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សំណួរដែលសួរដោយលោក ម៉េងឃី មិនមានបញ្ហាទេ ហើយវាចង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយអំពីទិដ្ឋភាពផ្នែកមនោសញ្ចេតនា ផ្នែកនៃជាទិដ្ឋភាពនៃការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ការព្រួយបារម្ភរបស់គាត់។ ដូច្នេះវាចូលទៅនឹងអ្វីដែលជាគោលបំណងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនាថ្ងៃនេះ។ សូមលោកប្រធានអនុញ្ញាត។

[១៣:៥៧:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់នេះ។ លោក ម៉េងឃី រៀបចំសំណួររបស់លោកសាជាថ្មីម្តងទៀត។

**សួរដោយលោក គឹម ម៉េងឃី៖**

បាទ សូមអរគុណលោកប្រធាន។

**ស៖** សំណួរពាក់ព័ន្ធទៅនឹងថា ក្តីកង្វល់របស់លោកអ៊ំអំពីជោគវាសនាទៅ មិនមែនមកដល់

បច្ចុប្បន្នទេ គឺជោគវាសនានៅពេលនោះ ពេលដែលជួបកូន ប្រពន្ធហើយហ្នឹងនៅក្នុងលក្ខណៈមួយ ប្រចុចញ៉ុច តើលោកអ៊ំនឹងយល់ថា តើខ្លួនអាចមានឱកាសនឹងជួបលើកទី២ ឬក៏អី? នេះគឺជាគោលបំណងដែលខ្ញុំចង់ឲ្យលោកអ៊ំបញ្ជាក់ ថាតើអារម្មណ៍លោកអ៊ំយ៉ាងម៉េចដែរ អំពីជោគវាសនារបស់លោកអ៊ំពេលដែលបានជួបជុំគ្រួសារនៅក្នុងលក្ខណៈត្បិតត្បៀតបែបនេះ?

**លោក ម៉ាន ស្លេះ៖**

**ឆ៖** នៅក្នុងអារម្មណ៍របស់ខ្ញុំ ខ្ញុំនឹកស្មានថា គង់តែស្លាប់ទេ ប៉ុន្តែមិនដឹងជាថ្ងៃណា ព្រោះគេធ្វើបាបយើងខ្លាំងណាស់ មិនឲ្យយើងហូបឆ្អែត មិនឲ្យយើងគោរពសាសនាយើង។

**ស៖** បាទ អរគុណលោកអ៊ំ។ លោកអ៊ំ ខ្ញុំសូមសួរបន្តទៀតអំពីលក្ខខណ្ឌនៃការងារដែលគេដាក់បន្ទុកឲ្យលោកអ៊ំទទួលខុសត្រូវនៅក្នុងសម័យនោះ។ តើសម្ពាធនៃការងារហ្នឹងមានលក្ខណៈយ៉ាងដូចម្ដេច ធូរស្រាល ឬក៏តឹងរ៉ឹងចំពោះលោកអ៊ំ ឬក៏ជាមួយអ្នកផ្សេងទៀត ដែលធ្វើការដូចលោកអ៊ំនោះ?

[១៤:០០:០១]

**ឆ៖** នៅពេលកំពុងធ្វើនេសាទជាមួយគ្នា មានគ្នាបួននាក់ទូកមួយ។ តែខាងជនជាតិចាម មានបីនាក់ មានពួកខ្មែរក្រហមនៅលើទូកម្នាក់ គាត់ជាអ្នកមើលការខុសត្រូវលើយើងឲ្យយើងខំប្រឹងរកត្រីឲ្យបានច្រើនយកទៅដាក់រោងបាយ។ ហើយរកទាំងថ្ងៃទាំងយប់ សម្រាកបានតែមួយម៉ោងទេ ជិតភ្លឺទៅរកទៀត។ ថ្ងៃអត់មានសម្រាកទេ សម្រាកតែពេលយប់យ៉ាងច្រើនមួយម៉ោង ឬមួយម៉ោងកន្លះ ទើបឲ្យរកទៀត។

**ស៖** អរគុណលោកអ៊ំ។ ខ្ញុំដូចមិនទាន់ជាក់លាក់ សុំលម្អិតបន្តិច។ លោកអ៊ំថា សម្រាកមួយម៉ោង ឬមួយម៉ោងកន្លះហ្នឹង បានន័យថាម៉េច? បានន័យថាលោកអ៊ំចុះទៅនេសាទហើយ ត្រឡប់មកវិញគេឲ្យលោកអ៊ំសម្រាកមួយម៉ោង ហើយចាំចុះទៅវិញ ឬក៏ការសម្រាកដោយអត់ធ្វើអីនៅលើផ្ទៃទឹកហ្នឹង ឬក៏យ៉ាងម៉េចលោកអ៊ំអាចបញ្ជាក់? លោកអ៊ំ សុំចាំបន្តិច។

**ឆ៖** ពេលដែលសម្រាកហ្នឹង មិនមែនសម្រាកលើផ្ទះទេ សម្រាកលើទូកហ្នឹង។ ហើយមួយម៉ោងទៅមួយម៉ោងកន្លះ ម៉ោងពីរចាប់ផ្ដើមរកទល់ភ្លឺ។ ទល់តែពេលបាយ ស៊ីបាយរួច ហូបបាយរួច ត្រូវរកទៀត ជារៀងរាល់ថ្ងៃ។

**ស៖** ខ្ញុំសូមបញ្ជាក់កន្លែងទទួលទានបាយ តើគេឲ្យលោកអ៊ំហូបគ្រប់គ្រាន់ទេ? រកបានត្រី ឬក៏រកបាន ដែលនេសាទបានមកហ្នឹង តើគេឲ្យយើងបរិភោគរបស់អស់ហ្នឹងដែរឬទេ?

**ឆ៖** ពេលដែលរកត្រីបាន ពួកគាត់ ពួកខ្មែរក្រហមឲ្យយើងហូប គ្នាប្អូននាក់ ត្រីតែប្អូនដែរ ត្រីប៉ុនៗមេជើង ឬក៏ធំជាងហ្នឹងបន្តិច។ គ្នាប្អូននាក់ ត្រីប្អូនដែរ។

[១៤:០៣:១៤]

**ស៖** បាទ អរគុណលោកអ៊ំ។ លោកអ៊ំ ខ្ញុំសូមឈានទៅប្រធានបទមួយទៀត ពាក់ព័ន្ធទៅនឹងការដែលលោកអ៊ំបានជួបសាច់ញាតិរបស់លោកអ៊ំ ពេលដែលលោកអ៊ំទៅម្តងៗហ្នឹង។ តើពេលនោះលោកអ៊ំមានទទួលបានដំណឹងអ្វីដែលធ្វើឲ្យមានអារម្មណ៍ភ័យរន្ធត់ ឬក៏ពាក់ព័ន្ធទៅនឹងរឿងហេតុណាមួយពីក្រុមគ្រួសារលោកអ៊ំដែរឬទេ ពេលនោះ?

**ឆ៖** នៅពេលនោះមងរហែក គេចាត់តាំងឲ្យខ្ញុំទៅរកខ្សែមកជួសមងសំណាញ់ហ្នឹង។ នៅពេលនោះខ្ញុំមានឱកាសលួចទៅជួបម្តាយខ្ញុំនិងប្អូនខ្ញុំ។ នៅពេលនោះប្អូនខ្ញុំបីនាក់ គេបញ្ជូនទៅការដ្ឋានអស់ នៅតែម្តាយធ្វើខាង នៅធ្វើការក្បែរៗផ្ទះ។ នៅពេលនោះខ្ញុំបានជួបគាត់បានតែមួយភ្លែតទេ មិនហ៊ាននៅយូរខ្លាចគេតាមដានឃើញ។ បន្ទាប់មកទៀតនៅថ្ងៃក្រោយមងរហែក គេឲ្យខ្ញុំទៅរកខ្សែមកជួសសំណាញ់ ខ្ញុំបានទៅដល់ អត់ឃើញពួកគាត់ខ្ញុំសួរអ្នកភូមិថា ពួកគាត់ គេយកទៅសម្លាប់ចោលអស់ហើយ ម្តាយនិងប្អូនបីនាក់។

**ស៖** តើក្តីបារម្ភអ្វីដែលខ្លះបានដែលកើតមានចំពោះលោកអ៊ំ បន្ទាប់ពីបានដំណឹងថាសាច់ញាតិហ្នឹងត្រូវបានបាត់ខ្លួន ឬក៏ត្រូវបានសម្លាប់ហ្នឹង? សូមលោកអ៊ំបញ្ជាក់កន្លែងហ្នឹង?

**ឆ៖** ទី១ បាត់បង់ឪពុកមុនគេ បន្ទាប់មកបាត់ម្តាយ និងប្អូន សរុបទាំងអស់ប្រាំនាក់ ហើយមានទុក្ខសោករឹតតែខ្លាំងជាងមុនទៀត។ នៅពេលនុ៎ង នៅពេលដែលហ្នឹងខ្ញុំមកកន្លែងនេសាទវិញ ខ្ញុំបានយំ។ អ្នកដែលធ្វើការជាមួយខ្ញុំ គាត់បានសួរថាហេតុអីបានយំ ថាឈឺពោះ។ ខ្ញុំបានលាក់ការណ៍ថាឈឺពោះ។ ខ្ញុំយំដូចកូនក្មេង។

**ស៖** បាទ អរគុណលោកអ៊ំ។ លោកអ៊ំរៀបរាប់អំពីឪពុកម្តាយបងប្អូន ដែលត្រូវបានគេយកសម្លាប់ ហើយចុះចំពោះប្រពន្ធ ហើយនិងកូន តើគេធ្វើទុក្ខបុកម្នេញលើគាត់យ៉ាងម៉េចដែរ នៅពេលដែលលោកអ៊ំមិននៅជាមួយគាត់ហ្នឹង? អ្វីដែលសូមរៀបរាប់នូវអ្វីដែលលោកអ៊ំបានដំណឹងដឹងពីគាត់ គាត់ប្រាប់លោកអ៊ំថាយ៉ាងម៉េចដែរ?

[១៤:០៧:៤៣]

**ឆ៖** នៅពេលដែលខ្ញុំទៅជួបម្តាយខ្ញុំជាលើកមុនដំបូង គាត់បាននិយាយប្រាប់ខ្ញុំថា ប្អូនៗទៅ

ការដ្ឋានអស់ហើយ ស្គមស្គាំងទុកកូនឯងមកជួបប្អូន ក៏មើលមិនស្គាល់ដែរ នោះជាលើកទី១។ ឯលើកទី ២ ទៅអត់ជួប នៅពេលនោះហើយ ដែលខ្ញុំត្រឡប់មករកខ្សែជួសសំណាញ់មង។ នៅពេលនុ៎ង ខ្ញុំមកដល់ ខ្ញុំយំដូចកូនក្មេង។ តែពួកដែលធ្លាប់ធ្វើការជាមួយខ្ញុំ ប្រធានខ្ញុំអី ខ្ញុំភ្ញួតគាត់ថា ខ្ញុំចុកពោះ។

**លោក គីម ម៉េងឃី៖**

បាទ អរគុណលោកអ៊ំ។ ខ្ញុំសូមសំណួរបន្ត ខ្ញុំសូមទុកឲ្យលោកមេធាវី ពេជ អង្គ សហមេធាវីនាំមុខ គាត់បន្ថែមបន្តិចទៀត។ ខ្ញុំសូមអស់ប៉ុណ្ណេះបាទ សូមអរគុណ។

**លោក ពេជ អង្គ៖**

សូមគោរពអនុញ្ញាតលោកប្រធាន ដើម្បីបន្តសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ខ្ញុំសូមជម្រាបសួរលោកអ៊ំ ម៉ាន ស្លេះ ខ្ញុំសួរមានសំណួរខ្លីបន្ថែម បំពេញបន្ថែមបន្តិចទៅលើអ្វីដែលលោក គីម ម៉េងឃី បានសួរទៅលោកអ៊ំ។ ហើយខ្ញុំចង់បានព័ត៌មានបញ្ជាក់បន្ថែម។ លោកអ៊ំអាចបញ្ជាក់បានទេ សម្រាប់លោកអ៊ំជាអ្នកកាន់សាសនាអ៊ីស្លាម ថាតើសាសនាហ្នឹងមានសារៈសំខាន់យ៉ាងណាសម្រាប់អ៊ំដែលជាអ្នកកាន់សាសនានោះ ហើយក៏ដូចជាជនជាតិចាមផ្សេងទៀត? សូមអញ្ជើញលោកអ៊ំឆ្លើយ។

[១៤:០៩:៥៤]

**លោក ម៉ាន ស្លេះ៖**

**ឆ៖** សាសនាអ៊ីស្លាម គេគោរពសំពះយ៉ាំងមួយថ្ងៃមួយ យប់ប្រាំដង។ ហើយគោរពយ៉ាងខ្ជាប់ខ្ជួន មិនដែលខកខាន។ ទោះជាមានការរវល់យ៉ាងម៉េចនៅពេលនោះ ថ្ងៃក្រោយយើងនឹង ដល់ពេលសំយ៉ាំងហួសម៉ោង យើងអាចសំយ៉ាំងសងវិញបាន នេះជាប្រពៃណីសាសនាអ៊ីស្លាម។ កាលណាយើងអត់បានគោរពសាសនា នឹងបាបធ្លាក់នរក។

**ស៖** មុនហ្នឹងលោកអ៊ំបានឆ្លើយទៅលោកមេធាវីដើមបណ្តឹង -- លោកមេធាវី គីម ម៉េងឃី ថាលោកអ៊ំ មិនបានប្រតិបត្តិសាសនាអ៊ីស្លាមទេនៅចាប់ពីឆ្នាំ១៩៧៥មក ឬក៏មុននេះ។ អ៊ីចឹងនៅពេលដែលលោកអ៊ំមិនបានប្រតិបត្តិសាសនាអ៊ីស្លាមហ្នឹង ថាតើផ្នែកមនោសញ្ចេតនា ទិដ្ឋភាពផ្លូវចិត្តរបស់អ៊ំមានអារម្មណ៍យ៉ាងម៉េចដែរនៅពេលនោះ?

**ឆ៖** នៅពេលហ្នឹងដូចខ្ញុំនិយាយត្រឡប់មកក្រោយបន្តិច ដោយសារអត់មានសាសនាហ្នឹងហើយ

ទើបពួកជនជាតិចាមនៅសហគមខ្ញុំងើបបះបោរ ដើម្បីសាសនាហ្នឹងហើយ ប្ដូរស្លាប់ ប្ដូររស់ ដើម្បីសាសនា។

**ស៖** ហើយនាពេលនោះ ថាតើលោកអ៊ំមានបានប្រតិបត្តិ មានបានលួចប្រតិបត្តិសាសនាហ្នឹងខ្លះដែរឬទេ ជាកំបាំងនោះ ឬក៏ជាយ៉ាងម៉េច លោកអ៊ំអាចបញ្ជាក់រឿងហ្នឹងបានទេ?

**ឆ៖** នៅពេលហ្នឹង ខ្ញុំលួចម្ដងម្កាលដែរ នៅពេលយប់ស្ងាត់បានប៉ាានលួច ខ្លាចឈ្លបគេតាមដានឃើញ អត់ប៉ាានធ្វើនៅពេលថ្ងៃទេ។

[១៤:១២:៣៥]

**ស៖** តើលោកអ៊ំមានប្រសាសន៍អម្បាញ់មិញខ្លាចឈ្លប តើលោកអ៊ំមានដែលឃើញឈ្លបដើរទៅលបមើល លបតាមដានដែរទេ?

**ឆ៖** ខ្ញុំបាទដែលឃើញគាត់ដើរតាមផ្លូវ ប៉ុន្តែមិនដឹងគាត់ទៅតាមដានក្រោមផ្ទះគេយ៉ាងណាខ្ញុំមិនដឹងដែរ។

**ស៖** បាទ អ៊ីចឹងអរគុណលោកអ៊ំ។ ចុះពីបញ្ហាភាសាវិញ នៅពេលនោះ ថាតើលោកអ៊ំអាចនិយាយភាសាចាមដែលជាភាសាកំណើតរបស់អ៊ំបានដោយសេរីដែរឬទេ?

**ឆ៖** ចាប់ពីពេលហ្នឹងមក ពួកខ្ញុំលែងប៉ាាននិយាយ ទាល់តែអត់ឃើញពួកវាទើបប៉ាាននិយាយស្ងាត់ៗ។

**ស៖** បាទ អរគុណលោកអ៊ំ។ ចំពោះរឿងចំណីអាហារវិញ ថាតើគេមានធ្លាប់តម្រូវឱ្យអ៊ំបរិភោគអ្វីដែលជាធម្មតាអ៊ំមិនបរិភោគដែរឬទេ អ៊ំអាចនិយាយអំពីបញ្ហានេះបានទេ? ហើយបើសិនបើថាមាន នៅកន្លែងណាអ៊ំ?

**ឆ៖** នៅពេលនុ៎ងសាច់ជ្រូកចាមតមមិនឱ្យស៊ីទេ ក៏ប៉ុន្តែគេធ្វើបុណ្យ គេអត់មានធ្វើអី អត់មានបបរដាក់គ្រឿងក្រៅដូចសព្វដងទេ គេដាក់សាច់ជ្រូក សុទ្ធតែខ្លាញ់ឱ្យយើងហូប។ ខ្លះមក គេចែកបបរឱ្យហើយ យកទៅច្របាច់យកទឹកហ្នឹងចេញ ហើយរម្ងាស់ៗហើយរម្ងាស់ទៀត យកទឹកចេញ នៅតែធុំសាច់ជ្រូកដដែល។ អ្នកខ្លះហូបបាន អ្នកខ្លះហូបមិនបាន ឯចំណែកខ្ញុំៗខ្លាចស្លាប់ ខ្ញុំហុតតែទឹកៗ។

[១៤:១៥:០៨]

**ស៖** បាទ អរគុណលោកអ៊ំ។ ហើយខ្ញុំចង់សួរអំពីការរស់នៅរបស់គ្រួសាររបស់លោកអ៊ំនៅសំភាស។ អ៊ីចឹងថាតើនៅសំភាសនោះមានអ្វីកើតឡើងចំពោះគ្រួសារអ៊ំជាចាម ឬក៏ថាអ្នកដែលជាចាម

ផ្សេងៗទៀតដែរឬទេ នៅសំភាសហ្នឹង?

**ឆ៖** ចំពោះរូបខ្ញុំគ្រាន់តែគេបំបែកមិនឲ្យជួបគ្នាតែប៉ុណ្ណោះ។ ឯធ្វើការបាក់កម្លាំងមិនឲ្យហូបឆ្អែត ហើយប្រពន្ធខ្ញុំ ដូចខ្ញុំនិយាយតាំងពីដើមមកថា មិនដែលឲ្យជួបនៅពេលថ្ងៃទេ។ ខ្ញុំទៅពេលថ្ងៃក៏មិនជួបដែរ ទាល់តែល្ងាចយប់បានមកជួបគ្នា ហើយកូនខ្ញុំក៏អីចឹងដែរ។ នៅពេលហ្នឹងហើយ ដែលខ្ញុំមានទឹកចិត្តចង់តែយំ ខ្ញុំអាណិតកូនប្រពន្ធខ្ញុំណាស់។

**ស៖** លោកអាច លោកអ៊ំបាននិយាយបានទេ កូនប្រពន្ធរបស់អ៊ំយ៉ាងម៉េចដែរ? ការរស់នៅរបស់គាត់យ៉ាងម៉េចដែរនៅសំភាសហ្នឹង?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាល់ទាន់!

**លោក ម៉ាន ស្អេះ៖**

**ឆ៖** គាត់ហូបដូចគេដូចឯង ប៉ុន្តែហូបមិនឆ្អែត តែឯអ្នកភូមិគាត់មានអង្ករលាក់ទុកនៅក្នុងផ្ទះគាត់ គាត់ដាំបាយស៊ីឆ្អែត ប្រពន្ធខ្ញុំអត់មានទេ។ គេចែករបបប៉ុនណា ហូបប៉ុណ្ណឹង ហើយមានបេះស្លឹកបាសស្លឹកអីលាយ ដូចជា ត្រកួនអីអីចឹង។

[១៤:១៧:៤១]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** តើលោកអ៊ំមានបានដឹងខ្លួនឯង ឬក៏ប្រពន្ធរបស់អ៊ំមានបានជម្រាបអ៊ំទេ អំពីថានៅសំភាសហ្នឹងមានចាមផ្សេងទៀត រស់នៅទីនោះដែរឬទេ? ហើយតើមានអ្វីកើតឡើងជាមួយនឹងពួកគាត់ដែរឬទេ?

**ឆ៖** នៅពេលដែលគេជម្លៀសទៅដល់ទ្នុង មានចាមស្រុកគេផ្សេងៗជម្លៀសនៅភូមិទ្នុងជាមួយឯនៅក្នុងភូមិខ្លួនឯងអត់មានទេ មានតែភូមិគេដទៃ ឲ្យទៅនៅកន្លែងសូភាស។

**ស៖** បាទ អរគុណលោកអ៊ំ។ ហើយខ្ញុំចង់សូមសួរលោកអ៊ំ ប្រហែលជាសំណួរចុងក្រោយរបស់ខ្ញុំហើយ។ នៅពេលដែលលោកអ៊ំបច្ចុប្បន្នរស់នៅស្វាយឃ្លាំង ហើយពេលណាដែលអ៊ំបានមករស់នៅស្វាយឃ្លាំងហ្នឹង? ហើយនៅពេលដែលអ៊ំបានមកដល់ស្វាយឃ្លាំង អ៊ំមានបានឃើញ ថាតើមានបងប្អូនរបស់អ៊ំ ឬក៏ចាមផ្សេងៗទៀត មានរស់នៅៗទីនោះ ត្រឡប់មកវិញច្រើនដែរឬទេ មករស់នៅស្វាយឃ្លាំងហ្នឹង?

**ឆ៖** ពេលដែលចប់សង្គ្រាមពួកខ្ញុំបានវិលមកស្រុកកំណើតវិញ នៅពេលនោះមានស្រុកគេជាច្រើនគ្រួសារបានមករស់នៅនឹងភូមិខ្ញុំខ្លះៗដែរ។ ឯអ្នកភូមិបាត់ប្រហែលដូចថា១០០គ្រួសារ នៅតែ៥០គ្រួសារទេ។ មានតែភូមិគេដទៃ គេមកនៅជាមួយ នៅភូមិស្វាយឃ្លាំងហ្នឹង។

**ស៖** អ៊ីចឹងអ៊ំដឹង មានដឹងទេថានៅមុន៧៥ ១៧ មេសា ១៩៧៥ហ្នឹង មានចាមរស់នៅច្រើនទេនៅស្វាយឃ្លាំងដែលអ៊ំរស់នៅហ្នឹង?

[១៤:២០:១១]

**ឆ៖** ចាមនៅស្វាយឃ្លាំងប្រហែលជា៨០០គ្រួសារទៅ១.០០០គ្រួសារយ៉ាងច្រើន។ ខ្ញុំមិនមែនអ្នកស្ថិតិទេ ប៉ុន្តែតាមស្មានសួរហាជី ហាក៏ម គេថាប្រហែលជិត១.០០០គ្រួសារ។

**ស៖** បាទ ខ្ញុំមកដល់សំណួរចុងក្រោយមែនទែនរបស់ខ្ញុំហើយ។ អ៊ំនិយាយអម្បាញ់មិញថាអ៊ំបានសួរហាជី ហាក៏ម ដែលជាអ្នកចាស់ទុំនៅក្នុងសាសនានៅស្វាយឃ្លាំងហ្នឹង។ តើពេលនោះពេលដែលអ៊ំមកដល់ហ្នឹង មានពួកគាត់គ្នាច្រើនទេអ៊ំ? មានតួន ឬក៏មានអ៊ីមុាំ គ្នាច្រើនទេ ដែលនៅសេសសល់នោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក ម៉ាន ស្លេះ៖**

**ឆ៖** នៅពេលដែលត្រឡប់មកវិញហ្នឹង គឺបាត់មនុស្សជាងពាក់កណ្ដាលហើយ ដែលចាស់ទុំធ្លាប់ពីដើមហ្នឹងស្លាប់អស់ហើយ។ ទើបមានបច្ចុប្បន្ននេះទេ ទើបមានអ្នកចេះដឹង គេទៅរៀនសាក្រោយហ្នឹង ធ្វើតួន ហាក៏ម បន្តពីអ្នកចាស់ៗជំនាន់មុន។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សហការីរបស់ខ្ញុំមានសំណួរមួយចុងក្រោយចង់ឲ្យខ្ញុំសួរទៅលោកអ៊ំ ថាតើចាប់ពី១៩៧៩ រហូតទៅដល់មានតួន មានអ៊ីមុាំ មានហាក៏មអីនៅក្នុងភូមិ នៅក្នុងឃុំរបស់អ៊ំហ្នឹង ចាប់ពីពេលនោះ មករហូតដល់ពេលណាបានចាប់ផ្ដើមមានអ្នកចេះដឹង ឬក៏ដឹកនាំនៅក្នុងសាសនាហ្នឹង?

[១៤:២២:៣៧]

**ឆ៖** ពេលដែលចប់របបខ្មែរក្រហម ចាស់ៗស្លាប់អស់ហើយ ក្មេងៗជំនាន់ក្រោយទៅរៀនបន្តនៅស្រុកក្រៅ ដូចប្រទេសអារ៉ាប់ សាអូឌីត នៅម៉ាឡេ អ្នកចេះដឹងបន្តវេនពីចាស់ៗជំនាន់នោះ។ មានជា

ច្រើន មានតួន មានអីបង្រៀនខាងសាសនាអ៊ីស្លាម មានបង្រៀនភាសាខ្មែរ ភាសាអង់គ្លេស ដូចខ្មែរជាតិដែរ។

**ស៖** ខ្ញុំចង់ដឹងថា តើឆ្នាំណាដែលពួកគាត់ មានពួកគាត់មកគ្នាច្រើនមកនៅក្នុងភូមិស្រុករបស់អ៊ំ ឆ្នាំណា?

**ឆ៖** ឆ្នាំ៨៩។

**លោក ពេជ អង្គ៖**

បាទ អ៊ីចឹងសុំអរគុណលោកអ៊ំចំពោះការឆ្លើយសំណួររបស់យើងខ្ញុំ។ សូមគោរពលោកប្រធាន សូមអរគុណចំពោះការផ្តល់ឱកាសដើម្បីសួរសំណួរនេះ។ យើងខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហ តំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បើសិនជាមាន។ សូមអញ្ជើញ!

[១៤:២៤:០៤]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ជម្រាបសួរលោក ម៉ាន ស្លេះ។ ខ្ញុំឈ្មោះ ត្រាវីស ហ្វារ ជាសហព្រះរាជអាជ្ញារងមកពីការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំមានសំណួរមួយចំនួន សួរទៅលោករសៀលនេះ។ លោកនិយាយអំពីការអនុវត្ត ប្រារព្ធសាសនាអ៊ីស្លាមនៅក្នុងរបបខ្មែរក្រហម។ តើលោកអាចជម្រាបជូនតុលាការបានទេថា ពេលនោះនៅស្វាយឃ្លាំងនោះ មានព្រះវិហារអ៊ីស្លាមហ្នឹងដែរទេ? ហើយបើមានហ្នឹង គេប្រើប្រាស់វាធ្វើអីដែរនៅក្នុងរបបខ្មែរក្រហមហ្នឹង?

**លោក ម៉ាន ស្លេះ៖**

**ឆ៖** បាទ សូមអរគុណ។ នៅពេលនោះព្រះវិហារហ្នឹងគេលែងឈប់សំយ៉ាំងហើយ ខ្មែរក្រហមមិនឱ្យសំយ៉ាំងទេ។ ដាក់គោ ដាក់ក្របី ឆ្នាំទឹកដែលលិចភូមិ គេយកគោ យកក្របីទៅដាក់។

**សៈ** សូមអរគុណចំពោះចម្លើយនេះ។ ខ្ញុំចូលទៅប្រធានបទមួយថ្មី ចូលនិយាយអំពីការចាប់ខ្លួនឪពុករបស់លោក ដែលលោកបានរៀបរាប់ខ្លះៗមកហើយ។ តើលោកអាចជម្រាបជូនតុលាការឲ្យបានលម្អិតបន្តិចដែរបានទេ ដំណើររឿងនៃការចាប់ខ្លួនឪពុករបស់លោកនេះ?

[១៤:២៥:៣៩]

**ឆៈ** ពេលដែលចាប់ហ្នឹង គាត់នៅទៅធ្វើការនៅក្រោយផ្ទះ ធ្វើដាំពោត ស្រាប់តែខ្មែរក្រហមចោទថាជាខ្មាំង។

**សៈ** ហើយនៅចម្ការពោតហ្នឹង នៅពេលដែលគេចាប់ឪពុករបស់លោកហ្នឹង តើគេមានចាប់អ្នកដទៃទៀត ទៅជាមួយនឹងឪពុករបស់លោកហ្នឹងដែរទេ?

**ឆៈ** បាទ មានចាប់ដែរ ចាប់ជាមួយគ្នាហ្នឹង ចាប់ប្រហែល៥០ទៅ៦០នាក់។ ប៉ុន្តែក្នុងនុំងគេដោះលែងអស់ នៅសល់តែប្រាំនាក់ ក្នុងនុំងមានឪពុកខ្ញុំមួយដែរ បួននាក់ហ្នឹងខ្ញុំអត់ស្គាល់ឈ្មោះ ប៉ុន្តែដឹងថាគាត់ជាអ្នកភូមិជាមួយខ្ញុំដែរ។

**សៈ** ហើយជាមួយនឹងក្រុមមនុស្សទាំង៥០នាក់ហ្នឹង ទាំងអស់ហ្នឹងគឺសុទ្ធតែជាចាម ឬក៏មានចាមផង ខ្មែរផង?

**ឆៈ** សូមអរគុណ។ សុទ្ធតែចាមទាំងអស់ អត់មានបងប្អូនខ្មែរទេ សុទ្ធតែចាម។

**សៈ** ខ្ញុំសូមសួរបញ្ជាក់អំពីពេលវេលា តើការចាប់ខ្លួននេះកើតឡើងនៅមុនពេលបះបោរនៅស្វាយឃ្លាំង ឬក៏កើតឡើងក្រោយពេលបះបោរនៅស្វាយឃ្លាំង?

**ឆៈ** សូមអរគុណ។ មុនបះបោរ។

**សៈ** ដូច្នេះនៅក្នុងមនុស្សមួយក្រុមទាំង៥០នាក់នេះ តើមានទាំងបុរស ទាំងស្ត្រី ឬក៏មានតែបុរស ឬក៏មានតែស្រីសុទ្ធ?

**ឆៈ** មានប្រុស មានស្រី មានក្មេង អាយុតាំងពី១៥ឡើងទៅ។ លាយឡំគ្នា មានប្រុស មានស្រី មានក្មេង។

[១៤:២៨:២២]

**សៈ** តើលោកអាចប៉ាន់ប្រមាណបានទេ ក្នុងចំណោមក្រុមមនុស្សទាំង៥០នាក់ហ្នឹង មានចាស់ប៉ុន្មាននាក់ មានក្មេងប៉ុន្មាននាក់?

**ឆៈ** មានក្មេងតិចជាងចាស់ មនុស្សចាស់ពេញកម្លាំងច្រើនជាងក្មេង។ ក្មេងគេហៅថា ក្មេង

ជំទង់ អាយុពី១៥។

**សៈ** តើលោកអាចជម្រាបជូនតុលាការបានទេ អ្នកណាជាអ្នកចាប់ខ្លួនមនុស្សទាំង៥០នាក់នេះ?

**ឆៈ** សូមអរគុណ។ អ្នកចាប់ខ្លួនហ្នឹង គេហៅថាខ្មែរក្រហម ព្រោះកាលហ្នឹងពាក់អាវខ្មៅ អត់មានស័ក្តិទេ។ ពាក់ខោអាវខ្មៅបង់ក្រមាដូចគ្នាៗ មិនដឹង គាត់ជាថ្នាក់ស័ក្តិប៉ុនណាទេ ដឹងថាខ្មែរក្រហម។

**សៈ** ចុះខ្លួនលោកផ្ទាល់នេះ ស្ថិតនៅក្នុងចំណោមមនុស្សដែលគេចាប់ខ្លួនទាំង៥០នាក់ហ្នឹងដែរឬក៏អត់ទេ?

**ឆៈ** មានខ្ញុំផងដែរ ប៉ុន្តែខ្ញុំបានដោះលែងមកវិញ។

**សៈ** តើលោកអាចជម្រាបជូនតុលាការបានទេ នៅពេលគេចាប់ខ្លួនដំបូងហ្នឹង គេចាប់នៅកន្លែងណា ហើយរហូតដល់ពេលភាគច្រើននៃមនុស្សនៅក្នុងក្រុមហ្នឹងត្រូវបានគេដោះលែង? ដំណើររឿងពីពេលចាប់ខ្លួន ចាប់នៅឯណា រហូតមកទល់ពេលដោះលែងមនុស្សភាគច្រើននោះ?

[១៤:៣០:២៤]

**ឆៈ** ពេលដែលចាប់ខ្លួនហ្នឹង ចាប់នៅក្នុងចម្ការ ហើយគេចងបណ្តើរយកមកដាក់ក្រោមផ្ទះបងប្អូនខ្មែរជាតិយើងហ្នឹង។ ប្រហែលជាមួយអាទិត្យ គេដោះលែងវិញ ហើយមានមួយចំនួនតូចនៅតែសល់តែប្រាំនាក់ គេចាប់ស្លាបសេកដាក់រទេះសេះ។ នៅក្នុងនុំងមានឪពុកខ្ញុំផងដែរ។

**សៈ** តើឪពុករបស់លោកមានតួនាទី មុខងារអ្វីសំខាន់ដែរទេ នៅក្នុងភូមិ?

**ឆៈ** គាត់ជាភូឈ្លួយទី២ ជាភូឈ្លួយរង។

**សៈ** លោកហៅគាត់ថាភូឈ្លួយរងហ្នឹង សូមលោករៀបរាប់ឲ្យច្បាស់បន្តិចមើល តួនាទីជាអ្វីធ្វើអ្វី កន្លែងណា?

**ឆៈ** វាហៅថាភូឈ្លួយរងហ្នឹង ទី១ លោកហាគីមហ្នឹងជាប្រធាន មានអនុប្រធាន គាត់ជារងទី២។ បើអត់ពីគាត់ គាត់ជាអ្នកធ្វើកិច្ចការនៅក្នុងភូមិហ្នឹង។ ប្រធានគេហាគីម បន្ទាប់មកភូឈ្លួយទី១ គាត់ទី២ បើអត់មានពីរនាក់ គាត់អាចជំនួសកិច្ចការខាងសាសនានៅក្នុងភូមិបាន។

**សៈ** អរគុណលោក ច្បាស់ហើយ។ ចុះមនុស្សប្រុសបួននាក់ដែលនាំខ្លួនទៅបាត់ រួមទាំងឪពុកលោកមួយទៀតប្រាំ ទាំងអស់ប្រាំនាក់នុំង តើមានបានជួបមុខអីឡើងវិញនៅក្នុងភូមិទេ?

**ឆៈ** បាទ អរគុណ។ នៅពេលហ្នឹងចាប់បាត់រហូតទាំងប្រាំនាក់ ទាំងឪពុកខ្ញុំផងដែរ អត់ដែលវិលមកវិញទេ។

[១៤:៣៣:០០]

**ស៖** ខ្ញុំសូមសួរព័ត៌មានពាក់ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនរបស់លោកគឺE3/6714 ERN អង់គ្លេស 01089919, ខ្មែរ 00563974 ដល់ 75, បារាំង 01137854។ លោកបានរៀបរាប់អំពីព្រឹត្តិការណ៍នេះ គឺព្រឹត្តិការណ៍ចាប់មនុស្សមួយក្រុមធំ ហើយក្រោយមកត្រូវបានគេដោះលែងភាគច្រើន។ ប៉ុន្តែលោកថា បុរសទាំងប្រាំនាក់នេះ គឺជាមនុស្សដែលគេហៅចាស់ទុំនៅក្នុងភូមិ រួមមានមេភូមិ មេភូមិរង មេភូមិឈ្មោះ កៅ និងជីដូនមួយឈ្មោះ ឌី មិន។ នៅពេលដែលលោករៀបរាប់ការចងចាំរបស់លោកទាក់ទងទៅនឹងអត្តសញ្ញាណរបស់អ្នកដទៃទៀតនោះ លោកថាអ្នកទាំងអស់ហ្នឹងមានតួនាទីខ្ពស់ខ្ពស់នៅក្នុងភូមិ។ សូមលោកបញ្ជាក់លម្អិតមើល។

**ឆ៖** ឈ្មោះ កៅ ហើយឈ្មោះ លី មីន ទេមិនមែនឈ្មោះដូចលោកមានប្រសាសន៍អម្បាញ់មិញទេ ឈ្មោះ លី មីន ជីដូនមួយខ្ញុំ។ គាត់ជាអ្នកធ្វើការនៅក្នុងភូមិ។ ឈ្មោះ កៅ ហ្នឹងគាត់ប្រធានភូមិ។

**ស៖** សូមអរគុណ។ អ៊ីចឹងមនុស្សទាំងពីរនាក់នេះ កៅ, លី មីន នេះគឺជាមនុស្សស្ថិតនៅក្នុងក្រុមមនុស្សទាំងប្រាំនាក់ រួមទាំងឪពុករបស់លោក ដែលគេយកដឹកនាំខ្លួនទៅបាត់ហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** បាទមែន។

**ស៖** សូមអរគុណចំពោះចម្លើយនេះ។ លោកក៏បានឆ្លើយផងដែរថា គេនាំអ្នកទាំងអស់ហ្នឹងសំដៅទៅសាលាស្រុក ទៅមន្ទីរស្រុក តើលោកជម្រាបជូនតុលាការបានទេ មន្ទីរស្រុកហ្នឹងនៅឯណាដែរ?

**ឆ៖** នៅក្រូចឆ្មារ ស្រុកក្រូចឆ្មារ មន្ទីរស្រុក។

[១៤:៣៥:៥១]

**ស៖** ពីពេលដែលគេដឹកឪពុករបស់លោក និងអ្នកដទៃទៀតទៅហ្នឹង តើលោកមានបានទទួលព័ត៌មានថាមានអ្វីកើតឡើងដល់ឪពុករបស់លោកនុ៎ងដែរទេ?

**ឆ៖** នៅពេលនុ៎ងដល់គេចាប់ចងស្លាបសេក ដាក់រទេះសេះ សំដៅទៅសាលាស្រុកក្រូចឆ្មារហ្នឹង អត់ដែលឮដំណឹងអីទេ បាត់រហូត បាត់រហូតអត់ដែលវិលមកវិញទេ ទាំងប្រាំនាក់ហ្នឹង។

**ស៖** បាទ អរគុណចំពោះចម្លើយនេះ។ លោកបានឆ្លើយថា ការចាប់ខ្លួននេះកើតឡើងនៅមុនពេលបះបោរ។ តើលោកមានបានដឹងការចាប់ខ្លួនដទៃៗទៀត ដែលកើតមានឡើងមុនពេលបះបោរនៅស្វាយឃ្លាំងនោះដែរទេ?

**ឆ៖** បាទសូមអរគុណ។ រឿងចាប់នៅក្នុងភូមិចាប់តាំងពីយូរមកហើយ តាំងពីឆ្នាំ៧៣ម្ល៉េះ រហូតមកដល់៧៥ ទើបមានការបះបោរ។

**ស៖** ហើយសំណួរមួយនេះប្រហែលជាសំណួរពិបាកបន្តិចហើយ ប៉ុន្តែលោកអាចប៉ាន់ប្រមាណបានទេថា ប្រជាជនសរុបទាំងអស់នៅភូមិស្វាយឃ្លាំងហ្នឹង ត្រូវបានគេចាប់ខ្លួនពីភូមិស្វាយឃ្លាំងហ្នឹង តាំងពី៧៣, ៧៤ រហូតដល់៧៥ គឺមុនការបះបោរ សរុបទាំងអស់ប្រហែលប៉ុន្មាននាក់? ១០នាក់ ១០០នាក់ ឬក៏២០០នាក់ លោកអាចប៉ាន់ប្រមាណបានទេ?

**ឆ៖** ខ្ញុំពុំអាចប៉ាន់ស្មានបានទេ ព្រោះខ្ញុំជាប្រជាជន ខ្ញុំពុំបានចំណាំមុខអស់ទេ ព្រោះខ្ញុំមិនអ្នកកត់ស្ថិតិទេ ប៉ុន្តែដឹងថាបាត់ជាច្រើន តែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ឥឡូវត្រឡប់ទៅនិយាយអំពីការបះបោរវិញម្តង។ តើ--

[១៤:៣៨:៤៥]

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន! យ៉ាងម៉េចទៅលោកក្រឡាបញ្ជី? លោកស្រី សែ កុលវត្តី?

លោកមេធាវី សុន អរុណទៅណា?

*(សម្រាករយៈពេលខ្លី)*

បាទ ឥឡូវហ្នឹងមានបញ្ហាអីចឹងផង ហើយដោយពេលវេលាក៏សមស្របនឹងសម្រាកដែលហើយ ឥឡូវអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និង ឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការវិញ នៅវេលាម៉ោងបីខ្វះប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរបន្តដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោក ម៉ាន ស្លេះ ពីខាងដើម នៅពេលដែលលោកឆ្លើយទៅនឹងសំណួរមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកបាននិយាយថា មូលហេតុមួយសម្រាប់នៃការបះបោរនោះគឺ រឿងដែលថា គេមិនអនុញ្ញាតឲ្យជនជាតិចាមប្រតិបត្តិសាសនាអ៊ីស្លាម។ តើមានហេតុផលអ្វីផ្សេងទៀតដែរឬទេ ដើម្បីក្រុមចាមធ្វើការបះបោរពេលហ្នឹង ក្រៅពីមូលហេតុមួយខាងដើមនេះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៤:៥៩:១១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ទៅលើសំណួរដែលតាំងដោយសហព្រះរាជអាជ្ញារងអន្តរជាតិ ទាក់ទងទៅនឹងការបះបោរជាលក្ខណៈទូទៅ។ ក្នុងសវនាការរបស់យើងនេះ យើងនិយាយអំពីការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយឥឡូវនេះដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសួរអំពីអង្គហេតុដែលទាក់ទងទៅនឹងការបះបោរ ដែលជាការប្រាសចាកពីគោលបំណងនៃសវនាការរបស់យើង។ ដូច្នេះខ្ញុំសូមលោកប្រធាន អង្គជំនុំជម្រះមេត្តាកត់សម្គាល់ទៅលើចំណុចនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញលោកអាចសួរបាន។ កាលណាដើមបណ្ដឹងរដ្ឋប្បវេណី គាត់បានដឹងរឿងហេតុដែលកើតមានឡើងនៅក្នុងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការ ក្រៅពីថ្លែងទុក្ខសោកវេទនាស្ថានភាពព្យសនកម្មដែលកើតមានចំពោះគាត់ គឺគាត់អាចឆ្លើយតបទៅនឹងសំណួររបស់ភាគីដែលសួរពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលគាត់បានដឹង ដែលគាត់ដឹងពាក់ព័ន្ធនឹងបញ្ហានោះ ដែលអង្គហេតុនោះ គឺក្នុងក្របខ័ណ្ឌនៃអង្គហេតុដែលបានចោទប្រកាន់ ហើយអង្គជំនុំជម្រះកំណត់ធ្វើសវនាការនាពេលនេះ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ប្រហែលខ្ញុំត្រូវសម្រួលសំណួរឡើងវិញជូនលោក។ តើមានមូលហេតុអ្វីខ្លះដែលប្រជាជនចាមនៅស្វាយឃ្លាំង គាត់សម្រេចចិត្តថា ធ្វើការបះបោរកាលនោះ?

[១៥:០០:៥២]

**លោក ម៉ាន ស្លេះ៖**

**ឆ៖** សូមអរគុណ។ មុននឹងសម្រេចធ្វើការបះបោរ ដោយសារខ្មែរក្រហមសម្លាប់ជនជាតិចាមច្រើនណាស់នៅក្នុងភូមិខ្ញុំ។ ទើបសម្រេចចិត្តនាំគ្នាបះបោរទាំងអស់គ្នាក្នុងមួយភូមិ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមត្រឡប់ទៅពេលមួយ បន្ទាប់ពីការបះបោរមួយថ្ងៃក្រោយមក ដែលប្រជាជននៅស្វាយឃ្លាំង ប្រជាជនចាមត្រូវបានគេជម្លៀសចេញ ដោយបង្ខំចេញពីភូមិនោះថាតើនរណាជាអ្នករៀបចំការជម្លៀសប្រជាជនចាមនៅពេលនោះ?

**ឆ៖** នៅពេលនោះ ឃើញតែយោធាស្ពាយកាំភ្លើង ពុំដឹងជាអ្នកណាទេ ឃើញតែយោធាតែមួយពាក់អាវខ្មៅ ស្ពាយកាំភ្លើង ជម្លៀសចេញពីភូមិយកទៅដាក់ឡថ្នាំ ឯស្រីៗដាក់នៅកន្លែងវត្ត នៅវត្តដើមជ្រៃ ឆ្ងាយពីគ្នាប្រហែលជា១គីឡូ។

**ស៖** ខ្ញុំចង់សួរសំណួរមួយទាក់ទងទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺជាប្រយោគចុងក្រោយមួយ បន្ទាប់ពីដែលលោកសរសេរ គឺនៅសន្លឹកចុងក្រោយ។ លោកនិយាយថា៖ "ខ្ញុំបានដឹងថា ប្រធានឃុំឈ្មោះ វង្ស ហើយអ្នកនៅក្រោមបញ្ជាឈ្មោះ ប៉េង ហេង ហើយអ្នកទាំងពីរនេះត្រូវបានសម្លាប់ដោយខ្មែរក្រហមគ្នាឯងដែលនាំអ្នកទាំងនោះចេញទៅ។" អ៊ីចឹងថាតើនៅពេលមានការបះបោរនៅស្វាយឃ្លាំង តើអ្នកទាំងពីរហ្នឹង មានភាពពាក់ព័ន្ធដូចម្ដេចដែរឬទេ?

ឆ៖ អ្នកដែលធ្វើការនៅក្នុងភូមិមានតែ ប៉េង ហេង និងឈ្មោះ ឡុង ទេ មិនមែនឈ្មោះដូច លោកនិយាយអម្បាញ់មិញ មិនមែនទេ។ មានតែឈ្មោះ ប៉េង ហេង និងឈ្មោះ ឡុង ហើយនៅពេលនុ៎ង ពួកយោធាខាងភូមិភាគកណ្ដាលចូលទៅ បើបូពា៌ ពួកហ្នឹងក៏គេយកទៅសម្លាប់ដែរ ទាំងពីរនាក់ហ្នឹង។

[១៥:០៤:០៥]

សៈ តើលោកអាចជម្រាបតុលាការ ថាតើឈ្មោះពីរនាក់ដែលខ្ញុំបញ្ជាក់ហ្នឹង ថាតើអ្នកទាំងពីរនាក់ហ្នឹង មានភាពពាក់ព័ន្ធអីជាមួយនឹងការបះបោររបស់ប្រជាជនចាមនៅស្វាយឃ្លាំងដែរឬទេ? មានឈ្មោះ ប៉េង ហេង មានឈ្មោះ ឡុង នេះ?

ឆ៖ នៅពេលរបបហ្នឹង គាត់ជាអ្នកគ្រប់គ្រងក្នុងភូមិខ្ញុំ គាត់ធ្វើជាមេឃុំ ប្រធាន និងអនុប្រធាន ឈ្មោះ ឡុង ហ្នឹងប្រធាន ប៉េង ហេង ហ្នឹងអនុ។

សៈ សូមអរគុណ។ ចំណុចចុងក្រោយដែលខ្ញុំចង់សួរលោកគឺ ពីអ្វីដែលលោកបានឮអំពីការសម្លាប់ម្ដាយរបស់លោក ហើយនិងបងប្អូនបង្កើតបីនាក់។ ហើយនេះអ្វីដែលលោកបានឮពីអ្នកភូមិដែលជាអ្នកប្រាប់លោក។ ហើយតាមអ្វីដែលលោកចងចាំ តើអ្នកភូមិទាំងនោះប្រាប់លោកអំពីអ្វីខ្លះ? អំពីតើម្ដាយរបស់លោក ហើយនិងបងប្អូនរបស់លោក គេយកទៅកន្លែងណា គេធ្វើដូចម្ដេច ហើយគេសម្លាប់នៅកន្លែងណា? តើលោកចាំបានអ្វីខ្លះ?

ឆ៖ ខ្ញុំៗបាទនៅចាំ។ ពេលដែលខ្ញុំទៅជួប ដែលបាត់ពីពួកគាត់ សួរអ្នកភូមិ អ្នកភូមិពុំអាចនិយាយជាមួយខ្ញុំបានច្រើនទេ និយាយប្រហែល២នាទីទេ ថាពួកគាត់គេយកទៅសម្លាប់នៅស្រុកស្ទឹងត្រង់ គេហៅថា បឹងកាចូត នៅក្បែរស្រុក ទីរួមស្រុកស្ទឹងត្រង់។ គេហៅថាបឹងកាចូត។

សៈ តើអ្នកភូមិទាំងនោះបានប្រាប់ថា គេយកសមាជិកក្រុមគ្រួសារលោកយកទៅទីនោះ ដើម្បីសម្លាប់ ឬក៏គេប្រាប់ដូចម្ដេច?

[១៥:០៦:២១]

ឆ៖ អ្នកភូមិនុ៎ង បាននិយាយជាមួយខ្ញុំអត់បានច្រើនទេ គាត់ខ្លាចដែរ។ គាត់ថាពួកគាត់ គេជម្លៀសយកទៅសម្លាប់ចោលនៅស្រុកស្ទឹងត្រង់ គេហៅថា បឹងកាចូត ដាក់កាណូតទៅ។

សៈ តើពួកគាត់ប្រាប់លោកពីអ្វីខ្លះ អំពីរបៀបនៃការសម្លាប់? តើគេប្រើកាំភ្លើងបាញ់ ឬក៏គេវាយនឹងដំបង ឬក៏គេសម្លាប់ដោយទម្លាក់ឲ្យលង់ទឹកស្លាប់ ឬក៏យ៉ាងម៉េច?

ឆ៖ សូមអរគុណ។ រឿងរ៉ាវទាំងអស់នេះ ខ្ញុំអត់បានដឹងទេ គាត់គ្រាន់តែប្រាប់ខ្ញុំថា គេជម្លៀស

ពីភូមិគាត់ហ្នឹង យកទៅសម្លាប់ចោលនៅស្ទឹងត្រង់ គេហៅបឹងកាចូត ស្រុកស្ទឹងត្រង់ បឹងកាចូត។ តែប៉ុណ្ណឹង អត់មាននិយាយអីបាញ់កាំភ្លើង បាញ់អី គ្រាន់តែនិយាយថា យកទៅសម្លាប់ចោលតែប៉ុណ្ណោះ។

**លោក ត្រាវីស ហ្វារ៖**

បាទ សូមអរគុណដែលលោកដើមបណ្តឹងរដ្ឋប្បវេណីដែលលោកបានឆ្លើយសំណួររបស់ខ្ញុំ ហើយខ្ញុំសូមអរគុណចំពោះសេចក្តីអំណត់ ទោះបីលោកមានការលំបាកក៏ដោយ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ដំបូងនេះផ្តល់វេទិកាទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន។ សូមអញ្ជើញ!

[១៥:០៨:២៦]

**លោក សុន អរុណ៖**

ខ្ញុំឈ្មោះ សុន អរុណ មេធាវីការពារលោក នួន ជា។ សូមជម្រាបសួរ លោកដើមបណ្តឹងរដ្ឋប្បវេណី។ សូមជម្រាបសួរអង្គសវនាការ សូមគោរពលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំមានសំណួរពីរបីសម្រាប់សួរលោកដើមបណ្តឹងរដ្ឋប្បវេណីថ្ងៃនេះ។ នៅចុងឆ្នាំ១៩៧៥ មានការបះបោររបស់ជនជាតិចាម ប្រឆាំងនឹងកម្លាំងខ្មែរក្រហមនៅក្នុងភូមិស្វាយ។ ហើយលោកអាចដឹងថា ហេតុអ្វីបានជាជនជាតិចាមបះបោរប្រឆាំងនឹងជនជាតិ -- ប្រឆាំងនឹងកម្លាំងខ្មែរក្រហម ដែលខ្មែរក្រហមទើបតែឈ្នះពីរដ្ឋាភិបាល លន់ នល់ថ្មីៗ។ ហើយគេជាកម្លាំងទ័ពទ័ព ហើយជនជាតិចាមជាប្រជាជនធម្មតា មានអាវុធណាតតាំង។ យល់យ៉ាងម៉េច បានជាប្រឆាំងនឹងរដ្ឋាភិបាលមួយដែលទើបៗនឹងឈ្នះរដ្ឋាភិបាលមួយទៀត? សូមលោកឆ្លើយ។

**លោក ម៉ាន ស្លេះ៖**

**ឆ៖** សូមអរគុណ។ ទី១ បានសម្លាប់ជនជាតិចាមជាច្រើនណាស់។ ទី២ មិនឱ្យគោរពសាសនា ព្រោះសាសនាហ្នឹងហើយ ជាសាសនាព្រះមហាម៉ាត់ដែលធំជាងគេ ខាងសាសនាអ៊ីស្លាម។ បានជាពួក

យើងខ្ញុំនាំគ្នាបះបោរ មិនខ្លាចស្លាប់ ដើម្បីសាសនា ដើម្បីជនជាតិចាមរបស់ខ្ញុំ។

**ស៖** សូមអរគុណ។ នៅពេលដែលធ្វើកាបះបោរហ្នឹង មានប្រជាជនប្រហែលប៉ុន្មាននាក់? តើលោកអាចដឹងច្បាស់ទេ?

[១៥:១០:៤៨]

**ឆ៖** សូមអរគុណ។ ខ្ញុំបានដឹងច្បាស់ក្នុងរឿងបះបោរនេះ ព្រោះហេតុអី ខ្ញុំនៅក្នុងភូមិហ្នឹងដែរ គឺបះបោរទាំងអស់គ្នា។ លើកលែងតែក្មេងតូចៗតាមម្ដាយទេ ហើយកូនស្រីៗ កូនខ្ចីទេ ដែលអត់មានធ្វើការបះបោរជាមួយគេ។

**ស៖** បើអ៊ីចឹងនៅពេលដែលបះបោរហ្នឹង លោកបានចូលរួមជាសកម្មនៅក្នុងពេលបះបោរហ្នឹងដែរ អ៊ីចឹង?

**ឆ៖** មិនមែនដូចលោកថាទេ ខ្ញុំនៅពីក្រោយទេ ខ្ញុំមិននៅជួរមុខទេ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការបង្វែរ សម្របសម្រួលក្បាលមីក្រូហ្វូនឲ្យគាត់និយាយអ៊ីចុះ គាត់និយាយឆ្ងាយ គាត់ងាកមកផុតមកលិចហើយ ងាកមកលិចមកណា។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំមេត្តា សូមមេត្តាលោកដើមបណ្ដឹងរដ្ឋប្បវេណីមេត្តាឆ្លើយម្តងទៀត អំមិញខ្ញុំស្តាប់លោកអត់សូវបាន។ សូមទោស។

**លោក ម៉ាន ស្លេះ៖**

**ឆ៖** ខ្ញុំស្តាប់មិនសូវច្បាស់ សូមលោកសួរសំណួរម្តងទៀត។

[១៥:១២:៣៥]

**ស៖** ខ្ញុំសូមសួរម្តងទៀត ថាពេលដែលបះបោរនោះ តើលោកបានចូលរួមជាមួយគេយ៉ាងសកម្មទេ នៅពេលដែលបះបោរនោះ រយៈពេលប៉ុន្មាន មួយថ្ងៃ មួយថ្ងៃកន្លះ? លោកបានចូលរួមជាមួយគេទេ?

**ឆ៖** ខ្ញុំបានជម្រាបអម្បាញ់មិញហើយ ថាខ្ញុំបានចូលរួម ប៉ុន្តែខ្ញុំនៅជួរក្រោយ មនុស្សជាច្រើនខ្ញុំនៅជួរក្រោយ។

**ស៖** សូមអរគុណ។ សូមលោកនិយាយត្រួសៗជម្រាបតុលាការថា ពេលដែលគេបះបោរនោះ តើសកម្មភាពនៃការបះបោររបស់ជនជាតិចាមជាមួយនឹងខ្មែរក្រហមខ្លាំងក្លារបៀបណា? តើលោកអាច

ជម្រាបបានទេ?

**ឆ៖** សូមអរគុណ។ ខ្ញុំអាចជម្រាបប្រាប់លោកបាន ពេលដែលធ្វើការបះបោរហ្នឹង ដូចនៅសមរភូមិប្រយុទ្ធគ្នា ដែលមានកងទ័ពទាំងសងខាង អ៊ីចឹងដូចគ្នា។ តែក៏ប៉ុន្តែជនជាតិចាមហ៊ានប្រយុទ្ធតែកាំបិតទេ ដើម្បីសាសនា តែសាសនាមហាម៉ាត់នេះឯង មិនខ្លាចស្លាប់។ ស្លាប់ជាច្រើនពួកចាម ហើយពួកយោធាស្លាប់ដែរ កាលក៏ប៉ុន្តែស្លាប់តិចជាងជនជាតិចាម។

**ស៖** លោកអាចជម្រាបតុលាការថា ពេលដែលបះបោរប្រទូស្តប្រទ្រាស់វ៉ៃគ្នាខាងកងទ័ព ប្រជាជនខ្មែរ ខាងខ្មែរក្រហមមានអាវុធ មានកាំភ្លើង មានអ្វីជាដើម។ ចំពោះជនជាតិចាមមាន អំមិញលោកដើមបណ្តឹងរដ្ឋប្បវេណីបានមានជម្រាបហើយថាមានតែកាំបិត មានតែដំបង។ តើតាមលោកយល់ ដែលចូលទៅវាយគ្នា ហើយមានគំនិតមុនហើយ ថាតែបើវាយទៅឈ្នះគេ ឬក៏យ៉ាងម៉េចទេ មានគំនិតអ៊ីចឹងទេ ឬក៏ចាញ់គេ ឬក៏ស្លាប់ ឬអី? ហើយលោក ខ្លួនលោកផ្ទាល់ហ្នឹង លោកយល់យ៉ាងម៉េច?

[១៥:១៥:៤៣]

**ឆ៖** ខ្លួនខ្ញុំបាទផ្ទាល់ ខ្ញុំយល់ថា នៅក៏មិនរស់ប៉ុន្មានដែរ ព្រោះថាគេធ្វើបាប ពួកជនជាតិចាមយើង ព្រោះគេចាប់រាល់ថ្ងៃ ដូចខ្ញុំប្រាប់ពីដើមមក។ គេចាប់ចង គេយកទៅសម្លាប់ជាបន្តបន្ទាប់រហូតមក ទើបមានការបះបោរ លែងខ្លាចស្លាប់ ១ចុះ ស្លាប់ដើម្បីសាសនា ដើម្បីអល់ឡោះព្រះខ្ញុំ នៅលើពីលើ។

**ស៖** ពេលដែលមានការបះបោរហ្នឹង បើតាមក្នុងឯកសារថានៅចុងឆ្នាំ១៩៧៥ សកម្មភាពរបស់ខ្មែរក្រហមដែលធ្វើបាប ដូចលោកមានប្រសាសន៍អំមិញ ថាធ្វើបាបតាំងពីមុនដំបូងមក តាំងពីចិត -- ខ្មែរក្រហមរំដោះប្រទេសកម្ពុជាពីរបប លន់ នល់ មក ការធ្វើបាបប៉ុន្មានខែហ្នឹង តើឲ្យលោកយល់ថាទាល់តែវាយគ្នាបាន១១១គេឈប់សម្លាប់យើង ទាល់តែវាយគ្នាបានយើងហ្នឹង បានឈ្នះទៅបានជាក្រុមបងប្អូនចាមហ្នឹងឈប់តវ៉ា លោកយល់អ៊ីចឹងអ្វី? ហើយក៏យល់យ៉ាងម៉េចផ្សេងទៅទៀត?

**ឆ៖** ខ្ញុំមិនយល់ដូចលោកទេ ខ្លួនខ្ញុំផ្ទាល់យល់ផ្សេងពីលោក គឺថាបណ្តោយឲ្យពួកខ្មែរក្រហមសម្លាប់ក៏ស្លាប់អត់មានន័យដែរ ដើម្បីធ្វើការបះបោរ ស្លាប់សម្លាប់ដូចថាយើងហ្នឹងសម្លាប់ដើម្បីសាសនា និងព្រះអល់ឡោះតែប៉ុណ្ណោះហើយ។ លែងសោកស្តាយទៀតហើយ រស់ធ្វើអ្វីបើគេនៅតែធ្វើបាប ចាប់ចងម្តងប្អូនប្រាំនាក់ ម្តងប្អូនប្រាំនាក់ជារៀងរាល់យប់។

**ស៖** ពេលដែលគេចាប់ចង ខ្មែរក្រហមចាប់ចងជនជាតិចាម មួយយប់បីប្អូនប្រាំនាក់ បីប្អូនប្រាំ

នាក់ លោកផ្ទាល់ហ្នឹង លោកដឹងមូលហេតុថាហេតុអីបានគេចាប់ចងទេ? ហើយហេតុអីបានគេធ្វើបាប ឬក៏គេវាយ ឬក៏គេយកទៅណា? ហេតុអីបានជាគេធ្វើអ៊ីចឹងទេ? យល់ទេ?

**ឆ៖** ខ្ញុំបាទ បានយល់ខ្លះៗ។ គេចង់សម្លាប់បំបាត់ពូជចាមពីកម្ពុជាយើង។

[១៥:១៩:០២]

**ស៖** លោកថា គេសម្លាប់ជនជាតិចាមដើម្បីបំបាត់ពូជពីកម្ពុជា។ ខ្ញុំនិយាយហ្នឹង ខ្ញុំនិយាយឡើងវិញហ្នឹង ត្រូវទេសម្ដីរបស់លោកអំមិញនិយាយ ខ្ញុំនិយាយសាឡើងវិញអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** លោកមានយល់ថា បើសិនជាកម្ពុជាចង់សម្លាប់ពូជសាសន៍ជនជាតិចាម ហេតុអីបានជាសម័យមុនៗមក រដ្ឋាភិបាលមុនៗហ្នឹងទៅទៀត សម័យ សីហនុ សម័យលន់ នល់ ម៉េចមិនសម្លាប់ចាម ហើយមកដល់ខ្មែរក្រហម បានជាសម្លាប់ចាមទៅវិញ? លោកអាចឆ្លើយត្រង់ហ្នឹងបានទេ?

**ឆ៖** បាទ អរគុណ ខ្ញុំអាចឆ្លើយបាន។ សំណួរដែលលោកដាក់មក សម័យមុនៗ គេមានសាលា គេមិនប្រកាន់ពូជសាសន៍ សាសនាណាក៏អាចមានសិទ្ធិរៀនដូចបងប្អូនខ្មែរជាតិដែរ។ មានរៀនភាសាខ្មែរ ភាសាចាម អង់គ្លេសផងដែរ។ បើសម័យខ្មែរក្រហម អត់ឲ្យរៀនទេ។ រៀនកើបអាចម៍គោ កូនកុមារៗ អត់ឲ្យរៀនទេ រៀនបាន បានតិចតួច។

**ស៖** សូមអរគុណលោក។ បើតាមខ្ញុំដឹង និងឯកសារខ្មែរយើងជាទូទៅមក គ្រប់សម័យគេមានសាលាដូចលោកមាននិយាយជម្រាបតុលាការអំមិញអ៊ីចឹង។ ប៉ុន្តែដល់សម័យខ្មែរក្រហម បើតាមឯកសារ និងភស្តុតាងដែលបានលើកឡើងមកចំពោះមុខតុលាការ គឺអត់មានសាលាដូចគ្នា។ អត់មានសាលា អត់ទាន់បង្កើតសាលាអីដូចគ្នា បើតាមឯកសារដែលមានមកហើយ ពីព្រោះអីរដ្ឋាភិបាលទើបបង្កើតថ្មី ទើបបង្កើតថ្មីហើយមិនទាន់បានរៀបចំ។ ប៉ុន្តែហេតុអីបានជាជនជាតិចាម យល់ខុសម្នាក់ឯងអ៊ីចឹងថាទេ ពួកហ្នឹងអត់មានឲ្យកូនក្មេង ឲ្យកូនចាមទៅរៀន ហើយជារឿងខុស ត្រូវតែតស៊ូ។ អាហ្នឹងលោកយល់យ៉ាងម៉េច?

[១៥:២១:៤៦]

**ប្រធានអង្គជំនុំ៖**

អ្ហឺ! លោកតាំងសំណួរដូចឆ្ងាយពេកហើយ ម៉េចក៏លោកប៉ានសន្និដ្ឋានថា ជនជាតិចាមដែលគេមានធ្វើការបះបោរតស៊ូប្រឆាំងនឹងការគ្រប់គ្រងនៃក្រុមរបបខ្មែរក្រហម ទៅជាការយល់ខុស? លោក

យល់ខ្លួនឯង ឬក៏យ៉ាងម៉េច? លោកតាំងសំណួរពាក់ព័ន្ធជាមួយនឹងអង្គហេតុឲ្យបានច្រើន បើសិនជាលោកមានប៉ងសំណួរសួរលើអង្គហេតុ។ បើសិនសួរលើព្យសនកម្ម គឺលោកសួរពាក់ព័ន្ធនឹងព្យសនកម្ម មិនមែនសួរឲ្យការប៉ាន់ស្មានជាទស្សនវិជ្ជា ដូច្នេះទេ។ រឿងខុសរឿងត្រូវ អត់ទាន់មានអ្នកណាអាចដឹងថា ការធ្វើការប្រតិកម្មប្រឆាំងតបតហ្នឹងខុសទេ។ ខុសមួយសម័យនេះ ហើយសម័យកាលផ្សេងវាអាចត្រូវ។ ការដើបបះបោរមិនមែនតែចាមទេ គឺគ្រប់ជនជាតិទាំងអស់នៅលើសកលលោក គឺតែងតែមានការបះបោរ បង្ហូរឈាមដើម្បីតស៊ូដែលគេយល់ឃើញថា វាសមស្របនឹងការប្រព្រឹត្តដូច្នេះដើម្បីទាមទារ ទោះបីគេពលីកម្មក្នុងអំឡុងពេលនេះមិនបានជោគជ័យ ប៉ុន្តែជាការបណ្ដុះគំនិតសម្រាប់មនុស្សជំនាន់ក្រោយឲ្យបន្តវេន ឬក៏តម្រែតម្រង់នូវទស្សនៈរបស់គេដើម្បីជាបន្តទៅទៀត។ លោកដាក់កំហុសថាគេខុសហ្នឹង គឺមិនត្រឹមត្រូវទេ។ លោករៀបចំសំណួរឲ្យបានល្អ ឡើងវិញ បើសិនលោកចង់សំណួរសួរបែបនេះ។

**លោក សុន អរុណ៖**

នេះយោងទៅលើចម្លើយរបស់គាត់ និងសំណួររបស់ខ្ញុំ។ គាត់ថា គាត់ខឹងនឹងខ្មែរក្រហមកាប់សម្លាប់ធ្វើបាបតាំងពីកូនក្មេងឡើង អត់បាន--

[១៥:២៣:២៩]

**ប្រធានអង្គជំនុំ៖**

លោកយល់ថា លោកថាគេខុស នៃបញ្ហានេះ។ ម៉េចៗថាគេយល់ខុស។ លោកចង់បន្ទោសជនរងគ្រោះដែលជាជនជាតិចាម ដែលបានទទួលមរណភាពកន្លងមក ដោយសារអំពើរបស់ខ្មែរក្រហមកាប់សម្លាប់គាត់ ថាខុសយ៉ាងម៉េច? យើងចង់ឲ្យលោករៀបចំនូវសំណួរដើម្បីទៅកុំឲ្យទម្លាក់កំហុសអំពើហ្នឹងទៅជាគេខុស។ យុត្តិកម្មនៃអំពើដូចជាមិនត្រូវទេ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ អរគុណដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខាងក្រុមមេធាវីលោក ខៀវ សំផន អត់មានសំណួរទេ។

សូមអរគុណ។

[១៥:២៤:២៧]

**ប្រធានអង្គជំនុំ៖**

បាទ ហើយជាចុងក្រោយនេះ តើលោកដើមបណ្ដឹងរដ្ឋប្បវេណី លោក ម៉ាន ស្លេះ តើលោកមានអ្វីចង់រៀបរាប់ថ្លែងពីទុក្ខសោកវេទនា ជាចុងក្រោយដែរឬទេ ឬក៏លោកមានសំណួរអ្វីចង់សួរតាំងសំណួរទៅជនជាប់ចោទ តាមរយៈប្រធានអង្គជំនុំជម្រះ គឺតាមរយៈយើងដែរឬទេ? បើសិនបើមានបំណងដូច្នេះ សូមអញ្ជើញ!

**លោក ម៉ាន ស្លេះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរពីរ ឬបីសំណួរ។ មានដូចតទៅ៖ សំណួរទី១ ហេតុអីបានជាខ្មែរក្រហមស្អប់ជនជាតិចាមម្ល៉េះ? សំណួរទី២ ហេតុអីបានជាខ្មែរក្រហមចង់សម្លាប់ចាមឲ្យផុតពូជ? ទី៣ សំណួរដែលសាសនាចាប់ សាសនាព្រះមហាម៉ាត់ ចាត់ទុកថាជាសាសនាសក្តិភូមិ? សូមអស់សំណួរហើយ។ ប្រតិកិរិយា សុំទោស ខ្ញុំភ្លេច ជាសាសនាប្រតិកិរិយា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបលោក ម៉ាន ស្លេះ ថាតាមបទប្បញ្ញត្តិនៃវិធាន២១ ចំណុច(១) អនុវិធាន១ ហើយនិងចំណុច(ឃ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា៖ “នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះត្រូវប្រាប់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរដល់ជនជាប់ចោទ។”

[១៥:២៦:២៥]

ហើយនៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្ដាប់ជនជាប់ចោទទាំងពីរនាក់ គាត់បានឆ្លើយបញ្ជាក់ពីការដែលពួកគាត់សូមរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរ។ ហើយនាសវនាការពេលនោះ អង្គជំនុំជម្រះក៏បានកត់សម្គាល់ថា ជនជាប់ចោទទាំងពីររូប នៅតែរក្សាជំហររបស់ខ្លួន បន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលព័ត៌មានជាក់លាក់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្ដីជនជាប់ចោទ។

នៅក្នុងសវនាការនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និង/ឬសហមេធាវីការពារក្ដី

ជនជាប់ចោទ ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការជូនដំណឹងមកអង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព បើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួរដែលអង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធ នៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការប្ដូរជំហររបស់ជនជាប់ចោទទាំងពីររូប ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបទៅនឹងសំណួរនោះនៅឡើយទេ។ ហើយអង្គជំនុំជម្រះបញ្ជាក់បន្ថែមថា អង្គជំនុំជម្រះមិនមានបទប្បញ្ញត្តិណាដែលផ្ដល់សិទ្ធិឲ្យអង្គជំនុំជម្រះហ្នឹង បង្ខំឲ្យជនជាប់ចោទត្រូវតែចាំបាច់ឆ្លើយបនឹងសំណួរទេ ព្រោះនេះជាគោលការណ៍ដែលចែងនៅក្នុងច្បាប់ ហើយនៅក្នុងវិធានផ្ទៃក្នុងដែលយើងមកអនុវត្តសព្វថ្ងៃនេះ។

[១៥:២៨:២៥]

ហើយអង្គជំនុំជម្រះសូមអរគុណលោក ម៉ាន ស្ដេះ។ សវនាការស្ដាប់សក្ខីកម្មរបស់លោក និងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីដែលលោកអះអាងថា បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ វត្តមានរបស់លោកនាពេលនេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅ បានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ មានសេចក្ដីសុខ សេចក្ដីចម្រើន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក ប៊ុន លឹមហួរ បុគ្គលិកអង្គការ ធី.ភី.អូ។ ឥឡូវនេះសវនាការសម្រាប់សាក្សីទាំងពីរ -- ដើមបណ្ដឹងរដ្ឋទាំងពីររូបនេះ បានចប់ហើយ ប៉ុន្តែដោយសារអង្គជំនុំជម្រះមានពេល អង្គជំនុំជម្រះត្រូវធ្វើបន្តស្ដាប់សក្ខីកម្មសាក្សី -- ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-CCP-1015 ជាបន្តទៀត។ ដូច្នេះអង្គជំនុំជម្រះសូមឲ្យលោកអង្គុយនៅទីហ្នឹងហើយ ហើយរង់ចាំអង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីបន្តទៅទៀត រហូតដល់ចប់នៅរសៀលនេះ។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក ម៉ាន ស្ដេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយនិងសូមឲ្យអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្ស

នាម 2-TCCP-1015 ចូលមកកាន់កន្លែងថ្លែងរៀបរាប់ទុក្ខសោកវេទនានៅចំពោះមុខអង្គជំនុំជម្រះ។

លោក ម៉ាន ស្តេះ អញ្ជើញទៅចុះ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៥:៣០:៣១]

**ប្រធានអង្គជំនុំ៖**

បាទ ហើយសូមជម្រាបជូនភាគីផងដែរថា អម្បាញ់មិញនេះមិនបានជម្រាបជូន ដោយសារតាមកាលវិភាគដែលបានគ្រោងទុក គឺដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងផ្តល់ការធ្វើសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មរបស់ខ្លួនហ្នឹង គឺតាមពិតតាមលំដាប់លំដោយដែលយើងបានកំណត់ហ្នឹង គឺ 2-TCCP-1014 ទេ ប៉ុន្តែដោយសារគាត់មានបញ្ហាសុខភាព ឥឡូវនេះគាត់កំពុងតែទទួលការព្យាបាលនៅពេទ្យប្រចាំការនៅ អ.វ.ត.ក។ ដូច្នេះហើយបានជាអង្គជំនុំជម្រះប្តូរមកស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1015 ជំនួសវិញ។

យ៉ាងម៉េចទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានបញ្ហាអីទេ មានការផ្លាស់ប្តូរការស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខលោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនេះ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ មិនមានបញ្ហាអ្វីចោទឡើងនោះទេ ហើយយើងខ្ញុំបានសួរទៅលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ក៏លោកស្រីបានត្រៀមខ្លួនហើយជាស្រេច។ ហើយលោកស្រីនឹងត្រូវសួរដោយសហមេធាវីនាំមុខអន្តរជាតិយើងខ្ញុំ គឺលោកស្រី ម៉ារី ហ្គីរ៉ូដ៍។ សូមអរគុណលោកប្រធាន។

[១៥:៣២:១២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ អរគុណ។ ហើយសួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីវេណី។ តើលោកស្រីឈ្មោះអី?

**លោកស្រី សៀង ចាន់ថី៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ សៀង ចាន់ថី។

**ស៖** បាទ អរគុណលោក សៀង -- លោកស្រី សៀង ចាន់ធី។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំទេ?

**ឆ៖** នាងខ្ញុំកើតនៅថ្ងៃទី១៤ ខែ៤ ឆ្នាំ១៩៦៣។

**ស៖** ទីលំនៅបច្ចុប្បន្នរបស់លោកស្រីនៅទីកន្លែងណា?

**ឆ៖** ទីលំនៅបច្ចុប្បន្នរបស់នាងខ្ញុំនៅភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង។

**ស៖** តើលោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំជាមន្ត្រីនៅក្នុងក្រសួងកសិកម្ម។

**ស៖** បាទ អរគុណ។ ហើយចុះស្វាមីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

[១៥:៣៣:៣២]

**ឆ៖** ស្វាមីខ្ញុំបែកគ្នា។ ខ្ញុំមានកូនប្រុសម្នាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សៀង ចាន់ធី។ ក្នុងឋានៈលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលនាំឲ្យលោកស្រីសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកស្រីជាអាទិ៍ ការខូចខាតខាងរាងកាយ ផ្លូវចិត្ត ឬក៏សម្ភារៈ និងជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋជាព្យសនកម្មផ្ទាល់ខ្លួន ដែលកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ។

ហើយដោយសារតាមសំណូមពររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះផ្តល់វេទិកានេះជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធជាមួយនឹងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មរបស់គាត់ ឬក៏អ្វីដែលមានការពាក់ព័ន្ធនឹងអ្វីដែលគាត់បានយល់ដឹង ពាក់ព័ន្ធនឹងអង្គហេតុផងដែរ បើសិនអាច បើមាន។ សូមអញ្ជើញបាទ!

[១៥:៣៥:១៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំជាអ្នកចោទសំណួរទៅលោកស្រីនៅរសៀលនេះ។ លោកស្រីត្រូវបានអញ្ជើញមកទីនេះ ដើម្បីនិយាយអំពីទុក្ខវេទនា ដែលលោកស្រីបានទទួលរងទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម។ ហើយខ្ញុំចោទសំណួរទៅនឹងលោកស្រី ទាក់ទងទៅនឹងការឈឺចាប់របស់លោកស្រី នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី លោកស្រីបានរៀបរាប់អំពីព្យសនកម្មផ្លូវចិត្ត។ ខ្ញុំសូមយោងទៅលើឯកសារ D22/366 លោកស្រីបានឆ្លើយថា ការធ្វើអត្តឃាតរបស់ឪពុករបស់លោកស្រីក្រោយពីពេលខ្មែរក្រហមគំរាមកំហែង គឺជាព្យសនកម្មផ្លូវចិត្តដែលលោកស្រីបានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះខ្ញុំសូមឲ្យលោកស្រីពន្យល់ជូនតុលាការថា តើនៅក្នុងកាលៈទេសៈណាដែលឪពុករបស់លោក ឈានចូលទៅដល់ការធ្វើអត្តឃាតខ្លួនឯង? តើគាត់ធ្វើអត្តឃាតរបស់គាត់នេះធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍លោកស្រីយ៉ាងដូចម្តេចដែរ?

[១៥:៣៦:៥២]

**លោកស្រី សៀង ចាន់ធី៖**

**ឆ៖** នាងខ្ញុំសូមរៀបរាប់ពីរឿងប្រវត្តិគ្រួសាររបស់នាងខ្ញុំ ដែលជាជនជាតិវៀតណាម កាត់ជនជាតិវៀតណាម។ ឪពុកខ្ញុំជាជនជាតិវៀតណាម ជីដូនជីតាខ្ញុំ គាត់ជាវៀតណាមក្នុងស្រុកខ្មែរ។ ពីឆ្នាំ១៩៧៥ នៅក្រោយថ្ងៃ១៧ មេសា ពួកប៉ុល ពត បានជម្លៀសពួកគ្រួសារនាងខ្ញុំកាត់ពីស្ពានអូរស្ទាច់មកឆ្លងកាត់ស្ពានអូរស្ទាច់មក ដើម្បីធ្វើដំណើរទៅភូមិឈូកស ឃុំឈើទាល ស្រុកស្វាយជ្រំ ដែលជាស្រុកកំណើតរបស់ឪពុក និងម្តាយខ្ញុំ។ ពេលទៅដល់ស្រុកកំណើតឪពុក និងម្តាយខ្ញុំ ពួកខ្ញុំជាពួក១៧មេសា ពេលទៅដល់ហ្នឹង ពួកប្រជាជនចាស់ គេតែងតែមើលងាយពួកខ្ញុំថា ពួកខ្ញុំជាពួកសក្តិភូមិ នាយទុន និងជាសាច់ឈាមកាត់វៀតណាម។ ដល់ពេលអ៊ីចឹងទៅ ការគំរាមកំហែងពីមួយថ្ងៃទៅមួយថ្ងៃ ដែលធ្វើឲ្យឪពុកខ្ញុំ គាត់មិនអាចទ្រាំរស់នៅហ្នឹងបាន ប្រហែលជាកន្លះខែ គាត់ក៏បានធ្វើដំណើរពីភូមិឈូកស មក

កាន់នៅភូមិឫស្សីព្រៃ ឃុំចំលង ស្រុកស្វាយជ្រំ ក្នុងខេត្តស្វាយរៀងដដែល។

ពេលធ្វើដំណើរមកបានប្រហែលជាកន្លះខែទៅ២០ថ្ងៃ ខ្ញុំអត់ចាំទេ កាលហ្នឹង ក៏បងប្រុសខ្ញុំពីរនាក់ទៀត ជម្លៀសពីភ្នំពេញទៅ។ គាត់ជាទាហាន និងជាប៉ូលិស។ ពេលទៅដល់បានប្រហែលជាកន្លះឬ២០ថ្ងៃដែរ ពួកវាបាននាំគាត់ទៅរៀនសូត្រ យកទៅរៀនសូត្រ។ ពេលដែលយកគាត់ទៅរៀនសូត្រហ្នឹង បានប្រហែលជា៥ទៅ៦ខែ ក៏វាដោះលែងមកវិញ ឲ្យមកធ្វើការជាទម្ងន់នៅក្នុងភូមិ។ ប៉ុន្តែដល់ពេលចុងក្រោយមក ឆ្នាំ១៩៧៦មិនដឹង ក៏៧៧មិនដឹង នាងខ្ញុំចាំមិនច្បាស់ ក្នុងខែស្ទួង ពេលថ្ងៃរសៀលម៉ោងប្រហែលជាបួនទៅប្រាំ ខ្ញុំបានឃើញកងឈ្លបវាចាប់បងប្រុសខ្ញុំ បងចន្ថា ដែលគាត់ផ្លាស់ពីឫស្សីព្រៃទៅនៅខាងបាសាក់ ចងដៃអូសតាមកង់ ហើយនិងវាយ។ ខ្ញុំពេលហ្នឹង ខ្ញុំឃើញ ។គាត់ស្រែកប្រាប់ថា "អូនអើយប្រាប់ម៉ែហើយប៉ាផង បងគេចាប់ហើយ"។ ខ្ញុំអត់ហ៊ានប្រាប់ម្ដាយខ្ញុំទេ ព្រោះម្ដាយខ្ញុំមានជំងឺម្យ៉ាង គឺជំងឺស្ទះដង្ហើម ខ្ញុំអត់ហ៊ានប្រាប់ទេ។

[១៥:៣៩:៥៤]

រហូតទាល់តែដល់ពេលប្រហែលជាកន្លះខែក្រោយមក មានគេលួចមាន់នៅក្នុងភូមិខ្ញុំហ្នឹង គេក៏ចាប់ពួកហ្នឹងទៅមន្ទីរស្រុកហ្នឹងដែរ គេជួបគាត់។ ជួបគាត់ បានគាត់មកវិញ គេលែងគាត់មកវិញ គាត់និយាយប្រាប់ថា បងខ្ញុំឈ្មោះ ចន្ថា ត្រូវគេចាប់យកទៅមន្ទីរស្រុកហើយ។ ពេលដែលខ្ញុំឃើញបងខ្ញុំគេចងដៃ ហើយរត់តាមកង់វ៉ៃ អ្នកណាឃើញក៏យកព្រនង់វ៉ៃគាត់ ដូចជាសត្វធាតុ។ ខ្ញុំ ការចងចាំរបស់ខ្ញុំនៅទាល់តែសព្វថ្ងៃហ្នឹង។ រហូតដល់ពេលឆ្នាំ៧៧ ខ្ញុំក៏មិនចាំខែច្បាស់ដែរ ពេលដែលវៀតណាមវ៉ៃចូលម្ដងទៀត ពេលវៀតណាវ៉ៃចូល ពេលហ្នឹង ប្រជាជនទាំងអស់គេត្រូវគេជម្លៀសចេញពីភូមិ ទៅតាមផ្លូវ។ ដល់ពេលហើយស្រាប់តែឃើញពួករៀនសូត្រហ្នឹងគេចងទាំងខ្សែទៅ ក៏ឃើញបងខ្ញុំ ម្ដាយខ្ញុំក៏ឃើញបងខ្ញុំ គាត់រត់យកបាយឲ្យ គាត់ស្រែកសុំម៉ែ ខ្ញុំសុំបាយហូប។ ម្ដាយខ្ញុំយកបាយរត់ទៅឲ្យ ប៉ុន្តែមិនបានដល់ដៃបងខ្ញុំទេ។ អ្នកដទៃយក ប៉ុន្តែកងឈ្លបគេដឹងថាម្ដាយខ្ញុំយកបាយឲ្យបងខ្ញុំ គេវ៉ៃបងខ្ញុំសុទ្ធតែគល់ឫស្សី ពេលខ្ញុំទៅមើលគោ មើលក្របី ឃើញគេវ៉ៃបងខ្ញុំដូចសត្វ ដូចធាតុទៀត។ ហើយម្ដាយខ្ញុំ គាត់គ្រាន់តែបានរត់តាមកូន គាត់ស្រែកកូនមាសម្ដាយ ម្ដាយយកបាយឲ្យកូន តែមិនដល់កូនទេ។ ម្ដាយខ្ញុំយំបោកខ្លួនព្រោះអាណិតកូន។ ប៉ាខ្ញុំគាត់ឱបម្ដាយខ្ញុំថា កុំនេះ ខ្លាចគេធ្វើបាបកូនកាន់តែច្រើន។ ដល់ពេលហើយ ក៏គេ ខ្ញុំនៅដូនលែប បានប្រហែលជា១០ថ្ងៃ វៀតណាមដកថយទៅវិញទៅ។ ដកថយទៅវិញ ពួកខ្ញុំគេឲ្យមកនៅភូមិស្វាយថ្លាវហ្នឹង នៅក្នុងឃុំតាសួស នៅក្នុងស្រុកស្វាយជ្រំដដែល។

[១៥:៤២:២៦]

មកនៅភូមិហ្នឹងគេបាន អ្នកសហករណ៍គេឲ្យពួកខ្ញុំហ្នឹងមក មកកងកម្លាំងស្រួច កម្លាំងទី១ គេឲ្យមកធ្វើការសមរភូមិមុខ។ ពេលព្រឹកឡើងពីព្រលឹម មកពេលល្ងាចត្រឡប់ទៅវិញ រៀងរាល់ថ្ងៃអ៊ីចឹង។ ប៉ាខ្ញុំ ហើយនិងម្ដាយខ្ញុំ គាត់នៅភូមិ ព្រោះអីប៉ាខ្ញុំ គាត់អ្នកដាំដំណាំ គាត់មិនអាចវិលទៅសមរភូមិក្រោយវិញទេ ទៅតែខ្ញុំ ហើយម្ដាយខ្ញុំទៅដែរ នៅតែប៉ាខ្ញុំទេនៅមុខ។ ដល់ពេលថ្ងៃមួយ ខ្ញុំទៅច្រូត ទៅច្រូតឆ្ងាយពីផ្ទះប្រហែលជាដី៤គីឡូ ទៅហ្នឹងខ្ញុំ បងប្រុសខ្ញុំ បងចាន់ថន ក៏គាត់ទៅដែរ។ ស្រាប់តែខ្ញុំចេះតែបាត់គាត់ អត់ឃើញសោះថ្ងៃហ្នឹង អត់ឃើញហូបបាយ។ ខ្ញុំរកសួរ គេថា មិនបាច់ទៅសួរទេ។ រកបងចាន់ថន ខ្ញុំ។ ដល់ពេលហើយ ស្រាប់តែខ្ញុំមកវិញ ក៏ខ្ញុំសួរប៉ាខ្ញុំថា ប៉ាៗម៉ែ បងចាន់ថន ទៅណាហើយ? ម្ដាយខ្ញុំគាត់ឆ្លើយថា "បងអ្នែង គេយកទៅសែងអីវ៉ាន់ឈ្លបហើយកូន។ សែងអីវ៉ាន់ឈ្លបលែងមកវិញហើយកូន បងគេយកទៅវ៉ៃចោលហើយ។ គេយកទៅប្អូននាក់។" ខ្ញុំកាលនោះ ខ្ញុំមិនហ៊ានយំឮទេ ខ្ញុំខ្សឹបយំឱបម្ដាយខ្ញុំ ប៉ាខ្ញុំយំ ខ្សឹប។

ពេលគេយកបងខ្ញុំទៅបាន ប៉ុន្មានថ្ងៃក្រោយមក គ្រួសារវៀតណាមនៅក្នុងភូមិខ្ញុំ មានបីគ្រួសារទាំងគ្រួសារខ្ញុំ គេយកគ្រួសារទី១ទៅ កូនស័ក្តិ៤ដែលម្ដាយគាត់ជាជនជាតិវៀតណាម។ ពេលនោះហើយដែលប៉ាខ្ញុំគាត់ពិបាកចិត្ត ព្រោះគាត់បានឃើញគេចាប់រំលោភកូនស្រីទាំងពីររបស់គ្រួសារវៀតណាមដែលគេយកទៅនោះ។ គាត់មកខ្សឹបប្រាប់ម្ដាយខ្ញុំ និងម៉ែខ្ញុំថា ឯងអើយ ខ្ញុំឃើញគេចាប់រំលោភកូនស័ក្តិ ៤ ថុន។ ដូច្នេះខ្ញុំមិនចង់រស់ទេ។ ខ្ញុំសាច់ឈាមមិនដូចគេទេ សាច់ឈាមខុសគេ ខ្ញុំមិនឲ្យគេយកទៅទេ ព្រោះគេយកទៅសម្លាប់ឈឺណាស់។ ខ្ញុំប្រហែលជាធ្វើអត្តឃាតហើយ។ ម្ដាយខ្ញុំថា "បងអើយ បងកុំៗអាលសម្លាប់ខ្លួនអី ចាំគេហៅ ចាំបងធ្វើ"។ ប៉ុន្តែប៉ាខ្ញុំគាត់បានធ្វើអត្តឃាតពីរដង ដោយចងនឹងក្រមា ចងនឹងក្រមា ម្ដាយខ្ញុំដេរក្រមាហើយ ប្រាប់គាត់ថា កុំអាលបង ចាំគេហៅ ចាំទៅ។ គាត់ថាគាត់នៅមិនបានទេ គាត់ហូបបាយក៏មិនបានដែរ។ ប៉ាខ្ញុំដោះអាវមក ស្គម ស្បែកហើយនិងឆ្អឹង។ ខ្ញុំថា "ប៉ា ម៉េចស្គមម្ល៉េះ? កូនអើយ ប៉ាហូបបាយអត់បានទេ ប៉ាភ័យណាស់។" ព្រោះកាលណាគេឃើញ ប្រធានសហករណ៍គេឃើញគាត់ហ្នឹង "តាធឿង តាឯងយួនសុទ្ធ។ តាឯងហ្នឹងអាយ៉ងយួន។ សាច់ឈាមតាឯង មិនច្រឡំមិនច្រឡំឯងទេ យួនសុទ្ធតែម្ដងតាឯង។" ប៉ាខ្ញុំភ័យ គាត់មិនដែលហ៊ានងើបមើលមុខគេទេ។

[១៥:៤៦:០៧]

ពេលយប់គាត់និយាយជាមួយម៉ែខ្ញុំថា "បើគាត់ស្លាប់ទៅ គ្រាន់នឹងមានកូនឃើញផ្នូរ ហើយកូន

ភ្នែកខ្មៅៗទាំងប្រាំមួយនាក់ហ្នឹង ក្រែងបានរស់នៅជាមួយគេ ច្រឡំសាច់ៗឈាម ច្រឡំគេ ច្រឡំឯង ភ្នែកខ្មៅៗ បើខ្ញុំស្លាប់ទៅ កូនអាចនៅរស់។" ហើយខ្ញុំក៏ចេះតែអង្វរគាត់ដែរ "ប៉ាអើយប៉ា ប៉ាឯងកុំអាលទៅណាចោលកូន។" គាត់ចេះតែផ្តាំថា "កូនអើយ កូនឯងនៅហ្នឹងកូនឯងធំជាងគេ បងស្រីអ្នែងពីរនាក់គាត់ទៅចល័ត គាត់អត់ដឹងអីទេ។ អ្នែងធំជាងគេ ជួយមើលថែរក្សាប្អូនផង អត់ពីប៉ាទៅ។ ចេះស្រឡាញ់បងប្អូន ចេះយល់ចិត្តគ្នា ចេះថែរក្សាគ្នា ព្រោះប៉ាសាច់ឈាមខុសគេ ឲ្យប៉ាទៅតែឯងទៅ។"

បានក្រោយពីបងខ្ញុំស្លាប់បានមួយអាទិត្យ ប៉ាខ្ញុំក៏គាត់ធ្វើអត្តឃាត។ គាត់ចងកនឹងដើមព្រីង នឹងខ្សែគោ។ ពេលដែលគាត់ចងកស្លាប់ ខ្ញុំមិនបាននៅ ព្រោះគេឲ្យខ្ញុំទៅច្រូតនៅប្រហែល៤គីឡូពីភូមិ នៅតែប្អូនប្រុសខ្ញុំបីនាក់ទៀត។ ពេលដែលព្រឹកឡើង ម៉ោងប្រហែលជាប្រាំបី គេស្រែកថា ន៎! មើលទៅដើមព្រីងជើងអ្នំ ម្តាយខ្ញុំគាត់ដឹង គាត់ដឹងថាគ្មានពីណាទេ ម្តាយខ្ញុំទម្លាក់ចង្អេរ ទម្លាក់ល្អីចុះ គាត់ថា គាត់ស្រែកហៅ "បងៗ" ព្រោះម្តាយខ្ញុំ គាត់ហៅប្តីតែបងទេ គាត់មិនដែលហៅអីទេ។ គាត់ថា គ្មានពីណាទេ "បងហើយ" ទៅដល់គេថា កាប់ទម្លាក់មក។ មនុស្សចងក កាប់ទម្លាក់មក ម៉ែខ្ញុំថា "អត់ទេ កុំកាប់គាត់ទម្លាក់ ដាក់គាត់ឲ្យស្រួលបួល។"

[១៥:៤៩:០៨]

ពេលគេដាក់ប៉ាខ្ញុំចុះមក ពួកប៉ុលពត ប្រធានសហករណ៍ វាថា "ចងខ្សែអូសទៅ ចងខ្សែអូសតាមភ្លឺស្រែ យកទៅកប់ទៅ" តែម្តាយខ្ញុំគាត់យំឱបៗសពប៉ាខ្ញុំ គាត់ថា អត់ឲ្យធ្វើអីចឹងទេ អត់ឲ្យធ្វើអីចឹងទេ ប្តីគាត់មិនដែលប្រឆាំងនឹងបដិវត្តន៍ទេ ព្រោះគាត់ភ័យ គាត់ខ្លាចគ្រួសារយៀកណាម ពីរគ្រួសារយកទៅអស់ហើយ យកកូនគាត់ទៅបាន៧ថ្ងៃហើយ យកកូនគាត់ទៅសម្លាប់ហើយ គាត់ខ្លាចស្លាប់ដូចកូនគាត់ បានជាគាត់ចងក ដើម្បីឲ្យកូនប្រាំមួយនាក់ទៀតនៅរស់។ គាត់សុខចិត្តធ្វើអត្តឃាត ដើម្បីកូន។ ពេលគេយកប៉ាខ្ញុំទៅកប់ អស់លោកដឹងទេ ប៉ាខ្ញុំគេយកទៅ ក្តារមឈូសគាត់ស្ពឹកត្នោត។ គេធ្វើពីស្ពឹកត្នោត ជើងក៏មិនជិតដែរ ចេញជើងប៉ាខ្ញុំមកក្រៅ ខ្ញុំឮម្តាយនិយាយប្រាប់។

មិនយូរប៉ុន្មានប្រហែលជាពីរបីថ្ងៃក៏មិនដឹង ១០ថ្ងៃក៏មិនដឹង ខ្ញុំមិននចាំទេ ពេលនុំងខ្ញុំនៅក្មេងដែរ មានអ្នកគេមកខ្សឹបប្រាប់ខ្ញុំទៀត តែខ្ញុំសូមបកក្រោយវិញ និយាយបកក្រោយវិញពីបងខ្ញុំ បងចន្ថា ដែលជាប់គុកនៅមន្ទីរស្រុកតាសួស។ ខ្ញុំសូមបកក្រោយវិញ មុននឹងពេលប៉ាខ្ញុំស្លាប់។ ពេលដែលខ្ញុំដើរមកតាមផ្លូវមកធ្វើការ ខ្ញុំដើរតាមផ្លូវហ្នឹង អ្នករៀនសូត្រគេឲ្យច្រូត ខ្ញុំដើរតាមភ្លឺស្រែ ខ្ញុំឃើញបងប្រុសខ្ញុំ ខ្ញុំអត់ស្គាល់ទេ ព្រោះគាត់ស្គម នៅសល់ស្បែកហើយនិងឆ្អឹង។ ពេលដែលខ្ញុំដើរមកដល់គាត់ថា គាត់ហៅខ្ញុំ

ខ្ញុំមិនស្គាល់គាត់ទេ គាត់ហៅខ្ញុំឈ្មោះនៅផ្ទះ អាម៉ែ ខ្ញុំថាអីបង បងឯងក៏ស្គមម្ល៉េះ។ ថាអូនអ្នកមានថ្នាំជក់ដែរ ឲ្យបងជក់ផង។ ហើយម្ដាយខ្ញុំគាត់ៗដឹងថាបងខ្ញុំធ្វើការនៅហ្នឹង គាត់វេចថ្នាំដាក់ត្បៀតក្លៀក ខ្ញុំថាម៉ែទម្លាក់ទៅម៉ែ។ ម៉ែខ្ញុំគ្រាន់ឃើញ កូនមាសម្ដាយ។ គាត់បានតែឃើញកូនមាសម្ដាយ ម៉ែ ប៉ុណ្ណឹង ទម្លាក់ថ្នាំឲ្យបងខ្ញុំស្រវាវេច ស្រវាវេចលាក់ពីកងឈ្លបគេហ្នឹង។ ស្រាប់ដល់ពេលហើយមើលតាមសម្លឹងមើលម្ដាយខ្ញុំ។ សម្លឹងរហូត ព្រោះខ្លាច បើម៉ែលាក់បាយឲ្យហូប តែម៉ែមិនហ៊ានលាក់ទេ ខ្លាចគេវ៉ៃកូនទៀត។ ខ្លាចគេធ្វើបាបកូនទៀត។

[១៥:៥២:៣១]

**លោក ប៊ុន លឹមហួរ៖**

មានអារម្មណ៍វិលមុខអត់ទេ?

**លោកស្រី សៀង ចាន់ធី៖**

**ឆ៖** អត់ទេ! អត់អីទេ គ្រាន់តែខ្ញុំកំសួល។ ពេលដែលបានជួបបងខ្ញុំហើយ ម្ដាយមកវិញហ្នឹង គាត់ពិសាទឹក គាត់អួលវិះស្លាប់ទៀត។ គ្រាន់តែពិសាទឹកក្អឹកចូល គាត់ថាកូនអើយជួយម៉ែផង អួលទឹកហើយ ខ្ញុំភ័យណាស់។ ភ័យណាស់ គួកម៉ែផងអីផង ម៉ែអើយៗម៉ែ។ គាត់ក្ដាប់ដៃក្ដាប់ជើង គាត់ពិបាក គាត់ថាម៉ែ គាត់ចេះតែធ្វើអ៊ីចឹង ដល់ហើយខ្ញុំគួកៗអ៊ីចឹង ឮសូរតែក្រឹតអ៊ីចឹងទៅ ស្រាប់ទឹកចុះទៅ បាន គាត់ដឹងខ្លួនវិញ។ នេះជាការពិតមិននិយាយភូតកុហកអង្គតុលាការទាំងមូលទេ នេះជាការពិតទុក្ខសោករបស់ក្នុងគ្រួសារខ្ញុំពិត ដែលខ្ញុំជួបប្រទេះ។

ក្រោយមកបាន ខ្ញុំនិយាយត្រឡប់ក្រោយទៅវិញ។ ដល់ពេលប៉ាខ្ញុំស្លាប់ហើយ ម្ដាយខ្ញុំគាត់ឃុំខ្លួននៅក្នុងផ្ទះរយៈពេល៣ខែ គាត់អត់ចេញទៅជួបអ្នកណាទាំងអស់ គាត់គិតតែយំ។ ម្ដាយខ្ញុំបាយក៏គាត់អត់ពិសា។ ពិសាបាយបានបន្តិចៗហ្នឹង ដោយសារខ្ញុំបញ្ចុកអ៊ីចឹង គាត់រកតែធ្វើអត្តឃាតទៀត។ តែខ្ញុំចេះតែអង្វរគាត់ ម៉ែអើយៗ ប៉ាទៅហើយ នៅតែម៉ែឯង កូនតូចៗឲ្យកូនសង្ឃឹមអី ម៉ែត្រូវតែទ្រាំរស់។ ម្ដាយខ្ញុំថ្ងៃណាក៏គាត់យំ ថ្ងៃណាក៏គាត់យំ យំរហូតដល់ខះទឹកភ្នែកអស់ យំដល់លែងចេញទឹកភ្នែក រហូតដល់គាត់គ្រាន់តែគាត់ស្វាបអ៊ីចឹង ថ្កាមគាត់នៅជាប់នៅហ្នឹង ទាល់តែដាក់ទះអ៊ីចឹងទៅបានធ្លាក់ទៅវិញ។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី!

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[១៥:៥៥:៣១]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោកស្រី សៀង ចាន់ធី៖**

**ឆ៖** បន្ទាប់គេយកប៉ាខ្ញុំទៅកប់ហ្នឹង ខ្ញុំអត់នៅផ្ទះទេ។ ពេលល្ងាច ពេលល្ងាចបានខ្ញុំមកពីច្រូតវិញ មកពីច្រូតវិញ ខ្ញុំឃើញប្អូនខ្ញុំ ប្អូនពៅខ្ញុំប្រហែលជាអាយុប្រាំមួយប្រាំពីរឆ្នាំ កម្ពស់នេះ ឃើញមុខស្លូត ខ្ញុំមិនដឹងទេគេអត់ប្រាប់ថាប៉ាស្លាប់ផង។ ខ្ញុំមកដល់សួរ "អាអូនៗថីហ្នឹងអូន?" វាអត់ស្ដីខ្ញុំទេ។ ដល់ពេលហើយខ្ញុំដើរចូលទៅក្នុងផ្ទះ ចូលដល់ក្នុងផ្ទះ ម៉ែខ្ញុំគាត់ប្រាប់ខ្ញុំថា ទៅស៊ីបាយទៅកូន ៗឯងទៅស៊ីបាយ ហើយយកបាយរោងបាយមកឲ្យប្អូនស៊ីផង។ ពេលដែលខ្ញុំដើរទៅដល់រោងបាយ ខ្ញុំឃើញគេសម្លឹងមុខខ្ញុំគ្រប់គ្នា ខ្ញុំ ដល់ពេលគេសម្លឹងមុខខ្ញុំគ្រប់គ្នា ខ្ញុំថា "អ្ហ៎ អ្នកទាំងអស់គ្នាសម្លឹងមុខអីចឹង គ្រួសារខ្ញុំប្រហែលជាថ្ងៃហ្នឹងត្រូវដល់ថ្ងៃគេយកទៅវាយចោលហើយ។" ខ្ញុំដើរបណ្ដើរ ខ្ញុំស្មាបកខ្ញុំបណ្ដើរ អ្ហ៎! មិនដឹងគេកាប់អញត្រង់ណាទេ កាប់មួយកាំបិតដាច់ងាប់ទៅ ក៏ងាប់ទៅ ឬមួយក៏គេបាញ់។ ដើរទៅដល់សុំបាយគេ ក៏បានមកយកឲ្យម្ដាយខ្ញុំ យកមកអី។ ដល់ពេលហើយម្ដាយខ្ញុំថា "អ្ហ៎! ប៉ាស្លាប់ហើយកូន។" ពេលដែលម្ដាយខ្ញុំប្រាប់ថា ប៉ាស្លាប់ហើយកូន ខ្ញុំណាបងទើបតែស្លាប់ថ្មីៗ ខ្ញុំពេលហ្នឹងយំអត់ចេញ។ ពាក្យថា "យំមិនចេញ" គឺខ្ញុំឆ្លងកាត់ហើយ លោកតុលាការទាំងមូល។ អត់មានទឹកភ្នែកយំទេ យំអត់ចេញ មិនដឹងយំថាយ៉ាងម៉េច ស្រែកថាម៉េច ឲ្យចេញទឹកភ្នែកមក អត់ទេ គឺខ្ញុំគាំង ខ្ញុំនៅស្ងៀម ខ្ញុំអត់ដឹងយំថាម៉េច ម្ដាយខ្ញុំចេះតែយំបោកខ្លួន ខ្ញុំឱបម្ដាយខ្ញុំ។

[១៥:៥៧:២៦]

ដល់ពេលព្រលប់ៗងងឹតៗ ទៅម្ដាយខ្ញុំគាត់ហុចៗដែកកេះឲ្យខ្ញុំ។ ហុចដែកកេះឲ្យខ្ញុំ ថា "កូនណេះយកដែកកេះទៅអុជចន្លុះទៅ ឲ្យភ្លឺផ្ទះ"។ ពេលដែលម៉ែខ្ញុំហុចដែកកេះមកឲ្យខ្ញុំ បានខ្ញុំយំចេញ ព្រោះខ្ញុំថា រាល់ថ្ងៃប៉ាខ្ញុំហុចឲ្យខ្ញុំ រាល់ថ្ងៃគាត់ប្រើ "នែ៎អាមែ អ្ហែងយកដែកកេះទៅអុជចង្កៀងទៅកូនឲ្យវា អុជចន្លុះទៅឲ្យភ្លឺ"។ ពេលម្ដាយខ្ញុំហុចដែកកេះឲ្យខ្ញុំ ៗនឹកឃើញថា ចាប់ពីពេលនេះទៅ ខ្ញុំអត់មានឪពុកហៅនឹងគេទៀតហើយ ខ្ញុំអស់ឪពុកហើយ ខ្ញុំជាកូនកំព្រាឪពុក។ ភាពភ័យខ្លាចរបស់ខ្ញុំ ខ្ញុំជាកូនកាត់វៀតណាម មិនដឹងថ្ងៃណាគេយកខ្ញុំទៅទៀត ព្រោះខ្ញុំរស់មួយថ្ងៃ ព្រឹកឡើងថ្ងៃរះ ខ្ញុំដឹងតែខ្ញុំរស់ហើយ ពេលថ្ងៃរសៀលម៉ោងពីរទៅម៉ោងបី ខ្ញុំដឹងថាខ្ញុំភ័យខ្លាច ខ្លាចគេយកទៅវាយចោល។ ដូច្នេះខ្ញុំធ្វើការ គ្មានអ្នកណាស្ដីរកខ្ញុំទេ។ ទៅលើកដី លើកម្នាក់ឯង កណ្ដៀតម្នាក់ឯង គេសែងពីរនាក់ ខ្ញុំលើកម្នាក់

ឯងមួយបង្គី លើកកណ្តៀតយកទៅចាក់។ ដល់ពេលគេអត់ស្លីខ្ញុំ ខ្ញុំសួរ លួចសួរអ្នកកងនារីដូចគ្នា "ហេតុអីបានពួកអ្នែងអត់ស្លីខ្ញុំ?" ថាអ៊្ហូ ឈ្មោះខ្ញុំនៅជាមួយអាពត ឈ្មោះខ្ញុំដាក់ឈ្មោះថា "យ៉ា" ថា "អ្នាមីយ៉ាអើយ ម៉ែអញឪអញមិនឲ្យស្លីរកអ្នែងទេ ព្រោះអីអ្នែងកូនកាត់យួន ខ្លាចគេយកអ្នែងទៅវាយចោល វាយដោយអញទៀត។" ម្ល៉ោះហើយខ្ញុំធ្វើការអីធ្វើតែម្នាក់ឯង ហូបបាយក៏តែម្នាក់ឯង។ ការងារ គេធ្វើពីរនាក់ ខ្ញុំធ្វើម្នាក់ឯង។ ក្នុងសម័យនោះ ហេតុអីបានគេរអើងជនជាតិវៀតណាម ដែលខ្ញុំគ្រាន់តែជាប់សាច់ជាប់ឈាមបន្តិចបន្តួច ខ្ញុំមិនទាំងដែលចេះវៀតណាមមួយម៉ាត់ផង។

ការរស់នៅជំនាន់ប៉ុល ពត ខ្ញុំរស់ទាំងភ័យខ្លាច អារម្មណ៍ដិតដាម ខ្លាចតែគេយកទៅវាយចោល។ ហើយនៅពេលដែលខ្ញុំថ្លែងទុក្ខប្រាប់អស់លោកទាំងអស់គ្នាស្តាប់ ប្រៀបដូចជារឿងហ្នឹងនៅថ្មី នៅមុខខ្ញុំប្រៀបដូចជាខ្សែវីដេអូមួយដែលចាក់បញ្ចាំងរឿងឈឺចាប់ទាំងប៉ុន្មាន ដែលខ្ញុំមានឆ្លងកាត់ពីជំនាន់ ប៉ុល ពត មក ដែលខ្ញុំព្រាត់ប្រាសឪពុកជាទីស្រឡាញ់ បងប្រុសទាំងពីររបស់ខ្ញុំដែលគេធ្វើទារុណកម្ម។ រហូតដល់សព្វថ្ងៃសូម្បីតែគេចាប់បានចោរ វ៉ៃនឹងមុខខ្ញុំ ក៏ខ្ញុំមិនហ៊ានមើលដែរ ព្រោះទិដ្ឋភាពទាំងអស់ហ្នឹងដែលខ្ញុំមើលឃើញគេវ៉ៃចោរ ប្រៀបដូចជាគេវ៉ៃបងខ្ញុំជំនាន់ ប៉ុល ពត នៅមុខខ្ញុំ ដែលខ្ញុំនៅដិតដាមរឿងនេះជាប់អារម្មណ៍ខ្ញុំជារៀងរហូតមក។

[១៦:០១:១២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោកស្រី សៀង ចាន់ធី ដំណើរការសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកបន្តធ្វើសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ព្យសនកម្ម និងផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួន។

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក ប៊ុន លឹមហួរ បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយសម្របសម្រួលក្នុងការធ្វើសេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី អ៎! សៀង ចាន់ថី។ ហើយនាពេលនេះ លោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី សៀង ចាន់ថី វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងសូមឲ្យ

អញ្ជើញគាត់មកចូលរួមសវនាការវិញនៅថ្ងៃស្អែកដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយសវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០១ ខែមីនា ឆ្នាំ ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនា និងព្យសនកម្មដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមាន គឺលោកស្រី សៀង ចាន់ថី បន្តបញ្ចប់ និងដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1014 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*